01418362 **E1/350.1**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥**

**ម៉ោង ០៩:០៤នាទី**

**សវនាការលើកទី៣៣១**

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 21-Mar-2017, 09:58
CMS/CFO: Sann Rada

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*
ចៅក្រម យ៉ា សុខន
ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍
*(Judge Jean-Marc LAVERGNE)*
ចៅក្រម យូរ ឧត្តរា
ចៅក្រម ធូ មណី (បម្រុង)
ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី
កញ្ញា រ៉ូប៊ីន្ទី ក្រូហ្វត៍ *(Ms. Robynne CROFT)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*
លោក សេង លាង
លោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*
លោក ស្រ៊ា រតនៈ
លោក ចូសេហ្វ អេនឌ្រូ ប៊យលី
*(Mr. Joseph Andrew BOYLE)*

**ជនជាប់ចោទ៖**

លោក នួន ជា
លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍
*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡៃ ជុនធី

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក ស្រ៊ា រតនៈ | ខ្មែរ |
| លោក ចូសេហ្វ អេនឌ្រូ បិយលើ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក រ៉ិចច័រ កូប៉េ | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោក ឡោ ជុនធី | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក ហ៊ីម ម៉ាន (2-TCCP-252) | ខ្មែរ |
| លោកស្រី នោ សាទះ (2-TCCP-270) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី÷ លោក ហ៊ឹម ម៉ាន** (2-TCCP-252)

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី.......................................................................ទំព័រ ៩

សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្ដើមពី.................................................................ទំព័រ ២៩

**ការសួរសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី÷ លោកស្រី នោ សានះ** (2-TCCP-270)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ......................................................................ទំព័រ ៣៦

សួរដោយលោក ឡោ ជុនធី ផ្ដើមពី......................................................................ទំព័រ ៣៨

សួរដោយលោក ស្រ៊ា រតនៈ ផ្ដើមពី ....................................................................ទំព័រ ៥៤

សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី ផ្ដើមពី ....................................................ទំព័រ ៥៩

# កិច្ចដំណើរការនីតិវិធី

[០៩:០៤:១៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅថ្ងៃនេះ តាមកាលវិភាគដែលបានគ្រោងទុក ហើយនិងជម្រាបជូនដល់ភាគីរួចហើយ អង្គជំនុំជម្រះនឹងបន្តធ្វើសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ហ៊ឹម ម៉ាន បន្តបញ្ចប់ ហើយនិងផ្តើមស្តាប់សក្ខីកម្មរដ្ឋប្បវេណី ដែលមានរហស្សនាម 2-TCCP-270។

ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍ពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! សម្រាប់សវនាការនៅថ្ងៃនេះក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ។

លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ហើយដើមបណ្តឹងរដ្ឋប្ប វេណីដែលត្រូវមកផ្តល់សក្ខីកម្មបន្តបញ្ចប់នៅថ្ងៃនេះ គឺលោក ហ៊ឹម ម៉ាន លោកមានវត្តមាននៅបន្ទប់ រង់ចាំៗការកោះហៅពីអង្គជំនុំជម្រះ។ ហើយដើមបណ្តឹងរដ្ឋប្បវេណីបន្ទាប់ដែលត្រូវមកផ្តល់សក្ខីកម្មគឺ ដើមបណ្តឹងដែលមានរហស្សនាម 2-TCCP-270។ ដើមបណ្តឹងរូបនេះ ក៏មានវត្តមាននៅបន្ទប់រង់ចាំៗ ការកោះហៅពីអង្គជំនុំជម្រះផងដែរ។ សូមអរគុណលោកប្រធាន។

[០៩:០៦:០១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី សែ កុលវុឌ្ឍី។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធិភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ ២០១៥។ មេធាវីការពារក្តីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថាជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុងតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥ បានកត់សម្គាល់អំពីស្ថានភាពសុខភាពរបស់លោក នួន ជា ថាមានអាការៈឈឺចង្កេះជាប្រចាំ វិលមុខ មិនអាចអង្គុយយូរបាន និងបានផ្តល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥)នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

[០៩:០៧:៥៩]

ហើយដោយអង្គជំនុំជម្រះបាន -- ទើបតែទទួលនូវសំណើសុំថ្មីចុងក្រោយរបស់ការិយាល័យសហព្រះរាជអាជ្ញាដែលបានស្នើសុំឲ្យអង្គជំនុំជម្រះទទួលយកនូវឯកសារភស្តុតាងថ្មី ដែលជាប្រភេទកំណត់ហេតុស្តាប់សក្ខីកម្មសាក្សីពីសំណុំរឿង០០៣ និង០០៤ ដែលសុំដាក់បញ្ចូលទៅក្នុងសំណុំរឿង ០០២ តាមវិធានផ្ទៃក្នុង៨៧(៤) ហើយនិងបន្ទាប់មកទៀត ក្រោយពីមានសំណើនេះ មានភាគីសហមេធាវីការពារក្តី ខៀវ សំផន មានបំណងធ្វើការ ធ្វើសេចក្តីសន្និដ្ឋានតបទៅនឹងសំណើសុំនេះ ដូច្នេះនាពេលនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីដើម្បីមានលទ្ធភាព និងមានឱកាសក្នុង

ការធ្វើការសារណាតបទៅនឹងសំណើសុំនេះជាមុនសិន មុននឹងស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី។

សូមអរញ្ជើញ!

**កញ្ញា អង់តា ហ៊ុគសសេះ**

សូមអរគុណលោកប្រធាន។ ជម្រាបសួរសហភាគាទាំងអស់គ្នា។ ខ្ញុំសូមធ្វើការបំភ្លឺមួយព្រោះថាយើងបានស្នើសុំក្នុងអ៊ីម៉ែលរបស់យើង<ដែលផ្ញើទៅកាន់អង្គជំនុំជម្រះ> គឺថាមិនសុំឆ្លើយដោយផ្ទាល់មាត់នោះទេ ប៉ុន្តែ<សូមធ្វើការស្នើ>សុំ<ពេលវេលាដោយ>ផ្ទាល់មាត់<>ដើម្បី<ផ្តល់ចម្លើយនេះដោយផ្អែកលើមូលហេតុពីរយ៉ាង> លោកប្រធាន។ ទី១ គឺថាសំណើនេះទាក់<ទង>តែនឹងចម្លើយជាលាយលក្ខណ៍អក្សរដែលចេញពីសំណុំរឿង<០០៣>, <០០៤> ដែលកំពុងតែស៊ើបអង្កេត<ប៉ុណ្ណោះ>។ <ដូច្នេះ> នេះជាសំណើមួយដែល<មិន>មានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងសំណើ<E363> ដែលយើងបានស្នើទៅអង្គជំនុំជម្រះ<>ទាក់ទងទៅនឹងឯកសារ<ទាំងអស់នេះ>ដែលមកពី<ការស៊ើបអង្កេតដទៃ>ទៀតដែលចូលជាបន្តបន្ទាប់<នៅក្នុងសវនាការ>យើងនេះ<ទេ>។ អ៊ីចឹងយើងសូមស្នើសុំ<នូវ>លទ្ធភាពឆ្លើយតបទៅនឹងសំណើរបស់<សហ>ព្រះរាជអាជ្ញា បន្ទាប់ពីអង្គជំនុំជម្រះចេញសេចក្តីសម្រេចមកលើសំណើរបស់យើងដែលមាន E363 សិន។ <ដូច្នេះ នេះជាផ្នែកទី១នៃការស្នើសុំរបស់យើង។ សំណើសុំពេលវេលានេះគឺមានភាពចាំបាច់> ពីព្រោះថានៅក្នុងសំណើ<របស់សហព្រះរាជអាជ្ញា E370> នេះ គឺថា<សហ>ព្រះរាជអាជ្ញាបាន<ស្នើសុំការអនុញ្ញាត>ដាក់ចម្លើយ<សាក្សីទាំង>២៥<ទៅក្នុងសំណុំរឿង ដែលជាកំណត់ហេតុស្តាប់ចម្លើយសាក្សីដ៏ច្រើន>។ <ដូច្នេះក្រៅពី>យើងសូមឲ្យអង្គជំនុំជម្រះមានការបំភ្លឺទៅលើឯកសារ<នៅក្នុងសំណុំរឿង០០៣ និង០០៤> យើង<ក៏ស្នើ>សុំ<>ពេលវេលា<បន្ថែមដើម្បីដោះស្រាយបញ្ហាទាំងនេះឲ្យបានស៊ីជម្រៅ>។ <ដូច្នេះការស្នើសុំនេះ មិនមែនជាការឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាទេ ប៉ុន្តែជាការស្នើសុំ>ឲ្យអង្គជំនុំជម្រះផ្តល់ពេលវេលាឲ្យយើងបន្ថែម <ដោយសារមូលហេតុទាំងអស់ដែលខ្ញុំបានលើកឡើងមុននេះ>។ <ដូច្នេះ ខ្ញុំសង្ឃឹមថា ខ្ញុំបានបំភ្លឺ>ច្បាស់<ជាងមុន លើចំណុចនេះ។ ដើម្បីឲ្យកាន់តែច្បាស់ជាងនេះ យើងស្នើសុំពេលវេលា<នេះដើម្បីចាប់ផ្តើម បន្ទាប់ពីអង្គជំនុំជម្រះ>ចេញសេចក្តីសម្រេចទៅលើសំណើ E363 <ដែលយើងបានដាក់ជាឯកសារកាលពីរបីថ្ងៃមុននេះ។>

[០៩:១១:២២]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ សូមអរគុណលោកប្រធាន។ ជម្រាបសួរអស់លោក លោកស្រីចៅក្រមទាំងអស់គ្នា និង ភាគីទាំងអស់។ ខ្ញុំមើលឃើញថានេះគឺជាសំណើមួយដែលមានលក្ខណៈរឹតត្បិតនៅដំណាក់កាលនេះ<។ ការធ្វើបែបនេះ> គឺ<ដើម្បីពន្យារពេលចំពោះលទ្ធភាពនៃការ>ឆ្លើយ<តប>ទៅនឹងសំណើសុំឱ្យទទួលយក<កំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួន>២៥ឯកសារនេះ<>។ ក៏ប៉ុន្តែទោះយ៉ាងណាក្តី បើសិនជាយើងទទួលសំណើរបស់<ក្រុមមេធាវីការពារក្តី>លោក ខៀវ សំផន នោះគឺវាហួសពេលទៅហើយដើម្បីប្រើកំណត់ហេតុស្តាប់ចម្លើយទាំង២៥នេះក្នុងពេលវេលាសមស្រប <ឬក៏នៅក្នុង>វគ្គមួយដែលពាក់ព័ន្ធនឹង<ជនជាតិ>ចាម<>។ <ហើយនេះជា>អ្វីដែលយើងចង់បាននោះ <លើកលែងតែ>អង្គជំនុំជម្រះចេញសេចក្តីសម្រេចលើការបញ្ជូនឯកសារពីសំណុំរឿងផ្សេងៗមកសំណុំរឿងនេះឱ្យលឿនបំផុតដើម្បីដោះស្រាយបញ្ហាឱ្យបាន។ ក៏ប៉ុន្តែទន្ទឹមនឹងនេះ យើងយល់ឃើញថា ភាគីអាចមានលទ្ធភាពប្រើកំណត់ហេតុស្តាប់ចម្លើយ<ទាំងអស់>ដែល<បានបង្ហាញមុននេះបន្តិច> ដើម្បីអាចចោទសំណួរទៅសាក្សីនិងដើមបណ្តឹងរដ្ឋប្បវេណី។ <នេះជាអ្វីដែល>មេធាវី<ការពារក្តី> នួន ជា និង ខៀវ សំផន <> បានធ្វើ<នា>ពេលកន្លងមកនេះ ដោយមិនបានដាក់ទៅក្នុងឯកសារ<សំណុំរឿង> នូវសំណើដើម្បីប្រើកំណត់ហេតុស្តាប់ចម្លើយទាំងអស់នេះទុកជាភស្តុតាង <ដោយ>មិនបានអនុលោមទៅតាមវិធាន៨៧ (៤) នោះទេ។ <ហើយនេះជារឿងកាន់តែសំខាន់ជាងមុនទៅទៀត ដោយសារ>កំណត់ហេតុស្តាប់ចម្លើយ<មួយចំនួន>ជាកម្មវត្ថុនៃសំណើ E370<។ ទាំង>នេះគឺ<>ជាចម្លើយរបស់សាក្សី<ទាំងឡាយ>ដែលនឹងមកផ្តល់សក្ខីកម្មនៅទីនេះ ហើយ<នេះគឺ>ជាសាក្សីដែលនឹងមកផ្តល់សក្ខីកម្មនៅសប្តាហ៍នេះ<ឬ>សប្តាហ៍ក្រោយទៀត គឺ <2-TCW-950 ឬ>សាក្សីមួយទៀត ដែលអង្គជំនុំជម្រះចង់ស្តាប់ជាអាទិភាពផងដែរ។

[០៩:១៣:៥៣]

បើសិនជាខ្ញុំមិនច្រឡំទេគឺ<សាក្សី 2-TCW-987 ប៉ុន្តែក្រៅពីបញ្ហានេះ> ដើម្បីរកការពិតឱ្យឃើញ ខ្ញុំគិតថាជាការ<ចាំបាច់>ដើម្បី<>ឱ្យភាគីទាំងអស់<អាច>យោងទៅនឹងឯកសារ<ទាំងនេះនិងដកស្រង់ឯកសារទាំងអស់ដើម្បីចោទសួរ>សាក្សី<ទាំងអស់ដែលនឹងមកផ្តល់សក្ខីកម្ម>នៅក្នុងសវ-

នាការសប្តាហ៍នេះ និងសប្តាហ៍បន្ទាប់។ ក៏ប៉ុន្តែ<ជាថ្មីម្តងទៀត> យើងសង្ឃឹមថា អង្គជំនុំជម្រះនឹងចេញសេចក្តីសម្រេចឲ្យលឿនជាងហ្នឹង ដើម្បីឲ្យយើងអាចដោះស្រាយ<>បញ្ហា<ដែល>កើតឡើងជាញឹកញាប់<នេះបាន> ហើយនិងដែលធ្វើឲ្យយើងខាតពេល វេលារបស់តុលាការ។ នេះហើយជាអ្វីដែលយើងចង់និយាយឆ្លើយតបទៅនឹងមេធាវីការពារក្តីលោកប្រធាន។

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន ដែល<អនុញ្ញាតឲ្យខ្ញុំឆ្លើយតប>យ៉ាងលឿន<ទៅសហ>ព្រះរាជអាជ្ញា។ ជាដំបូង <ខ្ញុំ>សូមឲ្យប្រើពាក្យឲ្យច្បាស់ៗ។ <ថ្ងៃនេះ> យើងមានសំណើ<នៃ>វិធាន៨៧(៤) <ដើម្បីស្នើសុំការទទួលស្គាល់ឯកសារមួយចំនួនដែលសហព្រះរាជអាជ្ញាថាជាឯកសារចាំបាច់>ដើម្បីរកការពិតឲ្យឃើញ។ <បើ>ខ្ញុំ<មិនច្រឡំទេ> បើសិនជាឯកសារនេះបានបញ្ជូនមកតាំងពី<ប៉ុន្មាន>ខែមុន<នោះ> ម៉េចក៏ព្រះរាជអាជ្ញាមិនព្រម<ស្នើសុំ>វិធាន<៨៧(៤) នេះតាំងពីពេលនោះ>ទៅ <បើសិនជាវាចាំបាច់ពិតមែន។ នេះជាការអង្កេតទី១ របស់ខ្ញុំ។>

ហើយចំណុចទី២ ខ្ញុំសូមរំឭកថា នៅពេលដែលយើងជំទាស់<ម្តងហើយម្តងទៀត>ទៅនឹងការប្រើប្រាស់ឯកសារទាំងអស់នេះ <ឬក៏>នៅពេលដែលយើង<ស្នើ>សុំពេលវេលាបន្ថែមកាលនោះ<> ដើម្បីពិនិត្យលើឯកសារទាំងអស់នេះ អង្គជំនុំជម្រះបានបញ្ជាក់ថា <វាធ្វើឲ្យមានភាពខុសគ្នា>រវាងចម្លើយដែលបាន<លាតត្រដាងឲ្យដឹងជា>ធម្មតា<> ហើយនិងឯកសារដាក់សុំធ្វើជាភស្តុតាង។ <ដូច្នេះថ្ងៃនេះ យើងមិនគួរបង្ហាញការពិតដែលថា ឯកសារសំខាន់ៗមួយចំនួនត្រូវបានបញ្ចេញឲ្យដឹងកាលពីប៉ុន្មានខែមុន ស្របពេលដែលមានការបែងចែកភាពខុសគ្នាយ៉ាងច្បាស់រវាងឯកសារ ដែលបានដាក់បង្ហាញនៅក្នុងសឺមីជាច្រើន> ហើយ<និង>ឯកសារ<ពួកគេស្នើសុំឲ្យដាក់ចូលជាភស្តុតាង>។

[០៩:១៦:០៥]

ចំណុចទី៣ ខ្ញុំ<សូមឲ្យសហ>ព្រះរាជអាជ្ញាបានផ្តល់លេខយោង<នៃឯកសារទាំងនោះ>ឲ្យយើង<ផង ពីព្រោះ>ថា<នេះមិនមែនជាលើកទី១ទេដែលខ្ញុំឮសហព្រះរាជអាជ្ញានិយាយថា យើង>ប្រើឯកសារទាំងអស់<នេះជាច្រើនដងមកហើយដែលបានមកពី>សំណុំរឿង០០៣, ០០៤ <ដើម្បីសាកសួរ>នៅក្នុងសវនាការនេះ។ ខ្ញុំសូមរំឭកថា គោលជំហរ<របស់ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន គឺមានភាព>ច្បាស់<លាស់>ណាស់<។> នៅពេលដែល<និយាយអំពីចម្លើយមុនៗរបស់សាក្សី គឺថាវាសំដៅទៅដល់>សាក្សី<ដែលបានកំណត់ថ្ងៃដើម្បី>មកផ្តល់សក្ខីកម្មនៅមុខអង្គជំនុំជម្រះនេះ <>នៅ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ពេលដែល<ពាក់ព័ន្ធដល់>ចម្លើយ<>មុនៗរបស់<សាក្សីដែលមកផ្តល់សក្ខីកម្មនៅមុខអង្គជំនុំជម្រះនេះគឺថា>មិនមាន<ការជំទាស់>អ្វីទេ<ចំពោះការដាក់ចម្លើយទាំងអស់នេះធ្វើជាភស្តុតាងនោះ> ព្រោះថា <>នេះ<ជាផ្នែកមួយនៃការ>សួរដេញដោល<ពី>ភាព<អាចឲ្យ>ជឿ<បានរបស់សាក្សី>។ <ដូច្នេះវាមិនមានបញ្ហាជាមួយសាក្សីទេ ដោយការផ្តល់សក្ខីកម្មនៅមុខអង្គជំនុំជម្រះនោះ។> ក៏ប៉ុន្តែ<ពាក់ព័ន្ធនឹងសាក្សីផ្សេងៗទៀតដែលមិនបានមកផ្តល់សក្ខីកម្ម ហើយ>សាក្សី<ទាំងនោះ>នៅរស់ ហើយ<មិនត្រូវបាន>កោះហៅ<ឲ្យ>មកផ្តល់សក្ខីកម្មនៅទីនេះ <គឺថាយើងដែលជាក្រុមមេធាវីការពារក្តីលោក ខៀវ សំផន សូម>ជំទាស់<យ៉ាងពិតប្រាកដដោយផ្អែកលើមូលដ្ឋាននៃប្រព័ន្ធក្នុងការប្រើប្រាស់ឯកសារដែលពាក់ព័ន្ធទាំងអស់នេះ។ ដូច្នេះទាំងអស់>នេះ<>ជា<ការបំភ្លឺរបស់>ខ្ញុំ<ដើម្បី>ឆ្លើយតបទៅ<នឹង>ការកត់សម្គាល់របស់ព្រះរាជអាជ្ញាអម្បាញ់មិញ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយអង្គជំនុំជម្រះក៏សុំជម្រាបជូនភាគីពាក់ព័ន្ធជ្រាបផងដែរថា សំណើសុំរបស់សហមេធាវីការពារក្តី ខៀវ សំផន ឯកសារ E363 នោះ អង្គជំនុំជម្រះបាននិងកំពុងតែពិចារណាហើយបានពិភាក្សាចំនួនពីរដងរួចមកហើយលើបញ្ហានោះ ហើយអង្គជំនុំជម្រះសង្ឃឹម និងជឿជាក់លើខ្លួនឯងថា នឹងអាចចេញសម្រេចលើ ឆ្លើយតបទៅលើសំណើសុំមកនេះក្នុងរយៈពេលខ្លីឆាប់ៗខាងមុខនេះដើម្បីដោះស្រាយបញ្ហាទាំងឡាយដែលកំពុងតែប្រឈមបច្ចុប្បន្ននេះឲ្យបានច្បាស់លាស់ ហើយនិងជ្រះស្រឡះ ដើម្បីរួមចំណែកយ៉ាងសកម្មនៅក្នុងការ កិច្ចប្រឹងប្រែងដើម្បីធ្វើឲ្យកិច្ចដំណើរការសវនាការតទៅមុខនេះមានប្រសិទ្ធភាព។

បាទ ហើយបញ្ហានេះអង្គជំនុំជម្រះនឹងពិនិត្យពិចារណាលើសំណើនេះឆាប់ៗ នឹងជម្រាបជូនភាគី។ បាទ តទៅទៀតហ្នឹង អង្គជំនុំជម្រះចាប់ផ្តើមស្តាប់បន្តស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ហ៊ឹម ម៉ាន។ មន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណី ហ៊ឹម ម៉ាន ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

[០៩:១៨:៤២]

**កញ្ញា អង់តា ហ្គីសសេ៖**

<សូមអភ័យទោស> លោកប្រធាន ខ្ញុំសុំ<ការ>បំភ្លឺមួយ។ <ដូច្នេះ> តើខ្ញុំ<អាចដឹងឲ្យច្បាស់បានទេ> ថាអង្គជំនុំជម្រះ<នឹង>ចេញសេចក្តីសម្រេចលើសំណើ<សុំពេលវេលា>របស់ខ្ញុំនៅពេល

ក្រោយ<>? ខ្ញុំសុំការបំភ្លឺឲ្យច្បាស់ត្រង់ចំណុចនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អ៊ីចឹងហើយ ព្រោះឥឡូវហ្នឹងអត់ទាន់សម្រេចទេ ហើយអង្គជំនុំជម្រះក៏កំពុងតែពិនិត្យ និងពិចារណាលើសំណើសុំរបស់មេធាវី ឯកសារ E363 ដែលបានដាក់នោះរួចហើយ ប៉ុន្តែកំពុងតែធ្វើការរៀបចំនូវសេចក្ដីសម្រេចមួយលើបញ្ហានេះដើម្បីដោះស្រាយឲ្យបានជ្រះស្រឡះ។ អ៊ីចឹងបញ្ហានេះ វាផ្ទួនគ្នាដោយសារដោះស្រាយបញ្ហានោះផង ហើយនិងដោះស្រាយបញ្ហាថ្មីលើសំណើថ្មី ដាក់កំណត់ហេតុឯកសារ ២៥ របស់សហព្រះរាជអាជ្ញាផង។ អ៊ីចឹងបញ្ហានេះ អង្គជំនុំជម្រះនឹងពិចារណាសម្រេចឆាប់ៗនេះដើម្បីដោះស្រាយបញ្ហានេះឲ្យបានល្អប្រសើរ។ បើសិនជាដោះស្រាយរួមតែម្ដង ទាំងពីរតែម្ដងគឺវាជាការល្អប្រសើររបស់យើងទាំងអស់គ្នា ហើយក៏ល្អសម្រាប់អង្គជំនុំជម្រះផងដែរ ពីព្រោះអង្គជំនុំជម្រះក៏ជ្រះស្រឡះលើបញ្ហានេះដែរ ប៉ុន្តែដោយសារបញ្ហាវាថ្មី ហើយបញ្ហាវាមានចរិតស្មុគស្មាញ។ អ៊ីចឹងយើងប្រជុំពីរបីដងហើយ ដើម្បីរកវិធីដោះស្រាយបញ្ហានេះឲ្យបានល្អប្រសើរនោះ។

អ៊ីចឹង យើងជឿថាលទ្ធផលដែលអង្គជំនុំជម្រះនឹងផ្ដល់ទៅបានល្អ ហើយនិងបានឆាប់ទេ មិនមែនជាយូរបានទេ ព្រោះបញ្ហាវានៅចំពោះមុខយើងនេះហើយ។

[០៩:២០:០៨]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:២១:៣៩]

**ប្រធានអង្គជំនុំ៖**

សួស្ដីលោក ហ៊ឹម ម៉ាន។ បានត្រៀមខ្លួនហើយនៅ? ហើយជាបន្តទៅនេះ អង្គជំនុំជម្រះ ផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្ដី ដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សីរូបនេះ។ ហើយដំបូងនេះ ផ្ដល់វេទិកាជូនទៅសហមេធាវីការពារក្ដីលោក នួន ជា ដើម្បីមានឱកាសសួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ឹម ម៉ាន។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម សហការីទាំងអស់។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ខ្ញុំមានសំណួរមួយចំនួនសួរទៅលោក នៅព្រឹកនេះ សួរបន្តពីសក្ខីកម្មរបស់លោកកាលពីពីរសប្តាហ៍មុន។ ដំបូងអនុញ្ញាតឲ្យខ្ញុំសួរលោកពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍នៅក្នុងឆ្នាំ១៩៧៥ មិនមែននៅក្នុងភូមិរបស់លោកទេ ប៉ុន្តែទៅភូមិមួយទៀត<ដែលនៅខាងក្រោមទន្លេបន្តិច> គឺភូមិកោះផល។ លោកត្រូវបានសួរ<អំពីរឿងនេះ លោកបាន>ឆ្លើយសង្ខេបអំពីការបះបោរនៅកោះផល។ លោកក៏និយាយអំពីការបះបោរនេះប្រាប់លោក អ៊ីសា ឧស្មាន <ដែរ។> គាត់បានដកស្រង់<សម្តីរបស់លោក>សរសេរនៅក្នុងសៀវភៅរបស់គាត់ គឺ E3/9336, ERN ជាភាសាអង់គ្លេស 00218503, បារាំង 00286655 និងខ្មែរ 00218496។ លោកសាក្សី លោកបាននិយាយថា ការបះបោរក៏ត្រូវបានគេគឺបាញ់កម្ទេចដោយសារការប្រើប្រាស់កាំភ្លើងធំ<> ហើយនិងក្រុមម៉ារីន។ លោកចាំទេ អ្នកណាប្រាប់លោកអំពីរឿងរ៉ាវនេះ?

[០៩:២៤:០៥]

**លោក ហ៊ឹម ម៉ាន៖**

**ឆ៖** បាទ ខ្ញុំឮ ខ្ញុំនៅក្នុងភូមិ ខ្ញុំឮ ព្រោះខ្ញុំឮគេប្រាប់ គេនិយាយ ព្រោះខ្ញុំនៅលើកដីទេ គេនិយាយសុះសាយ បាទ។ ហើយមួយទៅមួយៗ អ្នកភូមិទេនិយាយហ្នឹង។ បាទ និយាយសុះសាយទៅណា ខ្ញុំស្តាប់បាន។ បាទ ប៉ុណ្ណឹង។

**ស៖** លោកចាំទេ អ្នកណាប្រាប់លោក<អំពី>ការប្រើប្រាស់កាំភ្លើងធំ <>និងកងម៉ារីន ដើម្បីមក "កម្ទេចភូមិនោះចោលតែម្តង" <>?

**ឆ៖** បាទ កាលនុ៎ង ឮអ្នកភូមិថាដែរ ថាជំនាន់ខ្មែរក្រហមហ្នឹងណា បាទ ហើយខ្ញុំនៅរវល់

ធ្វើការខ្ញុំ ខ្ញុំឮ ហើយខ្ញុំឮមិនបានមើលមុខគេហ្នឹងចំផងកាលនុ៎ង នៅរវល់នៅធ្វើការហ្នឹង ដើម្បីថាយកគុណសម្បត្តិដើម្បីយកអាយុវែង។ ឲ្យគេឃើញថា អូ៎! អ្នកនេះខំធ្វើការណាស់បានអាយុវែង គេទុកអាយុឲ្យទៅ ម្ល៉ោះហើយគ្រាន់តែស្តាប់ឮបាទ ស្តាប់ឮ។

**ស៖** <ហេតុការណ៍ទាំងអស់>នេះ គឺកើតឡើងនៅតំបន់២១ ភូមិភាគបូព៌ា។ នៅពេលដែលគេនិយាយ<ជាមួយលោក>អំពី<ការបំបែកការ>បះបោរហ្នឹង តើគេមាននិយាយថាកម្លាំងមកពីខាងណាដែរ ដែលមកកម្ទេចភូមិហ្នឹងតែម្តង? តើកម្លាំងស្រុក ឬក៏ជាកម្លាំងរបស់ភូមិភាគ <>ឬក៏កម្លាំងរបស់តំបន់?

**ឆ៖** ឮជំនាន់ហ្នឹងឮថា ខ្មែរក្រហមៗហ្នឹង មិនដឹងលោកណាអីណាខ្ញុំមិនដឹងទេ ឮថាខ្មែរៗ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ជំនាន់ខ្មែរក្រហមហ្នឹង ព្រោះខ្ញុំនៅរវល់តែធ្វើការហ្នឹង មិនចង់ គ្រាន់តែស្តាប់ទៅ ឮទៅ មិនចង់ក្រឡេកមើលមុខគេទេ។ បាទ ប៉ុណ្ណឹង។

[០៩:២៦:៤៣]

**ស៖** បាទ មិនថ្វីទេលោកសាក្សី លោកក៏បានឆ្លើយទៅនឹងសំណួរមួយចំនួន<កាលពី>ពីរសប្តាហ៍មុននេះ និយាយអំពីពាក្យចចាមអារាម សូមដកស្រង់៖ "ខ្មែរក្រហមចាត់ទុកចាមថាជាខ្មាំងលេខមួយជាសត្រូវលេខមួយ" បញ្ចប់ការដកស្រង់។ តើនេះ<ពិត>ជាពាក្យចចាមអារ៉ាម<មែនឬ> ដែលអ្នកភូមិនិយាយតៗគ្នា ឬក៏<មានអ្វីច្រើនជាងហ្នឹងទៀត>?

**ឆ៖** បាទ អ្នកភូមិនិយាយដែរៗ បាទឮតែគេនិយាយ ហើយខ្ញុំកំពុងតែធ្វើការដដែល ការងារខ្ញុំកម្លាំងពលកម្មខ្ញុំដែលជីកដីជីកអីហ្នឹង ស្តាប់ឮអីចឹងដែរ។ រួចក្រោយមកហ្នឹង ឮអីចឹងរួចហើយ ក្រោយមកវាតឹងរឿងៗជនជាតិចាមហ្នឹង ខ្មែរអ៊ីស្លាមហ្នឹង។ គ្រាន់តែឮគេនិយាយប៉ុណ្ណឹងទេ មិនបានទៅមើលមុខគេថាអ្នកណាៗៗ អត់ដឹង។ មិនហ៊ានមើលមុខគេទេកាលនុំង គិតតែការងាររបស់ខ្ញុំ។

**ស៖** លោកសាក្សី កាលដែលខ្ញុំសួរសំណួរនេះដោយសារក្នុងសៀវភៅដែលរបស់ អ៊ីសា ឧស្មាន <ដែលខ្ញុំយកធ្វើជាឯកសារយោងនោះ> គេថាលោកត្រូវបានដកស្រង់សម្តីដែលលោកបាននិយាយថា ចាម គឺជាខ្មាំងលេខមួយនេះ ត្រូវបានប្រកាសនៅក្នុងភូមិ<ទាំង>នោះតែម្តង។ ឥឡូវនេះខ្ញុំចង់ដឹង តើនេះគឺគ្រាន់តែជាពាក្យដែលអ្នកភូមិនិយាយតៗគ្នាត្រឹមត្រូវដែរឬទេ មិនមែនជាការប្រកាសទេ តែជាពាក្យដែលអ្នកភូមិនិយាយតៗគ្នា អីចឹងមែនទេ?

**ឆ៖** និយាយ--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតបដើមបណ្តឹងរដ្ឋប្បវេណី។

សូមអញ្ជើញមេធាវីជាតិ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន ខ្ញុំមិនជំទាស់ទេ ប៉ុន្តែគ្រាន់តែចង់សូមឲ្យមេធាវីអន្តរជាតិរបស់លោក នួន ជា ផ្តល់លេខឯកសារ ហើយនិង ERN ផង ដើម្បីអាចផ្ទៀងផ្ទាត់បាន។ សូមអរគុណលោកប្រធាន។

**លោក វ៉ិចទ័រ កូប៉េ៖**

មិនជាអ្វីទេលោកសហមេធាវីនាំមុខ ដូចខ្ញុំនិយាយ<មុននេះ វានៅក្នុង>សម្រង់ដដែល គឺទំព័រជាភាសាអង់គ្លេសគឺទំព័រ ១៥៣ <នៅខាងក្រោមបង្អស់។> ERN ជាភាសាអង់គ្លេស 00218503, បារាំង 00286655, និងខ្មែរ 00218496។ ខ្ញុំសូមដកស្រង់៖ “<នៅឆ្នាំ៧៤ ពួកគេមានសម្ពាធ>--

[០៩:៣០:០០]

**ប្រធានអង្គជំនុំ៖**

លោក វ៉ិចទ័រ កូប៉េ ផ្អាកបន្តិចសិន មានបញ្ហាបកប្រែភាសាបារាំង ថាអត់ឮសំឡេងទេ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងខាងបច្ចេកទេសខាងប្រព័ន្ធសំឡេង មានបញ្ហាអីទៅ? បង្អង់បន្តិចបាទ ព្រោះមានបញ្ហាបកប្រែភាសា។

បាទ សូមអញ្ជើញត លោក វ៉ិចទ័រ កូប៉េ សូមបញ្ជាក់លេខ ERN សាជាថ្មីឡើងវិញ ព្រោះអំមិញអ្នកបកប្រែភាសាបារាំង អត់បានស្ដាប់ឮទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទ លោកប្រធាន ដូចខ្ញុំបានប្រាប់ហើយ គឺសៀវភៅរបស់ អ៊ីសា ឧស្មាន E3/9336 នៅផ្នែកខាងក្រោមនៃទំព័រ១៥៣, ERN ជាភាសាអង់គ្លេស 00218502, ខ្មែរ 00218496 ហើយនិងភាសាបារាំង 00286655 ដកស្រង់៖ “ដល់ឆ្នាំ១៩៧៤ ខ្មែរក្រហមគាបសង្កត់យើងកាន់តែខ្លាំងឡើងៗ”។ ខ្មែរក្រហមបានប្រកាសថា <>ចាមជាខ្មាំងទី១ ហើយខ្មែរគឺជាខ្មាំងទី២”។ ដូច្នេះ <លោកដើមបណ្ដឹងរដ្ឋប្បវេណី> ខ្ញុំ<សូមសួរលោកម្ដងទៀត> តើត្រឹមត្រូវដែរឬទេដែលថា គឺជាពាក្យដែលអ្នកភូមិនិយាយតៗគ្នា ឬក៏ថាវាជាការប្រកាសជាសាធារណៈតែម្ដង<? តើ>ក្នុងចំណោមពីរហ្នឹង តើមួយណា?

[០៩:៣១:៥៥]

**លោក ហ៊ីម ម៉ាន៖**

**ឆ៖** រឿងចាម ខ្មាំងទី១ហ្នឹង កាលនុំង មានប្រធានភូមិហ្នឹងចាមដែរ។ គេហៅប្រធាន តាំៗហ្នឹង បាទ។ ដំណឹងហ្នឹង វាមានប្រជុំកាលហ្នឹង ខ្ញុំមិនទៅប្រជុំទេ បើខ្ញុំនៅជីកដីដដែលនៅការងារហ្នឹង ប៉ុន្តែខ្ញុំនៅក្នុងភូមិហ្នឹង ពាសវាលឯង ខ្ញុំដឹងខ្លះៗ កាលហ្នឹងប្រធានភូមិ តាំ ហ្នឹង គេប្រកាសអីចេះចុះៗទៅ រឿងខ្មាំងចាម ខ្មាំងទី១។ អីចឹង វាធ្ងន់ធ្ងរនៅកោះផលហ្នឹងរួច បានជាដាក់ថាខ្មាំងចាម ខ្មាំងទី១ហ្នឹង។ បាទ អីចឹងខ្ញុំឮប៉ុណ្ណឹង។ រឿងអីបានខ្ញុំឮ កោះផលហ្នឹងថា ប្រយ័ត្នដូចនៅកោះផល គេហៅថា កោះផេះហ្នឹង វាខ្លាចបះបោរកន្លែងហ្នឹង បះបោរកន្លែងហ្នឹងរួច វាមានឈ្មោះនៅក្នុងហ្នឹងរួច បានជាគេប្រយ័ត្ននឹងចាម

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ជនជាតិទាំងអស់ហ្នឹង។ គេដាក់ជាខ្មាំងចាម ខ្មាំងទី១។ ខ្ញុំមិនដឹងរឿងរ៉ាវរបស់គេដែរ។ បាទ ប៉ុណ្ណឹង។

**ស៖** ឧទាហរណ៍ថា<ព័ត៌មានទាក់ទងនឹងពាក្យចចាមអារ៉ាម>របស់លោកត្រឹមត្រូវទៅចុះ។ ប៉ុន្តែតើហេតុអ្វីបានជា<ធាំ*(ស៊ឹក)* ដែលខ្លួនគាត់ផ្ទាល់ជាជនជាតិចាមដែរនោះ បែរជា>និយាយថា ចាមនេះ គឺជាខ្មាំងទី១<ទៅវិញ>?

**ឆ៖** ខ្ញុំនៅឆ្ងល់ដែរ ហេតុអ្វីបានជាគេដាក់ខ្មាំងចាមនេះ ខ្មាំងទី១នេះ។ ខ្ញុំនៅឆ្ងល់ទាល់សព្វថ្ងៃនេះ បាទ ខ្ញុំមិនដឹងរឿងរ៉ាវអាថ៌កំបាំងរបស់គេទេ។ ដាក់ខ្មាំងចាម ខ្មាំងទី១។ រួចនឹកឃើញរូបភាពហ្នឹង ក្រោយពីហ្នឹងមក ឃើញចាមយ៉ាប់យ៉ឺន គេយទៅសម្លាប់ បាទ ហើយដោយទាំងខ្ញុំទៅទៀត។

[០៩:៣៤:១៣]

**ស៖** លោកសាក្សី ខ្ញុំនឹងត្រឡប់មកនិយាយអំពីចំណុចនេះនៅពេលក្រោយ។ លោកក៏បានឆ្លើយផងដែរថា លោក<និងជនជាតិចាមផ្សេងទៀត> ត្រូវបានគេបង្ខំឲ្យហូបសាច់ជ្រូក។ លោកថា គេបង្ខំហ្នឹង គឺនៅក្នុងឆ្នាំ៧៥-៧៦។ តើលោកអាចជម្រាបជូនតុលាការបានទេ ការបង្ខំឲ្យហូបសាច់ជ្រូកហ្នឹង<កើត>ឡើង<យ៉ាងដូចម្ដេច>? ហើយថាតើបងប្អូនចាមនេះ ត្រូវបានគេបង្ខំឲ្យហូបសាច់ជ្រូក<ដែលប្រឆាំងនឹងឆន្ទៈរបស់ចាម>ដោយរបៀបណា? តើ<>សាច់ជ្រូក<មានគ្រប់គ្រាន់មែនទេ ទើបបានជា>ត្រូវបង្ខំឲ្យបងប្អូនចាមហូប ឬក៏ថានៅតាមទន្លេមេគង្គ <មិន>មានត្រី<គ្រប់គ្រាន់ ដើម្បី>ឲ្យចាមហូប<ទេ>? <តើលោកអាចពន្យល់បន្តិចបានទេ ថាតើវាកើតឡើងយ៉ាងដូចម្ដេច?>

**ឆ៖** គេកាលហ្នឹងគេបង្ខំឲ្យហូបសាច់ជ្រូក គេបំបាត់សាសនា គេឲ្យចាមកុំឲ្យថ្វាយបង្គំ គេឲ្យ -- គេមិនឲ្យចាមខាងមហាម៉ាត់នេះហូបសាច់ជ្រូក គេមិនឲ្យថ្វាយបង្គំ គេមិនឲ្យ -- គេឲ្យកាត់សក់ កាត់សក់ទៅជាខ្មែរតែមួយ បាទ មិនឲ្យសាសនាណាទៀតទេ គឺថាមានខ្មែរតែមួយ ជាតិតែមួយ។ កាត់សក់ កាត់អីទាំងអស់ មិនឲ្យថ្វាយបង្គំបាទ ប៉ុណ្ណឹង ខ្ញុំដឹងប៉ុណ្ណឹង។ ហើយក្រោយមកយ៉ាប់យ៉ឺនទៅទៀតហ្នឹង បន្ត។មក ហើយមិនបាច់អ្នកយាមទេ កន្លែងរោងបាយអីនោះ កាលហ្នឹងប្រជាពលរដ្ឋកាលហ្នឹងដណ្ដើមយកគុណសម្បត្តិ មិនបាច់ថាពួកខ្មែរក្រហមមកយាមតាមអាណាហូបទេ យកទៅបាញ់ចោល មិនបាច់ទេ អ្នកភូមិ អ្នក។ហូបបាយហ្នឹងគេហៅទៅរាយការណ៍បន្តហ្នឹង បាទ។ យូរ។តែអ៊ីចឹងទៅស្ងាត់។ទៅ យកមួយគ្រួសារទៅ ស្ងាត់។យកមួយគ្រួសារទៅ វាមានអនុនៅក្នុងហ្នឹងដើម្បីយកគុណសម្បត្តិ ដើម្បីរស់ ថារាយការណ៍ច្រើន អ្នកហ្នឹងស្មោះសរ អ្នកហ្នឹងស្មោះត្រង់បានអាយុវែង ហ្នឹងខំរាយការណ៍ទៅ ប៉ុន្តែខ្ញុំក៏នៅសង្ស័យ យូរ។បាត់មួយ យូរ។បាត់មួយគ្រួសារ។អ៊ីចឹងទៅ មិនដឹងជារឿងហេតុផលអី បាទ

ប៉ុណ្ណឹងដែលគេបំបាត់ហ្នឹង។

**ស៖** បាទ សូមអរគុណចំពោះចម្លើយដ៏វែងរបស់លោក ប៉ុន្តែខ្ញុំចង់ផ្តោតទៅលើចំណុច<ជាក់លាក់>មួយ<។>លោកថា<> ប្រធានភូមិ<នោះ ក៏>ជា<ជនជាតិ>ចាមដែរ<។> ភូមិរបស់លោក គឺ<>នៅតាមដងទន្លេមេគង្គ<តែម្តង ដែល>សំបូរទៅដោយត្រី សាច់ <ដូចដែលយើងដឹងស្រាប់ហើយ។ ហើយ>មានភស្តុតាងជាច្រើនបង្ហាញថាមិនមានការ<>ហូប<ចុកគ្រប់គ្រាន់>ទេ<។ ដូច្នេះ> តើ<>លោក<អាចផ្តល់ឧទាហរណ៍ឲ្យខ្ញុំមួយបានទេ តើនៅពេលណាដែល>លោក<>បានឃើញដោយផ្ទាល់ថា ជនជាតិចាមត្រូវបានគេបង្ខំឲ្យហូបសាច់ជ្រូក<ដែលផ្ទុយពីឆន្ទៈ>របស់គាត់<នោះ>? <តើវាកើតឡើងនៅពេលណា? តើលោកនៅឯណាពេលនោះ?> តើលោកអាចផ្តល់ឧទាហរណ៍ណាមួយជាក់ស្តែងដែលលោកបានឃើញដោយផ្ទាល់ទេ?

[០៩:៣៨:០៩]

**ឆ៖** អើបើៗខ្ញុំអីនៅទីហ្នឹងហើយ អត់ហ៊ាននេះអីចឹង នៅហូបសាច់ជ្រូកដោយៗទឹកភ្នែកបាទ ហូបបើមិនហូបទេហ្នឹង ក្រែងលោវាត្រូវគ្រាប់កាំភ្លើង ក្រែងលោកវាត្រូវព្រនង់ ហូបដោយទឹកភ្នែក ខ្លួនខ្ញុំផ្ទាល់ហើយដែលនៅជាមួយដែលពេលហូបបាយហ្នឹង បាទកន្លែងហ្នឹងហើយ ដែលខ្ញុំផ្ទាល់ហ្នឹងតែម្តង ហើយខ្ញុំបងប្អូនខ្ញុំ ក៏ដូចខ្ញុំដែរ បើមិនហូបទេ គឺជីវិតអត់ធានាបានទេ មិនដឹងម៉ោងៗណាទេ អីចឹងត្រូវតែហូប។ រួចសម្បូរត្រីហ្នឹងវាសម្បូរមែន ក៏ប៉ុន្តែគេបង្ខំឲ្យហូបសាច់ជ្រូក ហើយថាខ្មែរតែមួយប៉ុណ្ណឹង។

**ស៖** <តើ>ខ្ញុំយល់<ត្រឹមត្រូវ>ទេ<ដែល>ថាលោកមិនធ្លាប់បានឃើញអ្នកណាម្នាក់<ត្រូវបានគេ>បង្ខំឲ្យហូបសាច់ជ្រូកដោយផ្ទាល់នោះទេ <ប៉ុន្តែ>នេះគ្រាន់តែជាការភ័យខ្លាចទូទៅទេ <គឺ>ថា បើមិនព្រមហូបសាច់ជ្រូកទេ ជាការប្រឆាំងទៅនឹង<>ការបញ្ជារបស់គេ<?> តើ<អ្វីដែលខ្ញុំយល់ពីសក្ខីកម្មរបស់លោក>ត្រឹមត្រូវដែរ ឬក៏យ៉ាងណា?

**ឆ៖** អារឿងហ្នឹង ខ្ញុំក៏ឯកភាពដែរអីចឹងនោះបាទ ពីព្រោះថាមិនបានអ្នកណាម្នាក់មកនេះទេ ប៉ុន្តែគ្រាន់ថាគេប្រកាសថ្ងៃមុនហ្នឹង គេថាអ្នកឯងមិនហូប គឺអ្នកឯងប្រឆាំង អ្នកប្រឆាំងតែម្តង បាទអ្នកប្រឆាំង។ អីចឹងម្នាក់ៗ គឺខំហូបដោយទឹកភ្នែកបាទ ទ្រាំហូបដើម្បីជីវិត។

**ស៖** ខ្ញុំនៅមានសំណួរមួយចំនួន<ដើម្បី>សួរទៅលើ<ប្រធានបទ>នេះនៅឡើយទេ ក៏ប៉ុន្តែខ្ញុំសូមបន្តទៅមុខសិន<ដោយសារតែពេលវេលា>។ ឥឡូវនេះខ្ញុំនិយាយពីឆ្នាំ១៩៧៧ ជាពិសេសដែលលោកនិយាយថា ជា<ខែចន្ទគតិទីពីរ នៅពេលដែលលោករៀបការនឹងស្ត្រីជនជាតិចាមមួយរូបទៀត

ដែលជាប្រពន្ធលោកបច្ចុប្បន្ន។ ដើម្បីជាការបញ្ជាក់ឲ្យច្បាស់ ខែចន្ទគតិទី២ នៅឆ្នាំ៧៧នោះ តើវានៅក្នុងខែកុម្ភៈ ឆ្នាំ៧៧ មែនទេ?>

<**លោក វ៉ិចទ័រ កូប៉េ៖**>

<លោកប្រធាន ខ្ញុំបានឮថាមិនមានការបកប្រែជាភាសាខ្មែរទេ?>

**ប្រធានអង្គជំនុំ៖**

មើលមានបញ្ហា!

*(មានបញ្ហាបច្ចេកទេស)*

[០៩:៤១:៣៩]

**ប្រធានអង្គជំនុំ៖**

អញ្ជើញតទៀតលោកមេធាវី វ៉ិចទ័រ កូប៉េ មានបញ្ហាបន្តិចបន្តួចប៉ុណ្ណោះ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងសួរសំណួរឡើងវិញ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សំណួររបស់ខ្ញុំសួរអំពីការរៀបការរបស់លោក គឺជាមួយប្រពន្ធលោកសព្វថ្ងៃនេះដែលជាស្ត្រីជនជាតិចាមផងដែរ។ លោកបានឆ្លើយថា លោករៀបការនៅ<>ខែ<ចន្ទគតិទី២ នៅ>ឆ្នាំ១៩៧៧។ តើវាជាខែកុម្ភៈ ១៩៧៧ ឬក៏ចំពេលណា?

**លោក ហ៊ីម ម៉ាន៖**

**ឆ៖** ខ្ញុំឆ្លើយទាំង រៀបការហ្នឹងតាំងពីយូរមកហើយ។ រួចហើយខ្ញុំសព្វថ្ងៃនេះ ខ្ញុំវាចាស់ហើយ ខ្ញុំភ្លេចភ្លាំងអស់ហើយៗ ប៉ុន្តែដឹងថាការជំនាន់ប៉ុល ពត ការហើយ។

**ស៖** តើអ៊ីចឹងត្រឹមត្រូវទេ ដែលថាលោករៀបការជាមួយប្រពន្ធលោកសព្វថ្ងៃហ្នឹងគឺលោករៀប-ការរួមគ្នាជាមួយនឹងគូស្រករ៥០គូទៀតនៅឯវត្តអូរត្រកួន។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ រៀបការមែន។ មិនមែនតែខ្ញុំទេ រៀបការច្រើនណាស់បាទ ប្រហែលជាប៉ុន្មាននុំងហើយ ៥០គូហ្នឹងហើយ ព្រោះខ្ញុំទៅរៀបការកន្លែងហ្នឹងដែរ គេយកខ្ញុំទៅរៀបការកន្លែងនុ៎ង។ រួចសុទ្ធ ហូប សុទ្ធតែសាច់ជ្រូក។

**ស៖** ខ្ញុំនឹងត្រឡប់មកចូលចំណុចនោះវិញ។ លោកសាក្សី លោកនៅចាំទេថា មានជនជាតិចាម

ដែរទេក្នុងចំណោមគូស្រករដែលគេរៀបការឲ្យនៅឯវត្តអូរត្រកួនហ្នឹង?

**ឆ៖** មានខ្ញុំ មានក្រៅពីខ្ញុំដែរ ប៉ុន្តែខ្ញុំភ្លេចឈ្មោះអស់ទៅបាទ។

**ស៖** ខ្ញុំយល់ហើយ ក៏ប៉ុន្តែក្នុងចំណោមគូស្រករទាំង៥០គូនេះ តើមានជនជាតិចាមដែរទេ?

**ឆ៖** មានៗ ទាំងខ្ញុំជនជាតិចាម មានតាំងបងប្អូនខ្ញុំសាច់លោហិតហ្នឹងហើយ មានតាំងពីបងប្អូនខ្មែរដែរ។

[០៩:៤៥:០០]

**ស៖** ហើយលោកចាំទេ តើក្នុងចំណោម៥០គូនេះ ប៉ុន្មានគូជាជនជាតិខ្មែរ? ប៉ុន្មានគូជាជនជាតិចាម?

**ឆ៖** ខ្ញុំមិនបានចាំទេ។ មិនបានលម្អិតទេទាល់សព្វថ្ងៃហ្នឹង បាទ គ្រាន់តែចាំត្រង់ថា វគ្គៗហ្នឹង។ បាទ អត់មានថាប៉ុន្មានគូៗ ខ្ញុំមិនដឹងទេ។ មិនបានលម្អិតទេ ប៉ុន្តែគ្រាន់តែប្រហែល៥០គូហ្នឹង គឺប្រហែលទេ ប៉ុន្តែមនុស្សឃើញវាច្រើនដែរ។

**ស៖** តើលោកចាំទេថាស្ត្រីចាមគេឲ្យរៀបការជាមួយបុរសចាម ស្ត្រីខ្មែររៀបការជាមួយបុរសខ្មែរ។ តើវាអ៊ីចឹង ឬក៏អត់ទេ? ហើយលោកនឹកឃើញទេ?

**ឆ៖** គេឲ្យចូលខ្មែរតែមួយបាទ។ រួចដល់តែអ៊ីចឹងទៅ ខ្ញុំហ្នឹង មិនដឹងគេយល់យ៉ាងម៉េច បានជាគេចាត់តាំងខ្ញុំចំប្រពន្ធរបស់ខ្ញុំ គួដណ្ដឹងចាស់។ បាទ វាបានថា បានតែខ្ញុំហ្នឹង។ អូ៎! មានម្នាក់ទៀតដែរចំខ្មែរ គូដណ្ដឹងចាស់ដែរ។ វាហេងស៊យក៏មិនដឹង អីក៏មិនដឹង ចំគូដណ្ដឹងចាស់។

**ស៖** នៅពេលលោករៀបការជាមួយនឹងគូស្រករ ៥០គូទៀតនោះ<> តើ<>នៅក្នុងបរិវេណវត្តអូរត្រកួនតែម្ដងឬ? ហើយបើសិន<អ៊ីចឹងមែន> តើលោកជម្រាបតុលាការ<បានទេ ថាលោក>នៅត្រង់កន្លែងណា<ឲ្យប្រាកដ>?

**ឆ៖** រៀបការនៅបរិវេណវត្តអូរត្រកួនហ្នឹងហើយ នៅទិសខាងលិច ខាងក្រោយវត្ត នៅក្បែរវត្តហ្នឹង ប៉ុន្តែខាងក្រោយ មិនមែនខាងមុខទេ។

**ស៖** តើនៅពេលដែលលោករៀបការហ្នឹង គេឲ្យលោក ថាតើពេលលោកចូលទៅលោកដើរក្រឡឹងជុំវិញបរិវេណវត្តហ្នឹងគឺថា ឬក៏ដើរកាត់តម្រង់ត្រង់ទៅដល់កន្លែងការហ្នឹងតែម្ដង?

**ឆ៖** បាទ ខ្ញុំបាទទៅតម្រង់កន្លែងការតុហ្នឹងតែម្ដង តុដែលខ្ញុំអង្គុយហ្នឹង អត់មានដើរទៅណាខ្វេរខ្វល់តាមណាទេ ព្រោះចេះតែខ្លាច បាទ ខ្លាច ចេះតែប្រយ័ត្នជាប់អ៊ីចឹង។ ដើរទៅនេះ ទៅនោះហ្នឹង

វាថាយើងអ៊ីចេះអ៊ីចុះ ម្ល៉ោះហើយត្រង់តែលើតុដែលខ្ញុំអង្គុយហ្នឹង។

[០៩:៤៩:០២]

**ស៖** ប៉ុន្តែពេលលោកទៅដល់វត្តអូរត្រកួន <ដែលនៅខាងក្រោយនោះ គឺមានទន្លេមួយ> តើលោក<អាច>ដើរកាត់ពីខ្លោងទ្វារធំតែម្ដង ឬក៏លោក<អាច>ដើរវាងទៅ<ខាងកើត>? តើលោកនៅចាំទេ? ផ្លូវមួយណាដែលលោកដើរ<ដើម្បីទៅដល់កន្លែងប្រារព្ធពិធីនោះ>?

**ឆ៖** កន្លែងហ្នឹង ខ្ញុំសុំឆ្លើយ ត្រង់ថា ដូចជាភ្លេចភ្លាំងវាយូរយារណាស់មកហើយហ្នឹង ប៉ុន្តែថាប្រាកដដែលខ្ញុំមកការនៅវត្តអូរត្រកួន គឺប្រាកដណាស់។ បើរឿងដើរមកផ្លូវណាៗ ខ្ញុំដូចជាភ្លេចភ្លាំងព្រោះរឿងវាដូចវាយូរយារណាស់មកហើយ បាទ កាលពីខ្ញុំ ឥឡូវខ្ញុំជ្រុះធ្មេញចង់អស់ហើយហ្នឹង។

**ស៖** នៅពេលលោកចូលមកដល់បរិវេណវត្តអូរត្រកួន <តើ>លោកអាចមើលឃើញព្រះវិហារដែរឬទេ <ដែលជាអគារធំមួយនៅខាងឆ្វេងដៃ> នៅពេលដែលលោកចូលតាមខ្លោងទ្វារ<ធំនោះ>?

**ឆ៖** នៅវត្តអូរត្រកួននេះ ខ្ញុំមិនដែលឡើងទៅលើហ្នឹងទេ បាទ។ ខ្ញុំគ្រាន់តែតម្រង់ទិសដៅខ្ញុំមករៀបការតែប៉ុណ្ណឹងទេ បាទ មកលើតុប្ដីប្រពន្ធដែលគ្រួសារខ្ញុំនៅហ្នឹង គូព្រេងខ្ញុំហ្នឹងណ៎ះ! គឺថានីមួយៗគ្រប់គ្នាអ៊ីចឹង។ បាទ ដណ្ដើមគូ មួយគូៗប៉ុណ្ណឹង រឿងអាល័យឡើងទៅវត្ត ទៅអីហ្នឹង គ្មានទេ ព្រោះរឿងវាយូរយារណាស់មកហើយហ្នឹង។ បើខ្ញុំដឹងសព្វថ្ងៃ ដឹងថាមករៀបការកន្លែងនុ៎ងមែន។

**ស៖** លោកនៅចាំបានថា នៅពេលនោះ ក្នុងឆ្នាំ១៩៧៧ តើលោកដឹងថា មានគេ<>ឃុំឃាំងអ្នកទោសនៅក្នុងអគារណាមួយនៃវត្តនោះ ឬក៏ថានៅក្នុងព្រះវិហារនៃវត្តនោះដែរឬទេ? លោកមានដឹងទេ?

[០៩:៥២:១៦]

**ឆ៖** ខ្ញុំវាគ្រាន់តែចចាមអារាមថា ខ្មោះច្រវាក់នៅក្នុងវត្តហ្នឹង បាទ គ្រាន់តែឮប៉ុណ្ណឹង ប៉ុន្តែខ្ញុំមិនដែលទៅមើលថា អ៊ូ!វត្តហ្នឹងមានខ្នោះ មានច្រវាក់ទេ គ្រាន់តែឮចចាមអារាម កាលនុ៎ង ឮតាមគេតាមឯង។ អ៊ីចឹងឮតាមគេតាមឯង ក៏ខ្លាចតែម្ដង។ បាទ គិតតែពីធ្វើការខ្ញុំប៉ុននុ៎ង។

**ស៖** តើលោកនៅចាំទេថានៅឆ្នាំ១៩៧៧ ពេលលោករៀបការ និងឆ្នាំក្រោយមកទៀត មាន<បរិវេណ>សន្តិសុខ<មួយនៅ>ជុំវិញបរិវេណវត្តអូរត្រកួនដែរទេ?

**ឆ៖** មិនបានទៅមើលផ្ទាល់ទេ គ្រាន់តែឮទេ ប៉ុនខ្លាចឯងតែម្ដង មិនហ៊ានទៅណាទេ បាទ គិតតែពីរឿងការងារតែម្ដង។ ពីណាហ៊ានចូលទៅកន្លែងនុ៎ង កាលនុ៎ង គ្រាន់តែឮ គឺខ្លាចហើយ បាទ

មិនបានទៅមើលទេ ប៉ុន្តែឮតាមអ្នកផង។

**ស៖** ឥឡូវនេះ ខ្ញុំសូមអានសម្រង់មួយឲ្យលោកស្តាប់ គឺសម្រង់របស់សាក្សី<មួយរូបទៀត> ដែលបានឆ្លើយជូនអង្គជំនុំជម្រះ គឺនៅក្នុងបន្ទប់សវនាការនេះរួចមកហើយ។ លោកប្រធាន គឺជាសក្ខីកម្មរបស់ តាយ គឹមហ៊ាន់ គឺចម្លើយរបស់គាត់នៅក្នុង<ថ្ងៃទី១៦ ខែកញ្ញា> ឆ្នាំ២០១៥ នៅម៉ោង១៤:៤២ សំណួរគឺដូចតទៅ៖ “ដូច្នេះ បរិវេណ៧០០ ទៅ៨០០ម៉ែត្រជុំវិញវត្តហ្នឹង គឺថាគេមិនអនុញ្ញាតឲ្យប្រជាជនចូលបានទេ<។> ប៉ុន្តែ <តើមាន>បរិវេណ<កំណត់បន្ថែមទៀតទេ ដែលថា>មិនអនុញ្ញាតឲ្យប្រជាជន<រស់នៅក្នុងភូមិហ្នឹងទេ?”> ហើយ<បន្ទាប់>មក<សាក្សី>ឆ្លើយ<ថា “តើ>លោក<សំដៅទៅលើ>បរិវេណ<ជុំវិញវត្ត>វត្ត<មែន>ទេ? <បើ>និយាយបរិវេណខាងក្រៅវត្ត គឺ<ចង់>និយាយ<ចាប់>ពី<>របងវត្តរហូតទៅដល់មាត់ទន្លេតែម្តង <ហើយបរិវេណហ្នឹងត្រូវបានគេហាមឃាត់>។ ដូច្នេះ ខ្ញុំសូមបញ្ជាក់ថា នៅខាង<ជើង>វត្តគឺមានទន្លេ នៅខាងត្បូងមាន<ស្រះមួយ>។” <ហើយចុះក្រោមបន្តិច សាក្សីនោះនិយាយថា៖> “តាមដែលខ្ញុំដឹងពីទន្លេមកទល់នឹងវត្តនេះ គឺថាគេមិនអនុញ្ញាតឲ្យអ្នកណាម្នាក់ដើរជិតនោះ ឬក៏ដើរកាត់ទីកន្លែងនោះទេ។” ដូច្នេះ សំណួររបស់ខ្ញុំ<> គឺថាសាក្សីរូបនេះហាក់បីដូច<ជា>និយាយថាចាប់ពីវត្តរហូតទៅដល់ទន្លេ <>គឺជាតំបន់មួយហាមឃាត់<> ដែលមនុស្សមិនអាចចេញចូលបានទេ។ តើលោកនៅចងចាំថា វាដូច្នេះមែន ឬក៏យ៉ាងណា?

**ឆ៖** មែន ខ្ញុំ ដីនៅក្នុងភូមិសាច់ស្ងហ្នឹង គ្រាន់តែឮប៉ុណ្ណឹងហ្នឹងគ្មានអ្នកផងទាំងអស់ហ្នឹង គ្មានពីណាពីកាត់តាមនុ៎ងមែន មិនហ៊ានកាត់ទេផ្លូវហ្នឹង។ បាទ អ៊ីចឹងមែន គ្មានណា ប្រជាពលរដ្ឋទាំងអស់ហ្នឹងគ្មានពីណាហ៊ានកាត់ទេ នៅក្បែរហ្នឹងនោះ។

[០៩:៥៦:៥៨]

**ស៖** តើលោកនៅចងចាំបានទេថា<>បរិវេណ<កំណត់>ខាងក្រៅ<វត្តហ្នឹង តើមានប្រវែងប៉ុន្មាន? តើគិតចាប់ពី>បរិវេណ<វត្ត>ហ្នឹង <គឺចាប់ពី>របងវត្តហ្នឹង<រហូត>ទៅដល់ទន្លេ<មែនទេ?> ឬក៏គេកំណត់បរិវេណនៃទីតាំងនោះធំជាងនេះទៅទៀត?

**ឆ៖** ខ្ញុំមិនបានដឹង បាទមិនបានដឹងរឿងហ្នឹង ប៉ុន្តែបានដឹងដូចខ្ញុំជម្រាបមុនហ្នឹង បានដឹងប៉ុណ្ណឹងពីព្រោះថា គ្រាន់តែឮថាអ៊ីចេះអ៊ីចុះហ្នឹងគឺខ្លាចឯងហើយ កាលនុ៎ង មិនហ៊ានទៅជិតទេ។

**ស៖** ឥឡូវនេះខ្ញុំសូមបន្តទៅនឹងអ្វីដែលលោកបានឆ្លើយកាលពីពីរសប្តាហ៍មុន ថាលោកបានដើរនៅក្នុងហ្វូងជនជាតិចាមដែលត្រូវគេចាប់ខ្លួន លោកបានរត់គេចខ្លួនជាមួយនឹងប្រពន្ធរបស់លោក លោក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លាក់ខ្លួនចម្ងាយប្រហែលជា១០០ម៉ែត្រពីវត្តនោះ។ ខ្ញុំនៅតែមិនទាន់ច្បាស់នៅឡើយទីកន្លែងដែលលោកលាក់ខ្លួនហ្នឹង។ <តើ>លោក<អាច>ជម្រាបម្តងទៀត<បានទេ?> ឥឡូវនិយាយ<>ថា វត្តនៅខាងក្រោយខ្នងលោក <តើ>លោកនៅចំកន្លែងណា<>? <តើលោកនៅកន្លែងណាឲ្យប្រាកដ នៅពេលដែល>លោកឮសូរសម្រែកនៅពេលដែលគេសម្លាប់មនុស្ស<នោះ>?

**ឆ៖** បាទ ខ្ញុំនៅខាងកើត ខាងកើតទេ ខាងកើតរណ្តៅហ្នឹងទេ ចម្ងាយប្រហែលជា ខ្ញុំប្រហែលដែរ ប្រហែលជា១០០ម៉ែត្រប៉ុណ្ណឹង ប្រហែលទេបាទ ប៉ុនស្តាប់ឮសម្រែក បានខ្ញុំប្រហែលប៉ុណ្ណឹងបាទ។ ខ្ញុំពួននៅកន្លែងនុ៎ង។

**ស៖** តើ<មានអ្វីឲ្យប្រាកដនៅ>ចម្ងាយ១០០ម៉ែត្រពីវត្តទៅទិសខាងកើតហ្នឹង<? តើមានអ្វីនៅទីនោះ>ដែលអាចឲ្យលោកពួនលាក់ខ្លួនបានហ្នឹង?

**ឆ៖** កន្លែងខ្ញុំនៅពួនហ្នឹងមានគុម្ពោតព្រៃ គុម្ពោតព្រៃតូចមួយ។ បាទ មានគុម្ពោតព្រៃតូចមួយ ខ្ញុំពួនកន្លែងហ្នឹង។ អ៊ីចឹង ពួនកន្លែងហ្នឹង ដែលឮសម្រែកមក ដែលខ្ញុំឮហ្នឹង ឮសម្រែកថា "អស់ឡោះប៉ូលីយ!" អ៊ីចឹង ខ្ញុំពួកន្លែងហ្នឹង បានខ្ញុំប៉ាន់ស្មានថា ១០០ម៉ែត្រហ្នឹង ប្រហែលជាខ្ញុំមិនបានទៅវាស់ម៉ែត្រទេ ព្រោះខ្ញុំអាល័យជីវិតខ្ញុំ។

**ស៖** <តើ>លោក<អាចប្រាប់អង្គជំនុំជម្រះពីចម្ងាយប៉ាន់ស្មានថាតើ> គិត<>ពីទន្លេមេគង្គមកកន្លែងលោកលាក់ខ្លួន<របស់លោក តើមាន>ចម្ងាយប៉ុន្មាន?

**ឆ៖** ខ្ញុំប្រហែលទេ ប្រហែលជា៧កន្លះគីឡូហ្នឹង វាប្រហែល ខ្ញុំប្រហែលទេ មកកន្លែងខ្ញុំលាក់ខ្លួនក្នុងថ្លុកនោះណ៎ា ប្រហែលជាកន្លះគីឡូទេ ៥០០ម៉ែត្រអីប៉ុណ្ណឹង។

[១០:០១:២៧]

**ស៖** <ចុះបើ>គិតពីផ្លូវនៅខាងកើតវត្ត<តែម្តង តើ>លោក<នៅ>ចម្ងាយប៉ុន្មានពីផ្លូវនៅខាងកើតវត្តហ្នឹង?

**ឆ៖** ផ្លូវ អាផ្លូវនៅខាងកើតវត្តហ្នឹង? ចម្ងាយនេះ ចម្ងាយ ខ្ញុំមើលទៅចម្ងាយប៉ុណ្ណឹងដែរ ពីព្រោះថា កន្លែងថ្លុកដែលខ្ញុំនៅហ្នឹង វាចម្ងាយប៉ុណ្ណឹងដែរទេ ប្រហែលជាមួយគីឡូទេ ទៅដល់អាត្រពាំងដែលខ្ញុំនៅក្រាបហ្នឹង មាត់ត្រពាំងហ្នឹង។ ប្រហែល១គីឡូ ខ្ញុំប្រហែលដែរទេ បាទ។

**ស៖** ខ្ញុំសូមបញ្ជាក់ឲ្យច្បាស់បន្តិចមើលលោក<តើអ្វីជា>ចម្ងាយ<>១គីឡូម៉ែត្រ<ឲ្យប្រាកដ>?

**ឆ៖** ប្រហែលជា១គីឡូម៉ែត្រហ្នឹងហើយ ខ្ញុំប្រហែលទេ។ បាទ កាលនោះ អត់មានម៉ែត្រ

មានផឹងទេ ព្រោះអាល័យជីវិត។

**ស៖** ចម្ងាយ១គីឡូម៉ែត្រហ្នឹង គឺគិតពីទន្លេមក ឬក៏គិត<ពីវត្តមក តើវាជា>ថ្នុក<>ដែលលោកលាក់ខ្លួន <មែនដែរឬទេ>?

**ឆ៖** ខ្ញុំគិតពីថ្លុកដែលខ្ញុំនៅពួនមក ថ្លុកដែលខ្ញុំនៅពួនមកហ្នឹង នៅកន្លែងថ្លុកដែលខ្ញុំទៅលាក់ខ្លួនហ្នឹង ខ្ញុំគិតពីហ្នឹងមកដល់ទន្លេមេគង្គនេះ ប្រហែលជា១គីឡូដី ១០០០ម៉ែត្រ ប្រហែលបាទ។

**ស៖** ដូច្នេះថ្លុកនេះ<ប្រាកដជានៅចម្ងាយពាក់កណ្ដាលហើយ> គឺមានចម្ងាយប្រហែល <៥០០>ម៉ែត្រពីវត្តអូរត្រកួនហ្នឹង<>។ អ៊ីចឹង ត្រឹមត្រូវដែរឬទេ?

**ឆ៖** បើចែកគ្នាហ្នឹង គឺខ្ញុំមិនបានដឹងទេ ព្រោះខ្ញុំសុទ្ធតែប្រហែលទាំងអស់អ៊ីចឹង។ បើទន្លេមេគង្គមកត្រឹមហ្នឹង ហើយពីវត្តមកទៀតហ្នឹង មិនដឹងប៉ុន្មានទៀត ខ្ញុំក៏មិនបានដឹង សុទ្ធតែប្រហែលទាំងអស់។

[១០:០៤:៣២]

**ស៖** ឥឡូវនេះ ខ្ញុំ<កំពុង>និយាយអំពីស្រះ<តែមួយ>ដែលលោកបានឆ្លើយជូនតុលាការកាលពីពីរសប្ដាហ៍មុននេះ ថានៅពេលដែលកងទ័ពខ្មែរក្រហមបាញ់កាំភ្លើង "អឹម៧៩, <បេ៤០ និងកាំភ្លើង>អាកា<សំដៅមករកលោក>នៅក្នុងស្រះ<នោះ">។ <តើ>លោក<ចង់>សំដៅទៅលើស្រះតែមួយ <ដែលលោកត្រូវបាន>ខ្មែរក្រហមបាញ់<ដោយកាំភ្លើងធុនធ្ងន់មែនដែរឬទេ>?

**ឆ៖** ដល់ពេលខ្មែរក្រហមអ្នកបាញ់ហ្នឹង បាញ់ស្រះដែលខ្ញុំនៅហ្នឹង។ បាទ ដែលខ្ញុំរត់ពួនក្នុងហ្នឹង បាញ់រះកំប្លោកដែលខ្ញុំពួនហ្នឹង។ រះបឹង វ៉ាល់ហ្វាល់ ហើយបាញ់បន្តក់សេវេនធីណៃចូលក្នុងទឹក។ មួយថ្ងៃហ្នឹងខ្ញុំត្រាំទឹកមួយថ្ងៃហ្នឹង ព្រលឹមទាល់ល្ងាច ឮតែស្នូរបាញ់ ឮតែគ្រាប់រត់។ ហើយក្រោយមកមួយយប់មក គេនៅព័ទ្ធជុំវិញបឹងហ្នឹង ហើយជុំវិញបឹងហ្នឹងហើយ ព្រលឹមឡើងមានអ្នកភូមិមកប្រាំភូមិមកជាន់ថ្លុកហ្នឹង ថ្លុកដែលខ្ញុំពួនហ្នឹង។ សុទ្ធតែមនុស្សដូចកចិន។ បាទ យប់មកពួកហ្នឹងមកយាមជុំវិញថ្ងៃមក គេកែនអ្នកភូមិមកព័ទ្ធខ្ញុំហ្នឹង មករើសកំប្លោកដាក់មួយដុំៗ ដែលកំប្លោកដែលខ្ញុំរើដាក់លើទូលលើក្បាល។

**ស៖** តើគេបាញ់តម្រង់តែទៅលោកទេ ឬនៅក្នុងស្រះហ្នឹងមានអ្នកដទៃទៀតដែរ?

**ឆ៖** ក្នុងស្រះហ្នឹងគ្មានអ្នកណាទេ គឺមានតែខ្ញុំហើយប្រពន្ធរបស់ខ្ញុំពីរនាក់ហ្នឹង ព្រោះខ្ញុំចូលទៅគឺគ្មាននរណាម្នាក់ទេ។ បាញ់ហ្នឹង បាញ់ខ្ញុំតែម្ដងតាមខ្ញុំគិត ប្រពន្ធថាគ្រាប់រត់ជិតៗខ្ញុំ ហើយធ្លាក់ក្បែរៗខ្ញុំ ប៉ុន្តែសំណាងល្អវាមិនត្រូវ។

[១០:០៧:៣៣]

**ស៖** លោកសាក្សីធ្វើយ៉ាងដូចម្ដេចបានលោកដឹងថា គេបាញ់កាំភ្លើង អឹមសេវេនធីណៃ <និង> បាញ់គ្រាប់ បេ៤០ <>សំដៅទៅ<រកលោកនៅ>កន្លែងហ្នឹង <តើ>ធ្វើម៉េចបានលោកបានដឹង<ថាវាបានកើតឡើង នៅពេលលោកកំពុងតែលាក់ខ្លួនអស់ពេល៣ខែ និង២៩ថ្ងៃនោះ>?

**ឆ៖** បេ៤០ ខ្ញុំមិនបានសួរដឹងទេ ប៉ុន្តែខ្ញុំឮសំឡេងៗ បេ៤០ មុននឹងទៅឮខ្យល់សួរឡើងឆ្ងាច់បាទ ឆ្ងាច់ហើយធ្លាក់ទៅវិញខឹង។ អាហ្នឹងមានន័យថា បេ៤០។ រួច អឹមសេវេនធីណៃ ផក់ៗ ក្នុង អាហ្នឹង អឹមសេវេនធីណៃ បាទ។ រួចកាំភ្លើងអាកា បាញ់អាការ៉ល់ហ្វាល់ហ្នឹងផ្សេង គូប៉ាគូផ្សេង ខ្ញុំដឹងថាអាកា។ ដឹងប៉ុណ្ណឹង ស្មានផងទេ។ បាទ ស្មានទេ ព្រោះខ្ញុំ ទោះបីថាខ្ញុំមិនធ្វើអីក៏ដោយ មិនធ្វើទាហានក៏ដោយ មិនធ្វើស្អីក៏ដោយក៏ខ្ញុំឆ្លងកាត់គេហៅថាឮ គេហៅថា ស្រុកទេសមានសង្គ្រាម ឮបាទ អាចចាំសំឡេងអស់ហ្នឹង។

**ស៖** ដូច្នេះ អាវុធធន់ធ្ងន់ទាំងអស់នេះ ត្រូវបានគេយកទៅប្រើប្រាស់ដើម្បីបាញ់សំដៅតែទៅលោក ហើយនិងប្រពន្ធលោកដែលលាក់ខ្លួន ហើយលាក់ខ្លួននៅក្នុងស្រះនោះ។ តើអ៊ីចឹងឬក៏យ៉ាងណា?

**ឆ៖** ខ្ញុំហ្នឹង ខ្ញុំពិបាកគិតដែរអស់លោក មិនដឹងជា អាចិកំបាំងជាម៉េចទេ។ ប៉ុន្តែខ្ញុំដឹងតែត្រឹមតែគេយកទៅបាញ់ខ្ញុំប៉ុណ្ណឹង។ បាទដឹង គ្រាន់ថាឮៗថាមកបាញ់ខ្ញុំប៉ុណ្ណឹងហើយ គ្រាន់តែឮគេហៅថា តាមដានខ្មាំងទី១ហ្នឹង ខ្មាំងចាម ខ្មាំងទី១ហ្នឹង បាទ ដាក់ខ្មាំងទី១។ ហើយមកបាញ់ខ្ញុំអ៊ីចឹងទៀត ក៏ខ្ញុំរឹតតែគិតទៅទៀតហ្នឹង មិនដឹងអាចិកំបាំងរបស់គេមិនដឹងគេយល់ម៉េចទេ បើខ្ញុំម្នាក់យកកាំភ្លើងមកបាញ់ដែរ ប៉ុន្តែខ្ញុំឮមុនថា ខ្មាំងចាម ខ្មាំងទី១ ពួកខ្ញុំនេះចាមបាទ។

[១០:១០:៣៣]

**ស៖** តែអ្វីដែលលោកកំពុងតែរៀបរាប់នេះ គឺកើតឡើងនៅពាក់កណ្ដាលឆ្នាំ១៩៧៧ ប៉ុន្តែអ្វីដែលលោកឮថាចាមគឺជាខ្មាំងទី១ គឺឮតាំងពីឆ្នាំ១៩៧៥ <ឬ១៩៧៦ មក>ម្ល៉េះ។ អ៊ីចឹង តើវាមាន<>ទំនាក់ទំនងគ្នាទេ<រវាង>អ្វីដែលលោកឮ<នៅឆ្នាំ>៧៥ <ឬឆ្នាំ៧៦> និងអ្វីដែលកើតឡើងពាក់កណ្ដាល៧៧?

**ឆ៖** រឿងហ្នឹងហើយបានថា ខ្ញុំមិនចាំថ្ងៃចាំខែទេ ព្រោះខ្ញុំបានឮមិនដឹងជាខែប៉ុន្មាន ឆ្នាំប៉ុន្មានប៉ុន្តែខ្ញុំដែលបានឮនៅភូមិខ្សាច់សហ្នឹង បាទឮអ៊ីចឹង។ រួចថា ឆ្នាំនេះឆ្នាំនោះ បាទ ខ្ញុំមិនបានដឹងទេ ព្រោះថាខ្ញុំ គ្រាន់ថា ច្បាស់ដែលខ្ញុំឮចចាមអារាមគឺអ៊ីចឹងតែម្ដងបាទ។ រួចដាក់គេដាក់លេខថ្ងៃហ្នឹងខុសយ៉ាងម៉េចយ៉ាងម៉ា ខ្ញុំមិនដឹងទេ ប៉ុន្តែខ្ញុំចាំដែលថាគេឮចចាមអារាម ឮអ៊ីចឹងមែន ដាក់ខ្មាំងទី១ ឮ បាទ ឮគេ

និយាយអ៊ីចឹងតែម្តង។ រួចក្រោយមកហ្នឹងក៏វាយ៉ាប់យ៉ឺនចាម។ បាទប៉ុណ្ណឹង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ អរគុណដើមបណ្តឹងរដ្ឋប្បវេណី ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួល ផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅពេលវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១២ នាទី ដល់ម៉ោង ១០:៣៤ នាទី)*

[១០:៣៤:១៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុននឹងផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តី នួន ជា អង្គជំនុំជម្រះសូមជម្រាបឆ្លើយតបទៅនឹងសំណើសុំរបស់សហមេធាវីការពារក្តីលោក ខៀវ សំផន។ អង្គជំនុំជម្រះឆ្លើយតបថា អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន ក្នុងការពន្យារពេលការឆ្លើយតបទៅនឹងសំណើសុំរបស់ការិយាល័យសហព្រះរាជអាជ្ញា ឯកសារ E370 គឺរហូតដល់ក្រោយពេលដែលអង្គជំនុំជម្រះមានលទ្ធភាពចេញសេចក្តីសម្រេចលើសំណុំសុំរបស់ក្រុមមេធាវីការពារក្តី ឯកសារ E363 ហើយអង្គជំនុំជម្រះក៏សូមជម្រាបជូនភាគីពាក់ព័ន្ធផងដែរថា ការឆ្លើយតបទៅនឹងសំណើសុំរបស់សហព្រះរាជអាជ្ញា E370នេះ អង្គជំនុំជម្រះតម្រូវឲ្យភាគីធ្វើសេចក្តីឆ្លើយតបផ្ទាល់មាត់នៅក្នុងពេលសមស្របណាមួយ ដោយមិនឲ្យធ្វើសេចក្តីឆ្លើយតបជាលាយលក្ខណ៍អក្សរទេ ហើយអង្គជំនុំជម្រះក៏សូមជម្រាបជូនថា អង្គជំនុំជម្រះនឹងខិតខំប្រឹងប្រែង

ដើម្បីចេញសេចក្តីសម្រេចរបស់ខ្លួនលើសំណើសុំរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន ឯកសារ E363 ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ហើយនិងតាមមធ្យោបាយ និងលទ្ធភាពសមស្រប បំផុត ដើម្បីដោះស្រាយបញ្ហាប្រឈមចំពោះមុខខ្លួននាពេលនេះ ដើម្បីឱ្យដំណើរការសវនាការស្តាប់សក្ខី កម្មសាក្សីដែលបាន ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានគ្រោងទុកនៅក្នុងសប្តាហ៍នេះ និងសប្តាហ៍ក្រោយ អាចប្រព្រឹត្តទៅបាន។

ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តី នួន ជា ដើម្បីបន្តការ តាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណី។

[១០:៣៦:២០]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរសាជាថ្មីលោកសាក្សី។ ខ្ញុំព្យាយាមស្វែងយល់ថា តើលោកស្ថិតនៅត្រង់កន្លែង ណាពិតប្រាកដនៅពេលដែលលោកបានឆ្លើយថា លោកបានធ្លាក់ខ្លួន ៣ខែ ២៩ថ្ងៃ នៅក្នុងស្រះមួយក្បែរ វត្តនោះ។ ឥឡូវដំបូង ខ្ញុំសូមសួរទៅលោកថា តើៗថ្លុកមួយនេះ នៅទីនោះដដែលឬសព្វថ្ងៃនេះ?

**លោក ហ៊ឹម ម៉ាន៖**

**ឆ៖** បាទ នៅដដែល។ ថ្លុកហ្នឹងនៅទេសព្វថ្ងៃនេះ ប៉ុន្តែវាគ្រាន់តែអស់កំប្លោកប៉ុណ្ណឹងទេ កំប្លោក វានៅមាននៅខ្លះសព្វថ្ងៃហ្នឹង។ កាលពីមុនកំប្លោកវាណែន បាទ។

**ស៖** មុនពេលឈប់សម្រាក មុននេះបន្តិចនេះ គឺថាដូចខ្ញុំបាននិយាយទៅសួរលោក<អំពីផ្លូវមួយ ដែលនៅចំប៉ែកខាងកើតជាប់បរិវេណវត្តហ្នឹងតែម្តង។> តើ<លោកនៅចាំទេថាមាន>ផ្លូវ<លំតូចមួយ >នៅខាងកើតវត្តនេះ<ដែល>ជាប់បរិវេណវត្តតែម្តង<ដែរ>ឬ<ទេ>? តើមានផ្លូវតូចណាមួយភ្ជាប់ពី វត្ត ទៅទិសខាងកើតដោយផ្ទាល់នោះដែរទេ?

**ឆ៖** ផ្លូវមួយដែលនៅថាខាងកើតវត្តហ្នឹង គឺផ្លូវធំហ្នឹង មានមែន ក៏ប៉ុន្តែផ្លូវដែលខ្ញុំនៅពួនសម្ងំ នៅហ្នឹងមានខាងកើតហ្នឹង ផ្លូវតូចតាច ផ្លូវហៅថាផ្លូវស្រែ បាទ ខ្វាត់ខ្វែងនៅតាមហ្នឹង ដែលខ្ញុំក្រាបនៅ ក្បែររណ្តៅហ្នឹង ប្រហែលជា១០០ម៉ែត្រហ្នឹង ប្រហែល ហ្នឹងផ្លូវតូចតាចទេ។ ផ្លូវវត្តហ្នឹង ផ្លូវមានមែន បាទ ខាងកើតវត្តហ្នឹង បាទ។ បើខ្ញុំនេះនៅខាងផ្លូវតូចតាច នៅខាងកើតមកទៀត ខាងកើតផ្លូវហ្នឹងមក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅ ក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ទៀត។

[១០:៣៨:៥៣]

**ស៖** ហើយផ្លូវដែលខ្ញុំទើបតែសួរនៅខាងកើតវត្តនេះ <តើវា>ជាផ្លូវតម្រង់ទៅទិសខាងជើង ហើយព័ទ្ធជុំវិញថ្លុកមួយហ្នឹង <ហើយបត់ទៅទិសខាងត្បូងវិញ គឺទៅទន្លេ> តើត្រឹមត្រូវដែរឬក៏អត់ទេ?

**ឆ៖** ផ្លូវមួយហ្នឹងវាមកខាងកើតវត្តហ្នឹង វាបើនិយាយឲ្យចំទៅ ទៅត្រង់ទៅ ធ្លាក់ទៅរណ្ដៅខ្ញុំក្រាបហ្នឹងតែម្ដង ធ្លាក់ទៅរណ្ដៅខ្ញុំក្រាបហ្នឹងតែម្ដង។ ផ្លូវៗវត្ត ដែលថាផ្លូវធំនៅខាងកើតវត្តហ្នឹងណា ទៅរណ្ដៅថ្លុកដែលខ្ញុំក្រាបហ្នឹងហើយ ប៉ុន្តែមិនដឹងចម្ងាយប៉ុន្មានម៉ែត្រៗហ្នឹង រឿងហ្នឹងសុទ្ធប្រហែលហើយ។ បើចម្ងាយពីថ្លុកខ្ញុំមកហ្នឹង ប្រហែលដែរទេ ដែលខ្ញុំនៅក្នុងបឹងហ្នឹងនុះ។ អាមួយហ្នឹង ខ្ញុំចូលក្នុងបឹង អាមួយហ្នឹងខ្ញុំក្រាបទ្រោលចូលក្នុងបឹង។

**ស៖** អ៊ីចឹងឥឡូវនេះ<>មានត្រពាំងមួយនៅខាងកើតវត្ត ចម្ងាយប្រហែលជា១គីឡូម៉ែត្រ<ខាងជើងទន្លេហ្នឹង ហើយប្រហែល៥០០ ម៉ែត្រ ឬ១គីឡូម៉ែត្រពីវត្ត ខ្ញុំមិនសូវច្បាស់ត្រង់ចំណុចនេះ។> ប៉ុន្តែសំណួរខ្ញុំ សួរថា តើ<>ផ្លូវ<ហ្នឹងនៅ>ព័ទ្ធជុំវិញ<វត្ត> ហើយ<បត់ទៅ>ខាងត្បូងវត្ត<វិញ តើ> អ៊ីចឹង<មែន>ទេ?

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយតប សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

ខ្ញុំមិនបានក្រោកឡើង<មុន>ហ្នឹង តែឥឡូវនេះឃើញថា លោកមេធាវីកំពុងតែផ្ដល់សក្ខីកម្មខ្លួនឯងហើយទាក់ទងនឹងទីតាំងភូមិសាស្ត្រនុ៎ង<។ គាត់គួរតែ>យោងទៅឯកសារមួយនៅក្នុងសំណុំរឿងវិញ <ឬក៏អាចយោងទៅលើ>រូបថតដែលបានថតដោយ<អ្នកស៊ើបអង្កេតនៃការិយាល័យសហ>ចៅក្រមស៊ើបអង្កេត <គឺថា>វាមានលក្ខណៈសត្យានុម័តជាង ឥឡូវនេះគាត់ ការលើកឡើងរបស់លោកមេធាវីទាំងប៉ុន្មានហ្នឹង វាដូចជាលក្ខណៈអត្តនោម័តិខ្លាំង។ អ៊ីចឹង<យើងអាច>យោងទៅលើឯកសារអីមួយនៅក្នុងសំណុំរឿង<ដើម្បីរៀបរាប់ពីទីតាំងភូមិសាស្ត្រហ្នឹង>។

[១០:៤១:៣៥]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន អ្វីដែលខ្ញុំព្យាយាមសួរនោះ គឺខ្ញុំចង់ដឹង ថាតើគាត់ពិតជាបានលាក់ខ្លួននៅចំកន្លែង

ណាដែរក្នុងរយៈពេល៣ខែ ២៩ថ្ងៃនោះ<។ ជាការពិតណាស់> ពេលដែលសួរនោះ <>ខ្ញុំមិនបានប្រើប្រាស់ឯកសារ<ផ្សេងៗនៅក្នុងសំណុំរឿង>នេះទេ។ ប៉ុន្មានថ្ងៃ<មុន>នេះ ខ្ញុំក៏បានទៅទីនោះដើម្បីព្យាយាមយល់<ពី>ទីតាំង<ទាំង>នោះ<។ ការទៅមើលទីតាំងនេះពិតជាមានប្រយោជន៍ណាស់ ហើយគ្រប់គ្នាគួរតែធ្វើបែបនេះ។> ដោយសារថាមានផ្លូវមួយនៅខាងកើតវត្ត តម្រង់ទៅទិសខាងជើង<ហើយ>បត់មកជុំវិញ<ស្រះ>វិញ។ <ខ្ញុំគ្រាន់តែព្យាយាមស្វែងយល់ពីអ្វីដែលសាក្សីនិយាយ ថាតើស្រះដែលខ្ញុំគិតថានៅទីនោះ គឺជាស្រះដែលសាក្សីកំពុងតែនិយាយដែរឬទេ?>

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៤២:៤៥]

**ប្រធានអង្គជំនុំ៖**

បាទ ហើយការកត់សម្គាល់របស់សហព្រះរាជអាជ្ញារងអន្តរជាតិ គឺសមស្រប ហើយបញ្ហានេះធ្លាប់បានកើតម្តងហើយកាលពីមន្ទីរសន្តិសុខក្រាំងតាចាន់ ហើយឥឡូវនេះកើតឡើងសាជាថ្មីម្តងទៀត។ សូមលោកមេធាវីការពារក្តីលោក វ៉ិចទ័រ កូប៉េ កែសម្រួលពាក្យសំណួរលោកឡើងវិញ ជៀសវាងលោកធ្វើសក្ខីកម្មខ្លួនឯងមកសួរដេញដោលសាក្សី យកការដឹងអត្តនោម័តិរបស់ខ្លួន យកមកសួរដេញដោលសាក្សី ដែលបង្ហាញពីការផ្តល់សក្ខីកម្មដល់សាក្សីដោយខ្លួនអ្នកសួរ។

សាក្សីមិនឆ្លើយតបនឹងសំណួរនេះទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ដូច្នេះលោកប្រធានអនុញ្ញាតឲ្យខ្ញុំរៀបចំសំណួរឡើងវិញ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី មកដល់សព្វថ្ងៃនេះ តើលោកដឹងថាមានផ្លូវមួយភ្ជាប់ពីទិសខាងកើតវត្តតម្រង់ទៅទិសខាងជើង<>សំដៅ<ទៅ>ស្រះនោះដែរឬទេ មកដល់សព្វថ្ងៃនេះ<។ តើ>លោកដឹងថាមានផ្លូវមួយហ្នឹង<នៅព័ទ្ធជុំវិញ>ស្រះ<ហ្នឹង>ដែរ<ឬ>ទេ? <តើលោកដឹងទេ?>

[១០:៤៤:១១]

**លោក ហ៊ីម ម៉ាន៖**

**ឆ៖** សព្វថ្ងៃមានតើ មានផ្លូវថ្មីគេកសាងថ្មីហ្នឹង គេធ្វើធ្លាក់ទៅដល់ស្រះដែលខ្ញុំពួនហ្នឹង។ គេហៅបឹងក៏បាន ស្រះក៏បានដែលខ្ញុំពួនហ្នឹង។ មកទៅតាមផ្លូវណាក៏បានដែរ ផ្លូវហ្នឹង។ ផ្លូវខាងកើត ដែល

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ថាខាងកើតវត្តអូរត្រកួនហ្នឹងណ៎ា មានច្រើនណាស់សព្វថ្ងៃហ្នឹង ឲ្យតែថាទៅក្នុងបឹងកន្លែងបបុស គឺមិនអាចវង្វេងទេ។ រួចដល់ផ្លូវពីមុនហ្នឹង ផ្លូវហ្នឹងវាអើ បើផ្លូវស្រែផ្លូវអី ខ្ញុំវត់ឲ្យតែបានមក។ ផ្លូវតឡូវនេះ វាកើត ចង់ទៅកន្លែងបបុសហ្នឹងបាន។ អត់មានវង្វេងទេ កន្លែងបបុសដែលខ្ញុំពួនហ្នឹង គេហៅកន្លែងបបុសថាត្រពាំង ថាស្រះ ហ្នឹងកន្លែងបបុសហ្នឹងហើយ។ អាកន្លែងខ្ញុំពួននោះ។

**ស៖** តើលោកមានចម្ងាយប៉ុន្មានពីផ្លូវធំ<ដែលតម្រង់ទៅទិសខាងត្បូង ពីខាងត្បូងឆ្ពោះទៅខាងជើង> គឺ<>ផ្លូវលេខ៧០ <>តើលោកនៅចម្ងាយប៉ុន្មានពីផ្លូវលេខ៧០?

**ឆ៖** ផ្លូវលេខ៧០ គេកសាងថ្មីហ្នឹង អស់លោក? ខ្ញុំមិនបានចំណាំទុក ប្រហែលជាប៉ុន្មានៗទេ។ វាគ្រាន់តែប្រហែល។ ហ៊ឹះ! ពិបាកនឹងឆ្លើយណាស់ អស់លោក។

[១០:៤៦:៣៩]

**ស៖** ខ្ញុំខ្លាចតែយើងយល់គ្នាមិនបានច្បាស់។ អ៊ីចឹង ខ្ញុំប្តូរទៅប្រធានបទថ្មីទៅចុះ។ នៅពេលមួយលោកបានឆ្លើយថា លោកចង់បះបោរដែរនៅពេលដែលលោកលាក់ខ្លួនហ្នឹង លោកក៏បានទៅព្រះវិហារមួយដើម្បីស្វែងរកកាំភ្លើង ទៅរកកាំភ្លើង។ ហេតុអ្វីបានជាលោកទៅព្រះវិហារចាមនៅពេលហ្នឹង ដើម្បីទៅរកកាំភ្លើង។ តើនៅពេលហ្នឹង មានអ្វីធ្វើឲ្យលោកគិតថាអាចនឹងមានកាំភ្លើងនៅក្នុងព្រះវិហារចាមនុ៎ង?

**ឆ៖** បាទ ខ្ញុំៗនៅក្រាបនៅហ្នឹង ខ្ញុំវាអស់សង្ឃឹមថា បងប្អូនខ្ញុំដែលស្រែកថា "អល់ឡោះប៉ូលីយៗ!" អ៊ីចឹង ខ្ញុំក្រាបកន្លែងហ្នឹង ហើយខ្ញុំចង់ទៅរកកាំភ្លើង។ កាំភ្លើងមិនដឹងនៅគោលដៅណាទេ។ ខ្ញុំទៅដើរ គេហៅថា ទៅៗៗក្រែងរកមានជួបកាំភ្លើងអី ខ្ញុំមកជួយបងប្អូនខ្ញុំ ដែលនៅក្នុងរណ្តៅ គេនៅវ៉ៃចោលនុ៎ង បាទ។ ហើយទៅនុ៎ង នៅក្នុងព្រះវិហារហ្នឹង វិហារចាម បាទ វិហារចាមហ្នឹង ខ្ញុំក៏ឡើងទៅឡើងទៅហ្នឹងក៏រកកាំភ្លើង រកកាំភ្លើងហ្នឹងវាគ្មាន វាគ្មាន ក៏អស់សង្ឃឹម បាទ បើសិនជាខ្ញុំទៅរកកាំភ្លើងហើយបានមែន ខ្ញុំមកជួយបងប្អូនខ្ញុំហើយ។ ព្រោះខ្ញុំអាណិតបងប្អូនខ្ញុំ អាណិតប្អូនខ្ញុំ អាណិតពូជអំបូរខ្ញុំអាណិតទាំងអស់ អ្នកភូមិទាំងអស់ បានជាខ្ញុំទៅស្វែងរក ទៅរកកាំភ្លើង ខ្ញុំមិនមែនទៅលាក់កាំភ្លើងទេ។ ខ្ញុំទៅរក រើសកាំភ្លើង និយាយឲ្យចំទៅ។ ក្រែងលោមានកាំភ្លើងដែរ ខ្ញុំទៅជួយ។ ព្រោះខ្មែរក្រហមកំពុងតែនៅធ្វើបាបបងប្អូនខ្ញុំ។ ប៉ុណ្ណឹង។

[១០:៤៩:១១]

**ស៖** ហើយលោកក៏បានឆ្លើយដែរថា ព្រះវិហារចាមហ្នឹង គេលែងឲ្យប្រើប្រាស់តទៅទៀត

ហើយ ហើយគេយកព្រះវិហារហ្នឹង ទៅធ្វើជាជង្រុកស្រូវ។ អ៊ីចឹង នៅពេលហ្នឹងមានអ្វីដែលនាំឲ្យលោកគិតថា អាច<រក>កាំភ្លើង<បាន>នៅ<ក្នុងវិហារចាមហ្នឹង?> ហេតុអ្វីបានជាលោកទៅកាន់ព្រះវិហារ<ហ្នឹង>ដើម្បីទៅរកកាំភ្លើង?

**ឆ៖** បាទ ខ្ញុំមាន ពួកហ្នឹងវាទៅយាមកន្លែងហ្នឹង ព្រោះវាលែងឲ្យថ្វាយបង្គំហើយ ហើយវាយកព្រះវិហារហ្នឹង ដាក់ជា គេហៅថាត្បាល់កិន ត្បាល់អីហ្នឹង ហើយមានអង្ករស្លាបព្រាអីនៅក្នុងហ្នឹង បាទ ហើយនៅក្នុងហ្នឹង គឺមានអ្នកយាមៗ ខ្ញុំគិតថា ប្រហែលជាអ្នកយាមនេះពួកខ្មែរក្រហមនេះគឺ ប្រហែលជាមានកាំភ្លើងហើយ ខ្ញុំទៅរកមើល ព្រោះគេកំពុងនៅប្រហារបងប្អូនខ្ញុំណ៎ះ! ទៅដើររក បាទ។ ទៅរកហ្នឹងឃើញដេកតម្រៀប អ៊ីចឹងទៅវាអត់ដឹងខ្ញុំទេ ខ្ញុំបានទៅស្ទាបក្បាលវាទៀត វាអត់ដឹងទេ។ ប៉ុន្តែវាអត់មានកាំភ្លើង បើមានកាំភ្លើងខ្ញុំលួចយកមកហើយ ខ្ញុំយកមកជួយបងប្អូនខ្ញុំ។ បាទ ប៉ុណ្ណឹង។

**ស៖** តើព្រះវិហារមួយនេះ ស្ថិតនៅកន្លែងណាដែរ ស្ថិតនៅក្នុងភូមិអ្វីដែរ?

**ឆ៖** ព្រះវិហារមួយនេះ ស្ថិតនៅភូមិ គេហៅភូមិតាសូៗបាទ ភូមិតាសូ គេហៅព្រែកតាសូៗ គេហៅថាភូមិតាសូហ្នឹង ហ្នឹងណា នៅក្បែរពាមជីកងហ្នឹងហើយ នៅកៀកគ្នាភូមិជីកងហ្នឹង។ ភូមិចាមហ្នឹងភូមិតាសូ។

**ស៖** នៅក្នុងសក្ខីកម្មរបស់លោកកាលពីពីរសប្តាហ៍កន្លងទៅ លោកបានឆ្លើយនូវអ្វីដែលបានកើតឡើងនៅឯស្រះនោះ។ លោកប្រធាននេះគឺឯកសារ គឺគាត់បានឆ្លើយនៅ<ម៉ោង ១៤:០០:៥១វិនាទី នៅ>ថ្ងៃទី<១៧> ខែកញ្ញា គាត់ថា៖ “<ទោះជាយ៉ាងម៉េចក៏ដោយ> ប្រជាជនរស់នៅក្បែរនោះ គឺថាគេបានជួយ<អង្គរខ្មែរក្រហមឲ្យទុក>ជីវិត<ឲ្យ>ខ្ញុំ ដោយសារថាខ្ញុំនេះមិនពាក់ព័ន្ធនៅក្នុងការចោទប្រកាន់ទៅលើសកម្មភាពណាមួយនោះទេ”។ នៅពេលលោកនិយាយថា លោកមិនបានចូលរួមពាក់ព័ន្ធនៅក្នុងសកម្មភាពដូចដែលគេបានចោទប្រកាន់ តើលោកចង់និយាយថាម៉េចដែរ?

**ឆ៖** ព្រោះខ្ញុំមកគេឲ្យរស់នៅដោយសារថាខ្ញុំមានតម្រិះមួយដែលគេទុកឲ្យហ្នឹង ជនជាតិងាប់អស់ហើយនៅសល់តែខ្ញុំ ហើយនៅសល់តែខ្ញុំដែលខ្ញុំគេចាប់បានមកវិញហ្នឹង ហើយនៅសល់តែខ្ញុំៗបច្ចេកទេខាងមុជទឹកនៅបាតទន្លេ បាទ។ រួចអ្នកដែលៗវាយមងខាងនេសាទត្រីហ្នឹង គេត្រូវការអ្នកមុជទឹក ។ បាទ អ៊ីចឹងកន្លែងហ្នឹងហើយដែលគេឲ្យខ្ញុំរស់តទៅទៀតហ្នឹង គេនាំគ្នាស្រឡាញ់ខ្ញុំ អ្នកភូមិ ដើម្បីខ្ញុំ ធ្វើការនៅបាតទន្លេហ្នឹងបាន ព្រោះវាអស់មនុស្សជំនាញខាងបាតទន្លេហើយ។

[១០:៥៣:៣៣]

**ស៖** លោកសាក្សីកាលពីពីរសប្ដាហ៍កន្លងទៅ នៅពេលដែលគេសួរលោកឲ្យឆ្លើយដោយស្ម័គ្រចិត្ត សូមដកស្រង់៖ "ខ្ញុំមិនមែនជាអ្នកនិពន្ធ<ប្រលោមលោក ហើយមិនមែនមកទីនេះដើម្បី>ប្រឌិតរឿងអ្វី<ដែរ។"> តើលោកចង់និយាយថាម៉េច<ត្រង់>ចំណុចនេះ?

**ឆ៖** ខ្ញុំៗមិនមែននិពន្ធរឿងទេ ព្រោះខ្ញុំអ្នកការពិត ព្រោះខ្ញុំដែលខ្ញុំឆ្លងកាត់ការពិត ដែលខ្ញុំគេយកទៅសម្លាប់ ខ្ញុំឃើញការពិតៗ ហើយដោយខ្ញុំនៅភ្លេចភ្លាំងសព្វថ្ងៃនេះ ដែលមកសួរក្រោយនេះ ដោយសារខ្ញុំភ្លេចភ្លាំងដោយសារថា ខ្ញុំកាលហ្នឹងខ្ញុំនៅពីក្មេង រួចឥឡូវនេះ ខ្ញុំនេះវាចាស់ វាចង់អស់ធ្មេញអស់ទៅហើយ អីចឹងវានៅភ្លេចភ្លាំង វានៅខ្លះៗ ប៉ុន្តែការ មិនមែនការប្រឌិតទេ គឺតាមខ្ញុំឆ្លងកាត់ ហើយដោយសារខ្ញុំភ្លេចខ្លះនេះ ដោយសារខ្ញុំចាស់។

**ស៖** តើសព្វថ្ងៃហ្នឹងអ្នកភូមិចោទប្រកាន់លោកថាលោកគឺជា<អ្នកនិពន្ធប្រលោមលោក ឬ>អ្នកប្រឌិតរឿង ឬមួយក៏យ៉ាងណា?

**ឆ៖** អ្នកភូមិនៅសព្វថ្ងៃហ្នឹងក៏ដោយ បើចង់ជាក់ស្ដែង បើថាខ្លាចខ្ញុំនិពន្ធរឿង សាកសួរតទៅទៀតសួរទៅ បើថាខ្ញុំនិពន្ធរឿង គេប្រាប់ថានិពន្ធរឿងហើយ។ បើខ្ញុំនេះ ខ្ញុំប្រាប់ជម្រាបលោកថាខ្ញុំនេះឆ្លងកាត់ពិតៗ ខ្ញុំ ហ៊ឹម ម៉ាន នេះ។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំលោកសាក្សី។ គឺពាក់ព័ន្ធទៅនឹងសក្ខីកម្មរបស់លោកបានឆ្លើយជូនតុលាការ ខាងតំណាងសហព្រះរាជអាជ្ញាបានសួរទៅលោក គឺនៅចន្លោះម៉ោង ១៤:៤៩, ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ និយាយអំពីការជម្លៀសជនជាតិចាមនៅម៉ោងបី<រសៀល គឺ>អ្នកភូមិពីភូមិអង្គរបាន ភូមិសាច់ស្ង <និងភូមិអន្ទង់ស> ហើយលោកបានឆ្លើយដូចតទៅថា "អ្នកភូមិទាំងអស់នោះស្លាប់អស់ហើយ ពីព្រោះថាម្នាក់ៗគេបញ្ជូនទៅឲ្យធ្វើការនៅការដ្ឋាន<សង់ទំនប់> ហើយប្រជាជនទាំងអស់នោះប្រហែលស្លាប់ដោយសារតែការធ្វើការងារយ៉ាងនេះឯង"។ ហេតុអ្វីបានជាលោកឆ្លើយអំពីការចាប់ខ្លួនជនជាតិចាម? <តើលោកចង់សំដៅថា ពួកគេត្រូវបានចាប់ខ្លួន> ហើយក្រោយមកថា គេបញ្ជូនទៅឲ្យធ្វើការនៅ<ការដ្ឋានសង់ទំនប់ ឬ>ការដ្ឋានការងារ។ តើលោកចង់បញ្ជាក់យ៉ាងម៉េច<ដែរ>?

[១០:៥៧:១៦]

**ឆ៖** ខ្ញុំសូមឆ្លើយ។ បញ្ជូនមួយចំនួនដែលទៅហ្នឹង អ្នកមួយចំនួនដែលទៅហ្នឹងមិនបានមកទេ ហើយអ្នកដែលបាននៅក្នុងភូមិហ្នឹងគេបញ្ជូនយកទៅធ្វើការដ្ឋាននៅផ្លូវលេខ៦ នេះ អ្នកហ្នឹងអ្នកដែលនៅក្នុងភូមិទេ។ រួចអ្នកដែលទៅៗហើយៗ បាទ ទៅហើយអ្នកនុ៎ង។ ទៅៗហើយៗ ទៅបាត់ខ្លួនទាល់សព្វថ្ងៃ

ហ្នឹង ឃើញមកវិញប៉ុន្មានចាស់ទេ ឃើញ តាសុះ មួយត្រឡប់មកវិញ។ ហើយអ្នកដែលទៅការដ្ឋាននេះ បញ្ជូនទៅការដ្ឋាននេះ អ្នកដែលនៅក្នុងភូមិ គេជ្រើសរើសរួច វាទៅៗ ៥០ភាគរយ នៅ៥០ភាគរយ។ ៥០ភាគរយហ្នឹងមិនបានមកទេ បានមកខ្លះ នៅសល់ មកថា សង្គ្រាជ សុះ នៅសាច់ស្ង – សង្គ្រាជ សុះ។ អ៊ីចឹងវាបាត់ទាំងអស់ហ្នឹងហើយ។ ហើយឥឡូវនៅតែ សង្គ្រាជ សុះ។ រួចអ្នកដែលទៅការដ្ឋានផ្លូវលេខ៦ នេះអ្នកហ្នឹងដែលនៅក្នុងភូមិ គេមិនឲ្យទៅទេ ហើយគេមិនឲ្យទៅទេ ហើយអ្នកហ្នឹងហើយដែលទៅការដ្ឋាននៅៗផ្លូវលេខ៦នេះ អ្នកហ្នឹងហើយទៅការដ្ឋានហ្នឹង។

**ស៖** ដូច្នេះ<តើ>ខ្ញុំយល់<ត្រឹមត្រូវ>ទេ<ដែលថា> នៅពេលដែលអ្នកភូមិចាមត្រូវបានគេប្រមូល<ក្នុងថ្ងៃដែលមានការដើរជាជួរ ហើយ>ត្រូវគេបញ្ជូនទៅការដ្ឋាន<>លើកទំនប់ជិតផ្លូវជាតិលេខ៦ទេ។ លោកនិយាយថាអ៊ីចឹងឬក៏យ៉ាងណា?

**ឆ៖** ផ្លូវ--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតបលោកៗ ម៉ាន កុំអាលទាន់ឆ្លើយតប!

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថាសំណួរនេះគឺមិនច្បាស់ទេ ពាក់ព័ន្ធនឹងរយៈកាលដែលបានកើតឡើងនោះ គឺអាចមានការភ័ន្តច្រឡំគ្នា<កាលពី១០ថ្ងៃមុន ពាក់ព័ន្ធនឹងសាក្សី គឺប្រហែលទាក់ទងនឹងពេលវេលា ប៉ុន្តែវាជាការចាំបាច់ដើម្បី>បំភ្លឺឲ្យបានច្បាស់ថា ពេលណា? <ពីព្រោះនៅក្នុងអង្គជំនុំជម្រះនេះ យើងកំពុងតែនិយាយពី>រឿងពីរផ្សេងគ្នា <គឺថា> មួយជាការបញ្ជូនទៅការដ្ឋានធ្វើការនៅជិតផ្លូវជាតិលេខ៦ និងមួយទៀតវា អាហ្នឹងវាខុសពីអ្វីដែល<គាត់បាននិយាយ>នៅវត្តអូរត្រកួន។ អ៊ីចឹង <ខ្ញុំគិតថា>គួរតែបែងចែករយៈកាលនិងហេតុការណ៍ពីរហ្នឹងឲ្យបានច្បាស់ <ដើម្បី>កុំឲ្យសាក្សីគាត់ស្ដាប់ទៅគាត់ភ័ន្តច្រឡំ ហើយធ្វើឲ្យគាត់និយាយផ្ទុយគ្នា<ត្រង់ចំណុចនេះ>។

[១១:00:00]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនឃើញភាពចម្រូងចម្រាស់នៅក្នុងចំណុចនេះទេ គឺថាចម្លើយដែលសាក្សីបានឆ្លើយគឺទាក់ទងទៅនឹងសំណួររបស់ខ្ញុំហើយ ហើយគាត់បានឆ្លើយ<យ៉ាងច្បាស់>ថា "ប្រជាជនទាំងអស់នោះស្លាប់អស់ហើយ ដោយសារតែគេបញ្ជូនទៅលើកទំនប់នៅ<ការដ្ឋានការងារ>នោះ។ អ៊ិចឹង ហើយបានជាខ្ញុំសួរ

បញ្ជាក់ទៅសាក្សីត្រង់ ចំណុចនេះ។ ខ្ញុំអាចសួររយៈពេលខុសៗគ្នាបានប៉ុន្តែសាក្សីគាត់ហាក់បីដូចមានភាពច្របូកច្របល់ទៅនឹងកាលបរិច្ឆេទ។ ដូច្នេះ យើងខ្ញុំយល់ឃើញថាការជំទាស់បែបនេះ គឺថាគួរតែច្រានចោល។

*(ចៅក្រមពិភាក្សាគ្នា)*

**ប្រធានអង្គជំនុំ៖**

បាទ ហើយសេចក្ដីជំទាស់របស់សហព្រះរាជអាជ្ញារងអន្តរជាតិលើសំណួរនេះគឺមានមូលហេតុសមស្រប។ មេធាវីគប្បីធ្វើការញែកឲ្យបានច្បាស់លាស់រវាងអង្គហេតុនេះដែលកើតឡើង ហើយនិងអង្គហេតុផ្សេងទៀតដែលកើតឡើងនៅ បញ្ជូនជនជាតិចាមទៅសំដៅវត្តអូរត្រកួន ព្រោះអង្គហេតុនេះមើលទៅដូចជាមានពេលវេលាខុសគ្នា ហើយការសួរបញ្ជាក់ពីមុនមិនបានកំណត់ពេលវេលាជាក់លាក់លើសំណួរពាក់ព័ន្ធនឹងអង្គហេតុចុងក្រោយនៃការបញ្ជូនជនជាតិចាមទៅធ្វើការងារនៅការដ្ឋានផ្លូវលេខ៦នេះទេ។ អ៊ីចឹង សូមញែកឲ្យបានច្បាស់លាស់ ជៀសវាងមានការភ័ន្តច្រឡំបង្វែរអង្គហេតុដែលបានសួរដេញដោលរួចហើយទៅទិសផ្សេង នាំឲ្យសាក្សីមានការឆ្លើយភ័ន្តច្រឡំ។ ដើមបណ្ដឹងរដ្ឋប្បវេណីអាចឆ្លើយភ័ន្តច្រឡំ ដោយសារមិនកំណត់រយៈពេលច្បាស់លាស់។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនច្បាស់នោះទេ ប៉ុន្តែទំនប់១មករា គឺយើងនិយាយយ៉ាងវែងក្នុងឆ្នាំ១៩៧៧ ហើយក៏វា<ជារយៈពេលដូចគ្នាដែលយើងពិភាក្សា>ទាក់ទងទៅនឹងវត្តអូរត្រកួន។ តែយ៉ាងណាខ្ញុំរៀបសំណួរឡើងវិញ។

[១១:០២:៣៤]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី កាលពីពីរសប្ដាហ៍កន្លងទៅនោះ គឺលោកបានឆ្លើយថា សូមដកស្រង់៖ “អ្នកទាំងអស់ស្លាប់អស់ហើយ ដោយសារម្នាក់ៗគេបញ្ជូន គ្រប់គ្នាគេបញ្ជូនទៅការដ្ឋាន<លើកទំនប់>។ ដូច្នេះ ប្រជាជនទាំងអស់នេះប្រហែលជាស្លាប់ដោយសារតែពលកម្មនេះឯង ហើយអ្នកដែលគេចាប់ជាមួយអ្នក<ផ្សេងទៀត ហើយអ្នក>ទាំងនេះ<គឺ>ស្លាប់<ទាំងអស់>។ <>ប្រជាជនចាម<ដែល>មកពីភូមិសាច់ស្វ <អន្ទង់ស> អង្គរបាន គឺថាធ្លាប់ធ្វើការជាមួយគ្នាស្លាប់អស់ហើយ”។ តើ<លោកចង់សំដៅ>អំឡុងពេលមួយណាដែរ នៅពេលដែលលោកឆ្លើយនៅសក្ខីកម្មដែលខ្ញុំលើកអម្បាញ់មិញនេះ?

**លោក ហ៊ឹម ម៉ាន៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** នៅពេលដែលថា ដែលគេ ដែលខ្ញុំដឹងថា គេយកទៅខ្ញុំទៅសម្លាប់ហ្នឹងហើយ បានខ្ញុំដឹងថា បងប្អូននៅអន្ទង់សោម អង្គរបានហ្នឹង ក៏វាធ្វើជាមួយគ្នា ធ្វើជាមួយគ្នាជីកដីនោះ បានដែលយកទៅហ្នឹង ខ្ញុំដឹង។ ហើយយកទាំងខ្លួនខ្ញុំទៅទៀតហ្នឹង បានខ្ញុំដឹងហ្នឹង។

**ស៖** ប៉ុន្តែ លោកបាននិយាយ<ម្តងទៀត>យ៉ាងច្បាស់លាស់អំពីប្រជាជនដែលគេបញ្ជូនទៅឱ្យធ្វើការនៅ ការដ្ឋាន<លើកទំនប់នោះ>។ "ដូច្នេះ ប្រជាជនទាំងអស់នេះប្រហែលជាស្លាប់ដោយសារតែពលកម្ម។" នៅពេលដែលលោកថាអ្នកទាំងអស់នោះប្រហែលជាស្លាប់អស់ហើយ ប្រហែលជាស្លាប់ដោយសារពលកម្ម។ តើលោកចង់និយាយថាម៉េចចំណុចនេះ?

**ឆ៖** បាទ ខ្ញុំសូមឆ្លើយថា ខ្ញុំហ្នឹងក៏ស្មានដែរទេ ព្រោះបាត់មនុស្សហ្នឹងអស់។ វាបាត់មនុស្សដែលបញ្ជូនទៅហ្នឹង ព្រោះបញ្ជូនទៅឃើញសេសសល់មកវិញសព្វថ្ងៃនេះ ឈ្មោះ តាសង្គ្រាជ សុះ – សង្គ្រាជ សុះ មេវត្តហ្នឹង បាទ។ សង្គ្រាជ សុះ ភូមិសាច់ស្វ បាទ។ បើអស់មនុស្សហើយ ខ្ញុំសន្និដ្ឋានថាអស់ហើយ បាទ ងាប់អស់ហើយ។ ហើយមិនដឹងជាទៅត្រង់ណាទៀត ខ្ញុំមិនដឹងទេ ប៉ុន្តែខ្ញុំដឹងថា ស្មានខ្លួនខ្ញុំថា ងាប់អស់ នៅសល់ តាសុះ – ឈ្មោះ សុះ – យូសុះ – ស្រេន យូសុះ បាទ។ ទាល់តែងាប់អស់មិនអស់ហ្នឹង តាសុះ អាចដឹងថា គាត់បញ្ជូនគាត់នៅសល់ប៉ុន្មាន ប៉ុនគាត់នៅទេសព្វថ្ងៃនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ដោយសារតែពេលវេលា អ៊ីចឹងខ្ញុំសូមបញ្ចប់ការសួររបស់ខ្ញុំត្រឹមនេះ។

សូមអរគុណ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ។ តទៅនេះ ផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តី ខៀវ សំផន។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរ លោក ហ៊ីម ម៉ាន។ ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន។ ខ្ញុំសួរសំណួរបន្ថែមទៅលោក ក្នុងឋានៈខ្ញុំជាមេធាវីរបស់គាត់។ ជាបឋម ខ្ញុំចង់សួរលោកនូវសំណួរមួយចំនួន ពាក់ព័ន្ធទៅនឹងឆ្នាំ១៩៧៥ លោកបាននិយាយជាមួយលោកមេធាវី កូប៉េ និយាយអំពីការបះបោរនៅកោះផល។ លោកបញ្ជាក់ថាលោកបានស្តាប់ឮគេនិយាយអំពីរឿងនេះ។

អ៊ីចឹងនៅឆ្នាំ៧៥ នៅពេលដែលលោកឮគេនិយាយអំពីការបះបោរនៅកោះផលហ្នឹង លោកនៅស្រុកក្រូចឆ្មារមែនទេ?

**លោក ហ៊ឹម ម៉ាន៖**

**ឆ៖** ខ្ញុំសូមឆ្លើយ ខ្ញុំមិនៗមែននៅស្រុកក្រូចឆ្មារទេ ខ្ញុំនៅភូមិសាច់ស្ងួរហ្នឹងហើយ ស្រុកពាមជីកងហ្នឹងហើយ។ ហើយខ្ញុំគ្រាន់តែជីកដីប៉ុណ្ណឹងទេ ប៉ុន្តែឮគេនិយាយថា ព្រោងព្រាត តាំងកាលនុ៎ង តាំងនៅជីកដី មនុស្សនិយាយថាក្រូចឆ្មារនេះ សម្បើម បះបោរសម្បើមណាស់ គ្រាន់តែឮតាមចចាមអារាមទេ ឮចចាមអារាម។ រួចអ្នកជីកដីហ្នឹង មួយទៅមួយៗ វាខ្ទរខ្ទារអស់ទៅ។

**ស៖** អ្នកជីកដីជាមួយលោកហ្នឹង សុទ្ធតែជាចាម ឬក៏ជាខ្មែរ?

**ឆ៖** អ្នកជីកដីហ្នឹង វាចម្រុះៗមានចាម មានខ្មែរ អ្នកជីកដីហ្នឹង រួចចុះខ្មែរក្រហមហ្នឹង គេៗអ្នកយាមហ្នឹង គេយាមនៅក្បែរហ្នឹង អត់ហ៊ានមើលមុខគេទេ បាទ។

[១១:០៨:២៤]

**ស៖** ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ <ឬពេលក្រោយមកទៀត> តើលោកធ្លាប់ជួបអ្នកមកពីស្រុកក្រូចឆ្មារទេ<? ឬអ្នកដែលរស់នៅក្រូចឆ្មារ>នៅពេលដែលនិយាយអំពីការបះបោរហ្នឹង<>?

**ឆ៖** មិនៗដែលជួបទេ ក៏ប៉ុន្តែគ្រាន់តែឮ បើពេញភូមិ ពេញស្រុកអ៊ីចឹង បាទ។ រួចតែឮៗអ៊ីចឹងទៅ វាស្ងាត់ទៅ ឮថាក្រោយមក ធ្វើបាបចាមហ្នឹងធ្ងន់ធ្ងរហ្នឹង បាទ។ អ៊ីចឹងខ្ញុំចេះតែឆ្ងល់ៗបាទ។ ធ្វើបាបចាមអីក៏ខ្លាំងម្ល៉េះ វាទៅជាចាមខ្លាំងទី១ទៅវិញ។ អ៊ីចឹងខ្ញុំរឹតតែឆ្ងល់ទៅទៀត ត្រឹមម៉ាឆ្ងល់ប៉ុណ្ណឹងបាទ រឿងអាថ៌កំបាំងរបស់គេខ្ញុំមិនដឹងទេ ប៉ុន្តែបើឮខ្ញុំឆ្ងល់ៗ ឆ្ងល់ បាទ ឆ្ងល់ទាល់ៗសព្វថ្ងៃហ្នឹង បាទ ក៏ព្រោះតែអារឿងអាថ៌កំបាំងអស់ហ្នឹង គេមិនឲ្យដឹង ប៉ុន្តែឮបាន។ មិនដឹង មិនអាចដឹងរឿងអាថ៌កំបាំងរបស់គេបានទេ។

**ស៖** លោក អ៊ីសា ឧស្មាន បានសម្ភាសលោក អំពីបទពិសោធន៍ជីវិតរបស់លោក។ នៅក្នុងពេលសម្ភាសនោះ តើលោកមានបាននិយាយអំពីការបះបោរនៅកោះផលទេ? លោកមានចាំថា លោកបាននិយាយអំពីរឿងបះបោរនៅកោះផលហ្នឹងជាមួយ អ៊ីសា ឧស្មាន ទេ?

[១១:១០:១០]

**ឆ៖** បាទ ខ្ញុំបានមាននិយាយ គាត់មកសម្ភាសខ្ញុំមែន។ ខ្ញុំនិយាយបន្តិចដែរកាលនុ៎ង និយាយថាគាត់សួរថារឿងកោះផលនេះ គាត់សួរទៅ សួរ ខ្ញុំក៏ឆ្លើយប្រាប់ថា ខ្ញុំឮទៅតាមគេតាមអ្នកភូមិដូចជាខ្ញុំ

ជម្រាបអំមិញហ្នឹង ថាគេព័ទ្ធកោះផលសម្បើមណាស់ ព័ទ្ធៗមិនដាច់ទេ ហើយពួកចាមហ្នឹងរឹងណាស់។ អ៊ីចឹង រឹងណាស់។ អ៊ីចឹងថ្ងៃមួយ គេចាប់សង្គ្រាជ ចាប់គេហៅថាគ្រូ ថាគ្រូចាមទៅចុះ គេចាប់បានមក ដែលធ្លាប់នៅរៀនសូត្រនៅក្នុងភូមិហ្នឹង។ ហើយចាប់មក ខ្មែរក្រហមចាប់មកបាន គេឲ្យៗតាគ្រូហ្នឹង តាសង្គ្រាជហ្នឹងចុះ គេឲ្យមកស្រែមីក្រូ ថាឲ្យពួកចាមទាំងអស់ហ្នឹងទម្លាក់ដាវ ទម្លាក់ព្រនង់ចុះ នេះគាត់នេះជាគ្រូរបស់ឯងហើយ។ អ៊ីចឹងបានពេលហ្នឹង បានជាចាមទាំងអស់នៅក្នុងភូមិកោះផលហ្នឹង គេទម្លាក់អស់ មកសារភាព ដោយសារគ្រូ គេឲ្យឡើងមកហើយ កុំតទល់។ ហើយបានជាបរាជ័យកន្លែងហ្នឹងទៅ បរាជ័យកន្លែងហ្នឹងទៅ ហ្នឹងអ៊ីចឹង។ ក្រោយមកខ្ញុំឮអ៊ីចឹងដែរថា រលាយទៅហើយ គេហៅថាកោះផល វាក្លាយទៅជា កោះផេះៗ។ អ៊ីចឹងចាមក្រោយមក ចាមដាក់ខ្មាំងទី១។ ខ្មាំងទី១ហ្នឹងដោយសារខ្ញុំឮអាហ្នឹងមករួច ឮអាហ្នឹងមករួច ចុះមកយ៉ាប់នៅចាមនៅក្នុភូមិយ៉ាប់តែម្ដង យ៉ាប់ខ្មាំងទី១។ ខ្មែរក្រហមប្រយ័ត្នៗរឿងចាមហ្នឹង ដាក់ខ្មាំងទី១។ អ៊ីចឹងខ្ញុំចម្ងល់កន្លែងហ្នឹង នៅឆ្ងល់ទាល់សព្វថ្ងៃនេះ។ បើអស់កោះផលវារលាយហើយ គេខ្លាចចាមបះបោរដូចកោះផងហ្នឹង បាទ បានជាចាមរឹតតែយ៉ាប់ទៅៗ។

**ស៖** លោកបាននិយាយអំពីកោះផល ដូច្នេះក្រៅពីកោះផលនេះ លោកដឹងមានការបះបោរនៅភូមិឃុំណាផ្សេងទៀតនៅក្នុងស្រុកក្រូចឆ្មារហ្នឹងទេ លោកធ្លាប់<>ឮគេនិយាយអំពីកោះផលនោះ<ដែរ ឬទេ>?

[១១:១៣:១៤]

**ឆ៖** ខ្ញុំដូចជាមិនឮអីទេ ឮតែកោះផលមួយកន្លែងហ្នឹង។ ឮតែកោះផលមួយកន្លែងហ្នឹង។ ក្រោយ ខ្ញុំមកហ្នឹង វាចេះតែយ៉ាប់ៗក្នុងភូមិ មើលតែភូមិខ្លួនឯងហ្នឹង មើលមកមិនបាច់ថាខ្ញុំហ្នឹងអ្នកធ្វើមេធំទេ កាលនោះ ខ្ញុំអ្នកជីកដីទេ គឺជីកដីមកដេកមកពួនទៅ ឮតែនិយាយអ៊ីចេះអ៊ីចុះ ឮថាខ្លាចអ៊ីចេះអ៊ីចុះ។ ឮអាពាក្យមិនស្រួលមក នាំគ្នាភ័យៗខ្លាចតែងាប់ហ្នឹង។

**ស៖** ឥឡូវនេះ ខ្ញុំចូលទៅនិយាយអំពីរយៈកាលផ្សេងទៀត គឺជារយៈកាលដែលលោកនិយាយអំពីការចាប់ខ្លួនជនជាតិចាមនៅសាច់ស្វ។ ពាក់ព័ន្ធនឹងកាលបរិច្ឆេទ លោកបានឆ្លើយថា លោកមិនចាំច្បាស់អំពីកាលបរិច្ឆេទដែលគេបំបែកជនជាតិចាមនៅភូមិផ្សេងៗទេ ក៏ប៉ុន្តែលោកបាននិយាយថា លោកចាំច្បាស់អំពីពេលវេលាដែលលោកបានរត់គេច ហើយលាក់ខ្លួននៅក្នុងថ្លុក។ កាលពីព្រឹកមិញនេះ លោកក៏និយាយអំពីចំណុចនេះដែរជាមួយនឹងលោកមេធាវី កូប៉េ។ អ៊ីចឹងខ្ញុំចង់ដឹងថា តើលោកចាំថាពេលដែល

លោកលាក់ខ្លួននៅក្នុងថ្លុក<>ហ្នឹង លោកចាំថានៅឆ្នាំណាទេ?

**ឆ៖** ខ្ញុំនៅចាំថា ឆ្នាំដែលដាច់ហ្នឹង បាទ ឆ្នាំដាច់ហ្នឹងហើយ ដែលខ្ញុំនៅលាក់ក្នុងបឹងហ្នឹងនោះ។ មិនដឹងឆ្នាំប៉ុន្មាន វា១៩៧៨ ក៏មិនដឹង ៧៩ មិនដឹង។ ខ្ញុំនៅក្នុងបឹងហ្នឹង គឺថាខ្ញុំស្មានទេ។ ពេលហ្នឹងដែលខ្ញុំនៅក្នុងបឹងហ្នឹង។ ដូច ៧៨ មិនដឹង។ ឆ្នាំដាច់ហ្នឹង និយាយចំតែម្តងទៅ ដែលខ្ញុំទៅពួនហ្នឹង។ ព្រោះខ្ញុំមកវិញដាច់ ប្រទូស្តប្រទាំងដាច់។

**ស៖** តើនៅក្នុងឆ្នាំ១៩៧៨ហ្នឹង ចាមនិងខ្មែរ ស្លៀកខោអាវដូចគ្នាទេ? គឺពេលនុ៎ង <>គេហាមឃាត់អត់ឲ្យស្លៀកសម្លៀកបំពាក់ប្រពៃណីចាមអីទៀតហើយ គឺចាមក៏ស្លៀកពាក់ដូចខ្មែរដែរ មែនទេ?

[១១:១៦:២៤]

**ឆ៖** ពេលមិនដាច់ហ្នឹង ស្លៀកពាក់មិនបានទេ។ ស្លៀកពាក់ដូចថា ឲ្យតែខ្មែរគឺបាន។ បើស្លៀកពាក់ដូចចាមហ្នឹង អត់បានទេ។ ទាល់ដូចខាងបងប្អូនខ្មែរហ្នឹង គេកាត់សក់ គេឲ្យកាត់សក់ដូចបងប្អូនខ្មែរអ៊ីចឹង។ រួចគេមិនឲ្យយើងថ្វាយបង្គំជ្រូកដែលយើង គេមិនឲ្យស៊ីជ្រូក គេឲ្យស៊ីជ្រូក ស៊ីទៅ។ ថ្វាយបង្គំចាមធ្លាប់ថ្វាយបង្គំ គេមិនឲ្យយើងមិនថ្វាយទេ បើគេមិនឲ្យយើងថ្វាយ យើងលបថ្វាយ គង់តែមានម៉ោងបាត់ខ្លួនទេបាទ។

**ស៖** តើលោកចាំទេថាពេលគេចាប់ខ្លួនលោកហ្នឹង ជនជាតិចាមទាំងអស់ដែលលោកបានឃើញចាប់ខ្លួនហ្នឹង គឺសុទ្ធតែស្លៀកពាក់ខោអាវដូចជនជាតិខ្មែរទាំងអស់ មែនទេ ដែលគេចាប់នោះ?

**ឆ៖** បាទ ទាំងអស់ ស្លៀក -- សក់ហ្នឹងកាត់ខ្លីទាំងអស់ បាទ។ របៀបរបបខ្មែរទាំងអស់ គេថាមានជាតិតែមួយទេ គ្មានចាមទេ គ្មានខ្មែរទេ មានជាតិតែមួយ។ ដល់ពេលហ្នឹង យកទៅសម្លាប់ហ្នឹង ក៏ទៅទាំងសក់ខ្លីហ្នឹងដែរ។ ទៅថា អត់មានទូលក្រមា ទូលអីទេ។

**ស៖** លោកបានឆ្លើយថា គេប្រាប់ថា យើងសុទ្ធតែជនជាតិខ្មែរទាំងអស់ គឺជាតិតែមួយ។ លោកអាចបញ្ជាក់បានទេថា "គេ" ហ្នឹង ជាអ្នកណា ហើយលោកស្តាប់ឮពាក្យហ្នឹង នៅពេលណាដែរ?

[១១:១៨:៥០]

**ឆ៖** រឿងពាក្យហ្នឹង មិនដឹងជាឈ្មោះ"ក", ឈ្មោះ "ខ" ខ្ញុំមិនដឹងទេ ប៉ុន្តែខ្ញុំមនុស្សខ្ញុំនេះ នៅជីកដី ពលកម្ម មនុស្សពលកម្ម បាទ មនុស្សពលកម្ម។ ដែលគ្រាន់តែឮ ប្រជុំត្រង់ណាអាចឮ។ ព្រោះខ្ញុំមនុស្សពលកម្ម តែខ្ញុំធ្វើពលកម្មមួយ ខ្ញុំមានដើរទៅខាងណេះខាងណោះក្នុងភូមិបាន។ អ៊ីចឹង ខ្ញុំអាចឮពាសវាលបាន អាចឮពាសវាលបាន។ ហើយរួចចុះ បើតឹងទៅៗ បងប្អូនខ្ញុំអត់ហ៊ានទូលក្រមាទេ។ រឿង

ដោយសារគេឮមកហ្នឹងហើយ បានគេអត់ហ៊ានទូលក្រមាទេ។ អត់ហ៊ានថ្វាយបង្គំទេ។ ថ្វាយបង្គំ យប់លប លបថ្វាយបង្គំយប់។ ថ្វាយបាន ប៉ុន្តែលបថ្វាយកុំឲ្យខ្មែរក្រហមដឹង បាន។

**ស៖** ពេលគេចាប់ខ្លួនលោក តើនរណាជាមេផ្ទាល់របស់លោក?

**ឆ៖** ពេលគេចាប់ខ្លួនខ្ញុំៗទៅហ្នឹង អ្នកណាមេៗហ្នឹង ខ្ញុំភ្លេចភ្លាំងអស់ហើយ បាទ ព្រោះគេដកទៅជាតែលតោលកាលហ្នឹង ខ្ញុំនៅ ពីព្រោះមេកោយខ្ញុំ និយាយពីចាប់ហ្នឹង អ្នកដែលកម្លាំងៗជីកដីហ្នឹងវាចាមដែរ វារណាត់រណែងឈ្មោះអីទេ ខ្ញុំភ្លេចឈ្មោះទៅទៀត អ្នកដែលៗប្រធានក្រុមខ្ញុំហ្នឹង។ បាទ គេចាប់ ដែលគេចាប់ហ្នឹង ខ្មែរក្រហមមកចាប់ផ្ទាល់តែម្តង មកចាប់ផ្ទាល់ ខ្ញុំ អីចឹងខ្ញុំដឹងវាៗធ្វើឋានៈអីៗ ខ្ញុំមិនដឹងទេ ខ្ញុំដឹងតែពីរឿងខ្ញុំងាប់ ខ្ញុំគេមកចាប់ទៅងាប់ហើយ។

**ស៖** នៅក្នុងឯកសារទម្រង់បែបបទ<ពាក់ព័ន្ធនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី> របស់លោកគឺ <E3/4706>, ERN ជាភាសាអង់គ្លេសគឺ 00417865, ERN ជាភាសាខ្មែរ 00369053, មិនមាន ERN ជាភាសាបារាំងទេ។ លោកនិយាយមុនពេលចប់របបខ្មែរក្រហម លោកថាមានបញ្ហាមកពីថ្នាក់លើ។ លោកសំដៅទៅលើអ្នកណា នៅពេលដែលលោកថា "ថ្នាក់លើ" នេះ ហើយ <នរណាជាអ្នកផ្តល់ព័ត៌មានឲ្យលោក ហើយ>ព័ត៌មានហ្នឹងលោកបានមកពីណាដែលថាមានបញ្ហាពីថ្នាក់លើហ្នឹង?

**ឆ៖** នៅតាមភូមិ ក្រោយពីខ្ញុំរួចពីការងារ ឬមួយខ្ញុំនៅការងារ ឮប្រជុំនីមួយៗគេនិយាយតែពីរឿងថ្នាក់លើ មិនដឹងថ្នាក់លើមួយណា ខ្ញុំក៏មិនដឹងដែរ ថ្នាក់លើមួយណា នៅជំនាន់ខ្មែរក្រហម ជំនាន់ថ្នាក់លើៗ អង្គការថ្នាក់លើ។ ថ្នាក់លើ "ក", ថ្នាក់លើ "ខ" មិនបានដឹងទេអស់លោក។ ខ្ញុំមិនបានដឹងថាឈ្មោះអីៗ ថ្នាក់លើនៅត្រង់ណាអត់ដឹង ប៉ុន្តែឮថាថ្នាក់លើ។

[១១:២៣:២០]

**ស៖** ប្រសិនបើខ្ញុំស្តាប់មិនច្រឡំទេ គឺមិនមាននរណាម្នាក់ពន្យល់ប្រាប់លោកថា ថ្នាក់លើហ្នឹងជានរណាទេ ហើយលោកក៏មិនដែលធ្លាប់ស្តាប់ឮឈ្មោះ អ្នកណាជាអង្គការហ្នឹងដែរ គឺជាពាក្យគេហៅៗជាទូទៅអីចឹង អង្គការថ្នាក់លើអីចឹង តែលោកអត់ស្គាល់ឈ្មោះមនុស្សទេ មែនទេ?

**ឆ៖** បាទ ខ្ញុំអត់ស្គាល់ឈ្មោះមនុស្សទេ បាទ ឮថាឮគេថ្នាក់លើៗ ដូចថា ប្រជុំត្រង់ណា ខ្ញុំអ្នកកម្លាំងជីកដីហ្នឹងឮត្រង់ណា សុទ្ធតែអង្គការថ្នាក់លើ។ បាទ មិនដឹងលើហ្នឹងឈ្មោះអីៗ ខ្ញុំអត់ដឹងទេ ខ្ញុំឮប៉ុណ្ណឹងដែរ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំដឹងថាពេលវេលាគឺខើចណាស់ទៅហើយ ។ប្រសិនបើគាត់ចង់ធ្វើសេចក្ដីថ្លែងទុក្ខសោករបស់គាត់ ខ្ញុំអាចឈប់នៅពេលនេះបានលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ លោក ហ៊ីម ម៉ាន ជាចុងក្រោយនេះលោកអាចថ្លែងរៀបរាប់ប្រាប់ដល់អង្គសវនាការស្ដាប់អំពីរឿងហេតុទំនាក់ទំនងទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ដែលបានប៉ះពាល់ចំពោះលោកក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលនាំឱ្យលោកតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាមទារសំណងជំងឺនិងជាសម្ភារភាពពីជនជាប់ចោទ ហើយនិងពីស្ថានភាពព្យសនកម្មដែលមានចំពោះលោក ជាអាទិ៍ ការខូចខាតរាងកាយ សម្ភារៈ ផ្លូវចិត្ត និងផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋដោយជាព្យសនកម្មផ្ទាល់ខ្លួន និងបានកើតមានរហូតដល់បច្ចុប្បន្ននេះ ហើយប្រសិនបើលោកមានបំណងធ្វើដូច្នេះ។ សូមអញ្ជើញបាទ!

[១១:៣៥:៥៩]

**លោក ហ៊ីម ម៉ាន៖**

ខ្ញុំហ្នឹង ក្នុងចិត្តហ្នឹង គឺវាសព្វថ្ងៃនេះលើខ្លួនខ្ញុំដែលវារ៉ាំរ៉ៃតាំងពីនុំងមកហ្នឹង គឺថាមានរោគ មានគាសឹងថា ចង់កើតមនុស្សមិនកើតតែម្ដង គឺហៅថា អស់សង្ឃឹម តែថាទុក្ខសោកខ្ញុំនេះ វាអស់តាំងពីបងអស់តាំងប្អូនសាច់លោហិតទាំងអស់។ តាំងពីទ្រព្យរបស់ ទ្រព្យអី ខ្ញុំអត់និយាយទេរឿងទ្រព្យរបស់ហ្នឹង និយាយតែពីរឿងបងប្អូនសាច់សាលោហិតខ្ញុំ រលីងហើយ ព្រោះខ្ញុំនៅនេះ សព្វថ្ងៃនេះសឹងថា ងាប់ល្អជាង បាទ គ្មានអ្វីប្រៀបបានទេនៅក្នុងចិត្តខ្ញុំនេះ សព្វថ្ងៃនេះសឹងថា ដូចថាមនុស្សឆ្កួតទៅហើយ លែងសង្ឃឹមអី បាទ រួចថាបានសង្ឃឹមត្រង់កន្លែងណា គឺថាសំណាងល្អដែលអ្នកមានគុណមកជួយទាន់ អស់លោកសុទ្ធតែអ្នកមានគុណហើយ ទាំងអស់គ្នាដែលមកជួយទាន់បាទ កុំអីងាប់អស់ហើយចាមខ្មែរយើងនោះ។ សំណាងល្អបានអស់លោកមកជួយទាន់ អ្នកមានបុណ្យ។ រួចខ្ញុំមិនចេះរ៉ាយរ៉ាប់ ព្រោះខ្ញុំមនុស្សខ្ញុំមនុស្សអក្ខរកម្មទេអស់លោកអើយ ព្រោះខ្ញុំភ្លេចភ្លាំងអស់ហើយ។

វាគ្មានអីក្បោះក្បាយទេ ព្រោះខ្ញុំអត់ដែលរៀបរាប់ក្បាយហ្នឹង ព្រោះវាថា ខ្ញុំសង្ខេបតែម្ដងទៅថា វាដូចជាមនុស្សថា គ្មានសង្ឃឹមអីទេ សព្វថ្ងៃហ្នឹងវាដូចជាមនុស្សឆ្កួតទៅហើយហ្នឹង វាអស់រលីង ស្មារតីរ៉ាំរ៉ៃតាំងពីនុំងមក។ មនុស្សមានសង្ឃឹមអីទៀតបើវាអស់ពូជអម្បូរអស់ទៅហើយ។ អស់ពូជអម្បូរ អស់

សាច់ញាតិរលីងទៅក្នុងរណ្ដៅអស់ហើយ។ ខ្ញុំគ្មានអីរ៉ាយរ៉ាប់ច្រើនទេ ពីព្រោះថាលោកដឹងហើយ រឿងរ៉ាវទាំងអស់ហ្នឹង។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអរគុណលោក ហ៊ឹម ម៉ាន ការស្ដាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីបានដល់ទីបញ្ចប់ហើយ។ ហើយអង្គជំនុំជម្រះសូមអរគុណចំពោះលោកដែលបានមកផ្ដល់សក្ខីកម្ម ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្ដីនេះ។ ហើយឥឡូវនេះវត្តមានរបស់លោកនៅ អ.វ.ត.ក លែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ សូមលោកជួបតែសំណាងល្អ ហើយបានសេចក្ដីសុខសេចក្ដីចម្រើន។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សីនិងអ្នកជំនាញក្នុងការជូនលោក ហ៊ឹម ម៉ាន វិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។

ហើយនៅរសៀលនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-270 ហើយឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយនិងសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំនៅខាងក្រោមសាលសវនាការ និងឲ្យនាំគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៣០ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:០៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយបន្តទៅនេះ អង្គជំនុំជម្រះធ្វើ

សវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-270 ហើយមុននឹងអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីរូបនេះឲ្យចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ ទី១ គឺជម្រាបភាគីថា ក្នុងការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីរូបនេះនឹងមានវត្តមានកញ្ញា សាន់ កល្យាណ បុគ្គលិកអង្គភាពគាំពារសាក្សី និងអ្នកជំនាញអង្គុយអមដើមបណ្តឹងរដ្ឋប្បវេណីរូបនេះក្នុងរយៈពេលនៃគាត់ផ្តល់សក្ខីកម្ម។

ហើយទី២ សូមជម្រាបជូនភាគីជ្រាបថា កាលបរិច្ឆេទថានឹងស្តាប់សក្ខីកម្មសាក្សីមួយរូប 2-TCW-828 នៅថ្ងៃស្អែកនោះ -- 928 -- 2-TCW-928 នៅថ្ងៃស្អែកនោះ គឺត្រូវអាក់ខាន ហើយជំនួសដោយការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-845 វិញ ដោយសារមូលហេតុសាក្សី 2-TCW-928 មានជំងឺមិនអាចមកផ្តល់សក្ខីកម្មបាននៅថ្ងៃស្អែក។ ហើយកាលបរិច្ឆេទស្តាប់សក្ខីកម្មសាក្សីរូបនេះ អង្គជំនុំជម្រះនឹងជម្រាបជូនភាគីនៅពេលក្រោយ។

មន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណី រួមទាំងបុគ្គលិកអង្គភាពគាំពារសាក្សី និងអ្នកជំនាញមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីដើមបណ្តឹងរដ្ឋប្បវេណី តើលោកស្រីឈ្មោះអី?

**លោកស្រី នោ សាទះ៖**

**ឆ៖** ខ្ញុំឈ្មោះ នោ សាទះ។

**ស៖** អរគុណលោកស្រី នោ សាទះ។ តើលោកស្រីកើតនៅថ្ងៃខែឆ្នាំណា? លោកស្រីចាំទេ?

**ឆ៖** ខ្ញុំអត់ចាំទេ កើតថ្ងៃខែ ខ្ញុំអត់ចាំទេ។

**ស៖** ឥឡូវនេះលោកស្រីអាយុប៉ុន្មានឆ្នាំ?

**ឆ៖** អាយុ៥៧ឆ្នាំ។

**ស៖** អរគុណ។ តើលោកស្រីមានទីកន្លែងកំណើតនៅទីកន្លែងណា?

**ឆ៖** នៅស្វាយឃ្លាំង នៅស្រុកក្រូចឆ្មារ ឃុំស្វាយឃ្លាំង ភូមិស្វាយឃ្លាំង ខេត្តកំពង់ចាមកាលនោះ ឥឡូវគេប្រែប្រួលមកនៅត្បូងឃ្មុំ។ គេដាក់ត្បូងឃ្មុំវិញហើយឥឡូវនេះ។

**សៈ** ចុះទីលំនៅបច្ចុប្បន្នតើលោកស្រីរស់នៅទីកន្លែងណា?

**ឆៈ** រស់នៅបច្ចុប្បន្ន ខ្ញុំនៅ នៅឯស្វាយឃ្លាំងហ្នឹងហើយ ប៉ុន្តែដល់ពេលឆ្នាំ៧៥ ហ្នឹងគេបះបោរទៅនៅស្វាយឃ្លាំងហ្នឹង គេជម្លៀសខ្ញុំទៅនៅខ្សាច់ប្រឆេះលើ។

[១៣:៣៨:១០]

**សៈ** កុំអាលទាន់ យើងសួរតែសព្វថ្ងៃទេ ឥឡូវនេះ តើលោកស្រីរស់នៅទីកន្លែងណា? នៅភូមិអី? ឃុំអី? ស្រុកអី?

**ឆៈ** ខ្ញុំនៅភូមិស្វាយឃ្លាំង នៅឃុំស្វាយឃ្លាំងដែរ ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ។

**សៈ** អរគុណ។ តើឪពុកបង្កើតរបស់លោកស្រីឈ្មោះអី? ហើយម្តាយបង្កើតរបស់លោកស្រីគាត់ឈ្មោះអី?

**ឆៈ** ឪពុកខ្ញុំឈ្មោះ ស្មះ នោ។ ម្តាយខ្ញុំឈ្មោះ ទ្រេស ម៉ែសំ។

**សៈ** ចុះប្តីរបស់លោកស្រីឈ្មោះអី? ហើយលោកស្រីមានកូនប៉ុន្មាននាក់?

**ឆៈ** ប្តីខ្ញុំឈ្មោះ ស្លេស ម៉ានមីន។ កូនខ្ញុំ ប្រាំបីនាក់នៅរាល់ថ្ងៃនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយអង្គជំនុំជម្រះសូមជម្រាបជូនលោកស្រីថា ជាចុងក្រោយបង្អស់នៃការផ្តល់ចម្លើយរបស់លោកស្រីនៅក្នុងនាមលោកស្រីជាដើមបណ្តឹងរដ្ឋប្បវេណី លោកស្រីមានសិទ្ធិថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលកើតមានចំពោះលោកស្រីក្នុងរបបកម្ពុជាប្រជាធិបតេយ្យប្រសិនបើលោកស្រីមានបំណងធ្វើដូច្នេះ។ ហើយអនុវត្តតាមបទប្បញ្ញត្តិនៃវិធាន ៩១ ស្ទួននៃវិធានផ្ទៃក្នុង អ.វ.ត.ក. អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្ប-វេណីសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះមុនភាគីដទៃទៀតនៃរឿងក្តី។ ដើមបណ្តឹងរដ្ឋប្បវេណីរួមទាំងសហព្រះរាជអាជ្ញាមានពេលពីរវគ្គនៃថ្ងៃសវនាការនៅក្នុងការសួរដេញដោលសាក្សីរូបនេះ។ សូមអញ្ជើញ!

[១៣:៤០:១០]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងភាគី សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ នេះ មេធាវីនាំមុខ សូមប្រគល់សិទ្ធិនៅក្នុងការសួរជូនលោកមេធាវី ឡោ ជុនធី ហើយ

ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ អាចនឹងបន្ថែមសំណួរមួយចំនួនក្នុងករណីចាំបាច់។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**លោក ឡោ ជុនធី៖**

បាទ អរគុណ លោកប្រធាន។ ដំបូង ខ្ញុំបាទសូមគោរពអង្គជំនុំជម្រះទាំងមូល សូមគោរពភាគីផងដែរ។ នៅពេលនេះ ខ្ញុំបាទ ឡោ ជុនធី ដែលជាមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងជាមេធាវីមកពីអង្គការជំនួយផ្នែកច្បាប់នៅកម្ពុជា។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** នៅពេលនេះ ខ្ញុំបាទសូមជម្រាបសួរទៅលោកស្រី នោ សាទះ។ នៅពេលនេះ អំពីអង្គហេតុដែលលោកស្រីបានជួបប្រទះ នៅក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដែលលោកស្រីបានជួបប្រទះនៅក្នុងរយៈកាលនោះ។ ជាដំបូង ខ្ញុំបាទជម្រាបសួរថា តើលោកស្រី កាលពីមុនឆ្នាំ១៩៧៥ នៅកន្លែងណាដែរ?

**លោកស្រី នោ សាទះ៖**

**ឆ៖** នៅ ខ្ញុំនៅស្វាយឃ្លាំង ស្រុកក្រូចឆ្មារ -- ឃុំៗស្វាយឃ្លាំង ភូមិស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម កាលនោះ។

**ស៖** បាទ អរគុណ។ ថាតើនៅៗភូមិដែលលោកស្រីបានរស់នៅហ្នឹង ជាភូមិចាម ឬមួយជាភូមិដែលចម្រុះ?

[១៣:៤២:៤១]

**ឆ៖** រស់នៅភូមិចាម កាលហ្នឹងនុះ។

**ស៖** បាទ អរគុណ។ ថាតើនៅក្នុងភូមិនោះ បងប្អូនជន ប្រជាជនចាមនៅទីនោះ មានការគោរពបូជាផ្នែកសាសនា ឬមួយប្រពៃណីហ្នឹងជាធម្មតាដែរៗឬទេ នៅពេលនោះ?

**ឆ៖** បូជាគោរពសាសនាហ្នឹង កាលជំនាន់ហ្នឹង កាលឆ្នាំ៧៥ហ្នឹង វាច្របូកច្របល់ហើយ។ សាសនា អត់មានសាសនាទេ អត់មានចាមទេ កាលនុ៎ង គេចង់បំបិទ ហើយអត់ឲ្យមានចាមទៅថ្វាយបង្គំនៅក្នុងស្គី ព្រះវិហារទេ។

**ស៖** សុំទោស ដោយសារអម្បាញ់មិញ ខ្ញុំអត់បានប្រាប់ពីពេលវេលាច្បាស់លាស់ ប៉ុន្តែពេលវេលាខ្ញុំបានប្រាប់ពីមុន។ អ៊ីចឹងខ្ញុំសូមជម្រាបសួរថា អ្វីដែលខ្ញុំសួរនេះ ថាតើនៅពេលដែលមុនឆ្នាំ១៩៧៥ បានន័យថាមុនបន្តិចណ៎ា មុន៧៥ ថាតើការគោរពបូជានៅក្នុងភូមិរបស់លោកស្រីហ្នឹង គេគោរពនៅធម្មតា ឬមួយវាមានការប្រែប្រួលអីហើយ?

**ឆ៖** កាលហ្នឹង វានៅមានសាសនា នៅគោរពបូជា នៅសំយ៉ាំង ថ្វាយបង្គំអីបានធម្មតាណ៎ា ប៉ុន្តែអើដូចថា នៅភ័យខ្លាចដែរ កាលមុនហ្នឹង មុនឆ្នាំ៧៥ហ្នឹង។ ដល់មកជិត៧៥ហ្នឹង ដូចថាវាៗបាត់អស់ហើយ គ្មានរឿងអីទេ ប៉ុនចាមបះបោរហ្នឹង--

[១៣:៤៤:៤៩]

**ស៖** បាទ ឈប់ៗ ឈប់សិនៗ។ សូមអ្នកមីង ស្តាប់សំណួរមួយៗ ហើយឆ្លើយតាមកម្រិតណ៎ាអាច។ អ៊ីចឹងខ្ញុំចង់ជម្រាបសួរបន្តទៀតថា ក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥។ អ៊ីចឹងថាក្រោយថ្ងៃ១៧ មេសា ថាតើប្រជាជនចាមនៅក្នុងភូមិរបស់លោកស្រីហ្នឹងនៅទីនោះដដែល ឬមួយត្រូវគេបញ្ជូនទៅខាងណា?

**ឆ៖** នៅកាល៧៥ហ្នឹង គេជម្លៀសហើយ គេបះបោររួច គេជម្លៀសខ្ញុំហ្នឹង បងប្អូននៅភូមិស្វាយឃ្លាំងហ្នឹង គេជម្លៀសទាំងអស់ គេអត់ឲ្យនៅទេ។ អាខ្លះទៅខាងដំបែទៅ អាខ្លះទៅខាងកំពង់ធំទៅ ទៅខាងសម្ពាសទៅ ខ្ញុំនេះអត់មានឪពុក ខ្ញុំទៅនៅខ្សាច់ប្រឆេះ នៅខ្សាច់ប្រឆេះលើនេះ។

**ស៖** បាទ អ្នកស្រីថាតាំងពីក្រោយឆ្នាំ១៩៧៥មក ត្រូវគេជម្លៀស។ ថាតើជាក់ស្តែងក្រុមគ្រួសារអ្នកស្រីហ្នឹងត្រូវគេជម្លៀសទៅខាងណាដែរ ឬមួយមិនជម្លៀសទេ?

**ឆ៖** គេជម្លៀសទៅនៅខ្សាច់ប្រឆេះ ប៉ុន្តែទៅមុនដំបូងចេញពីភូមិស្វាយឃ្លាំងទៅ ទៅនៅក្រូចឆ្មារលើ ទៅនៅក្នុង គេយកទៅឃុំឃាំងនៅឡថ្នាំ ឡគេដាក់ថ្នាំ ឃ្លាំងដាក់ថ្នាំន មួយខែ បីថ្ងៃ ពួកខ្ញុំចេញមកហ្នឹង មកនៅខ្សាច់ប្រឆេះហ្នឹង រួចបានគេឲ្យខ្ញុំចេញមកនៅខ្សាច់ប្រឆេះនេះ។

**ស៖** អ៊ីចេះសូមលោកស្រីជម្រាបទៅអង្គជំនុំជម្រះឲ្យបានជ្រាប ហើយដំណាក់កាលផងថា តើពេលភ្លាមហ្នឹង គេបញ្ជូនទៅកន្លែងណា ហើយកន្លែងហ្នឹងគេធ្វើអីខ្លះ? សូមឲ្យបញ្ជាក់អ៊ីចឹងណា ហើយយើងដាក់ហើយទៅដល់ខ្សាច់ប្រឆេះ ឬមួយយ៉ាងដូចម្តេច? ពេលដែលចេញពីផ្ទះហ្នឹងទៅកន្លែងណាសិន?

[១៣:៤៨:០០]

**ផ៖** ខ្ញុំសូមបញ្ជាក់ម្តងទៀត គេជម្លៀសខ្ញុំទៅហ្នឹង ទៅនៅក្រូចឆ្មារលើហ្នឹង គេយកទៅឃុំឃាំងណា ប៉ុន្តែពេល -- អានេះខ្ញុំនិយាយកាត់ -- ខ្ញុំចេញពីភូមិមកហ្នឹងណា ខ្ញុំបាត់បង់ឪពុកម្នាក់ហើយ។ ឪពុកខ្ញុំណា គេចាប់នៅមាត់ស្ពានព្រែកចាម គេឲ្យមកនៅខាងភូមិសំរោងនេះ គេឃាត់នៅកន្លែងហ្នឹងហើយ រួចហើយគេឲ្យខ្ញុំដើរមកៗនៅៗក្រូចឆ្មារលើនេះ នៅក្នុងឃ្លាំងគេដាក់ថ្នាំ។ ឃ្លាំងគេដាក់ថ្នាំហ្នឹង គេឃុំឃាំងពួកខ្ញុំអត់ឲ្យទៅណាទេ គេនៅយាមជុំវិញ។ រួចនៅតែម្តាយបងប្អូនខ្ញុំហ្នឹងហើយ ជីដូនខ្ញុំម្នាក់ទៀត មួយគ្រួសារខ្ញុំហ្នឹង រួចក្រៅពីហ្នឹងៗវាច្រើនណាស់ ខ្ញុំអត់ចាំទេ មិនដឹងជាពីណាខ្លះទេ។ នៅក្នុងហ្នឹងបានពីរបីរយនាក់ក្នុងមួយឃ្លាំងឡហ្នឹងនោះ។ រួចដល់អ៊ីចឹងទៅ គេឲ្យពួកខ្ញុំនៅមួយខែ បីថ្ងៃៗហ្នឹងបានគេឲ្យចេញ រួចហូបចុកអីអត់មានគ្រប់គ្រាន់ទេ ហូបតែបបរគេចែកឲ្យមួយវែកទេ។ ប្អូនខ្ញុំកុមារហ្នឹង និយាយពីយំស្រែកឈឺពោះ អត់មានពីអត់មានថ្នាំព្យាបាលទេ អត់មានអីទេ។ យូរៗទៅទាល់តែបាត់ខ្លួនឯង។

**ស៖** បាទ អរគុណ។ អម្បាញ់មិញ លោកស្រីបានបញ្ជាក់ថា នៅពេលដែលចេញហ្នឹងត្រូវបាត់ឪពុក។ តើបាត់ហ្នឹង បាត់យ៉ាងដូចម្តេច ហើយឬមួយបាត់ៗតែគាត់ទេ ឬមួយបាត់នរណាទៀត?

**ផ៖** បាត់ឪពុកខ្ញុំហ្នឹង គេឃាត់ឃាំងនៅកន្លែងហ្នឹងហើយ គេអត់ឲ្យតាមពួកខ្ញុំមកទេ នៅកន្លែងហ្នឹង បាត់ទាល់ឥឡូវ។ បាត់តែម្នាក់ឪពុកខ្ញុំហ្នឹង។

**ស៖** ចុះប្រជាជនផ្សេងទៀត ដែលមកតាមហ្នឹង អ្នកមីងដឹងថា មានការបាត់ហ្នឹងអត់ទេ?

**ផ៖** ខ្ញុំនៅចាំថា ដូចថា អើ! នៅជិតៗផ្ទះខ្ញុំអីហ្នឹងហើយ បាត់ទៅហ្នឹង ទៅតែម្តង អត់ឃើញមកវិញទេ។ អាខ្លះមកវិញ អាខ្លះអត់មកទេ។ ដូចឪពុកខ្ញុំអី បាត់សូន្យតែម្តង មកដល់រាល់ថ្ងៃនេះ។

**ស៖** បន្ទាប់មកថា ទៅនៅស្អីរោងដាក់ថ្នាំ បាទ។ នៅកន្លែងនោះ ប្រជាជនច្រើនទេ តើនៅទីនោះគេឲ្យនៅធ្វើអី ឬមួយនៅយ៉ាងម៉េច?

[១៣:៥១:៣០]

**ផ៖** ប្រជាជននៅកន្លែងហ្នឹង គេឃាត់ឃាំងនៅកន្លែងហ្នឹង ដើម្បីគេរកខ្មាំង។ គេអត់ឲ្យទៅណាទេ គេឃុំនៅកន្លែងហ្នឹងហើយ មួយខែ បីថ្ងៃហ្នឹង។ មានយោធា មានអីគេនៅយាមជុំវិញហ្នឹងហើយ។ រួចពួកខ្ញុំហ្នឹង គេអត់ឲ្យធ្វើអីទេ គេឃុំនៅកន្លែងហ្នឹង ទាល់តែគេឲ្យថ្ងៃចេញហ្នឹងតែម្តងហើយ។

**ស៖** អ្នកស្រីបានលើកឡើងថា គេឲ្យទៅទីនោះ គេអត់ឲ្យធ្វើអីទេ ដើម្បីរកខ្មាំង។ ចុះគេរកខ្មាំងតើគេរកយ៉ាងម៉េច អ្នកស្រីដឹងដែរឬទេ?

**ឆ៖** គេរកខ្មាំងហ្នឹង ដើម្បីថា ពួកខ្ញុំហ្នឹងវាបះបោរទេ។ ដល់អ៊ីចឹង គេចោទយើងថា ខ្មាំង។ រួច គេរកអត់អស់ គេមកស្រាវជ្រាវទៀត។

**សៈ** អ្នកមីងបានលើកឡើង ថាតើពាក់ព័ន្ធនឹងការបះបោរ តើអ្នកមីងដឹងថាបះបោរហ្នឹងនៅឯណាដែរ?

**ឆ៖** បះបោរហ្នឹង នៅស្វាយឃ្លាំងហ្នឹងហើយ។ នៅភូមិស្វាយឃ្លាំងហ្នឹងហើយ ដល់យើងចាញ់គេហើយនោះ បានគេជម្លៀសយើងចេញមកហ្នឹង។ អ្នកណាមិនចេញ អ្នកហ្នឹងខ្មាំង។ សម្លាប់នៅកន្លែងហ្នឹង បាញ់ចោលនៅកន្លែងហ្នឹងហើយ បើអ្នកអត់ចេញ បើយើងចង់រស់ ចេញទៅ។

**សៈ** តើអ្នកមីងនៅក្នុងព្រឹត្តិការណ៍ហ្នឹងដែរអត់?

**ឆ៖** ខ្ញុំនៅ នៅក្នុងហ្នឹងដែរ កាលហ្នឹង អាយុខ្ញុំ១៧ឆ្នាំ នៅក្នុងព្រឹត្តិការណ៍នៅចាមបះបោរនៅស្វាយឃ្លាំងហ្នឹង។

[១៣:៥៤:១៤]

**សៈ** ថាតើនៅព្រឹត្តិការណ៍នៅពេលនោះ ដឹងថា ចាមហ្នឹង ឬមួយ ដឹងថាក្រុមចាម ក្រុមណាអីក្រុមណាទេ អ្នកមីងមានដឹងដែរអត់ទេ?

**ឆ៖** ខ្ញុំអត់ដឹងដែរកាលណោះ ខ្ញុំដឹងថា ឃើញថាគេ -- បើអ្នកណា ដូចថា ពាក់ព័ន្ធនៅក្នុងហេតុការណ៍ហ្នឹង គេយកទៅតែម្តងហើយ ខ្ញុំដឹងតែប៉ុណ្ណឹង។ កាលហ្នឹង ខ្ញុំនៅជាមួយគ្នាដែរហ្នឹងហើយ ពេលបះបោរហ្នឹង។

**សៈ** សូមទោសខ្ញុំចង់ដឹង សូមអ្នកមីងជម្រាបទៅអង្គជំនុំជម្រះឲ្យបានច្បាស់តិចមើល៍ ថាតើនៅពេលដែលបះបោរហ្នឹងពេលយប់ ពេលថ្ងៃ ឬមួយពេលណា?

**ឆ៖** បះបោរហ្នឹងនៅពេលយប់ ម៉ោងប្រាំពីរអីហ្នឹងហើយ គេចាប់ផ្តើម។ ដល់ថ្ងៃហ្នឹងទៀតមួយថ្ងៃទៀត ដល់យប់ម៉ោងប្រាំពីរហ្នឹង ត្រូវចាញ់គេហើយ ត្រូវចាកចេញពីភូមិស្វាយឃ្លាំងហ្នឹងហើយ។

**សៈ** បាទ អរគុណ។ ខ្ញុំសូមចូលទៅបរិបទមួយដែលអ្នកមីងថា ក្រោយពីមានការបះបោរហ្នឹងគេបានបញ្ជូន ជម្លៀសប្រជាជនចេញ។ ហើយអម្បាញ់មិញបានលើកឡើងថា ទៅនៅខ្សាច់ប្រឆេះលើតើខ្សាច់ប្រឆេះលើហ្នឹងនៅក្នុងក្រុចឆ្មារហ្នឹងដែរ ឬមួយនៅកន្លែងណា?

**ឆ៖** គេជម្លៀសខ្ញុំទៅនៅខ្សាច់ប្រឆេះលើហ្នឹង ឲ្យទៅនៅក្នុងឃ្លាំងឡហ្នឹងសិនទៅ គេឃុំខ្លួនខ្ញុំមួយខែ បីថ្ងៃហ្នឹងរួច បានគេឲ្យខ្ញុំទៅនៅខ្សាច់ប្រឆេះលើហ្នឹង។

[១៣:៥៦:៥០]

**ស៖** តើនៅខ្សាច់ប្រឆេះលើហ្នឹង នៅបានប៉ុន្មានខែ ប៉ុន្មានថ្ងៃ ឬមួយនៅរហូតទៅដល់ពេលបែក ៧៩?

**ឆ៖** នៅខ្សាច់ប្រឆេះលើហ្នឹង គេជម្លៀសទៅហ្នឹងទាល់តែពួកនិរតីហ្នឹងចូលមកហ្នឹងហើយ ពួកខាងនិរតី អាពត វាវៃខាងបូព៌ានោះ។ វាចូលមកហ្នឹង បានវាប្រមូលពួកខ្ញុំទៅហ្នឹងហើយ នៅខ្សាច់ប្រឆេះហ្នឹងជាប់ពីរឆ្នាំ ជាងពីរឆ្នាំដែរ ជិតបីឆ្នាំដែរ ៧៥, ៧៦, ៧៧ហ្នឹង។ ៧៧ហ្នឹងហើយដែលវាខ្លាំងក្លាជាងគេបង្អស់ យកមនុស្សទៅវៃចោលគ្មានស្គាល់មុខពីណាទេ។

**ស៖** តើនៅខ្សាច់ប្រឆេះលើហ្នឹង គេមានហៅប្រជុំប្រាប់រឿងអីទេ នៅខ្សាច់ប្រឆេះលើហ្នឹង?

**ឆ៖** គេឲ្យទៅនៅខ្សាច់ប្រឆេះលើហ្នឹង គេហ្នឹងទៅនៅផ្ទះមីង អ៊ូយ ហ្នឹង ក្នុងមួយខែគេប្រជុំម្ដងហើយ ជួនណាអត់ដល់មួយខែទេ គេប្រជុំ គេអប់រំយើង។ គេអត់ឲ្យយើងនិយាយចាម គេអត់ឲ្យយើងដូចថានៅជួបជុំបងប្អូនចាមពីរបីនាក់ ទាល់តែមានខ្មែរម្នាក់នៅជាមួយ គេអត់ឲ្យនិយាយចាម ហើយនិងគេបំបាត់សាសនាយើងហើយ គេអត់ឲ្យយើងថ្វាយបង្គំទេ គេអត់ឲ្យយើងរៀនសូត្រធម៌អីទេ អត់មានទេពេលហ្នឹងដាច់អស់ហើយ គ្មានសល់ទេ។ ប៉ុនថាគេឲ្យហូបចុកអី គ្រាន់បើដែរ បានពាក់កណ្ដាលឆ្នាំបានវាអត់មែនទែន។

**ស៖** អម្បាញ់មិញអ្នកមីងបានលើកឡើងថា មានការប្រជុំហាមឃាត់អំពីការគោរព ថាតើនៅពេលនោះអ្នកដែលមិនគោរពហ្នឹង អ្នកមីងបានជួបប្រទះទេ? តើគេហ្នឹងត្រូវបានគេចាត់វិធានការយ៉ាងដូចម្ដេច ឬមួយអត់ទេ?

[១៣:៥៩:៥៦]

**ឆ៖** អ្នកណាអត់គោរព គឺថាមានថា បើយើងនៅ -- គេឃាត់យើងហើយ រួចយើងនៅតែខំថ្វាយបង្គំ យើងខំសំយ៉ុំងថ្វាយបង្គំហ្នឹង អាហ្នឹងគេថាយើងខ្មាំងហ្មងហើយតើ គេអត់ទុកយើងទេ គេយកទៅហើយ។

**ស៖** ថាតើអ្នកមីង ក្រោយមកទៀត គេមានបញ្ជូនទៅធ្វើការងារនៅកងចល័តដែរអត់ទេ?

**ឆ៖** ក្រោយមក ខ្ញុំទៅនៅ -- គេឲ្យខ្ញុំទៅធ្វើការនៅកងចល័ត ដល់ខែប្រាំង គេចាត់តាំងពួកខ្ញុំទៅនៅបឹងក្រចាប់អស់ ទៅធ្វើការលើកទំនប់ ជីក លើកទំនប់នៅបឹងក្រចាប់ រយៈកាលបីខែបញ្ចប់។ រួចជីទំនប់ហ្នឹង លើកទំនប់ហ្នឹង ក្នុងមួយថ្ងៃ ៣ម៉ែត្រគូប។ ហូបបបរទេកាលហ្នឹង បបរគ្រាន់បើដែរ គ្រាន់

តែរាងខាប់ៗបន្តិចទៅ ដល់យូរៗទៅរាវ។ ហូបបបរជាមួយអំបិលរាល់ថ្ងៃ គ្មានរឿងអីថា ម្ហូបដែលថាឆ្ងាញ់ រស់ជាតិយ៉ាងម៉េចអត់ដែលស្គាល់ទេ។ ធ្វើការថ្នាក់ដល់ខ្ញុំលើកទំនប់ ថ្ងៃហ្នឹង ដូចថាយូរៗទៅ វាទ្រុឌទ្រោមទៅ វាអស់កម្លាំង វាហេវហត់ទៅ វាទៅជាឈឺ វាគ្រុនក្ដៅ រាករូសប្រហែលម៉ោងពីរ បានបង ឃឹម ចំរើន ដែលគាត់ជូនខ្ញុំទៅមន្ទីរពេទ្យ នៅពេទ្យវត្តឃ្លង់ហ្នឹង។ ទៅដេកបានប្រហែល១០ថ្ងៃ ខ្ញុំចេញមកវិញហើយ ខ្ញុំនៅអត់សុខទេ ខ្ញុំខ្លាចណាស់ ខ្ញុំដេកយូរពេកនោះ។ សូម្បីថាជាល្មមៗ ក៏ខ្ញុំព្រមមកធ្វើការហើយ ខ្ញុំអត់នៅទេ។ ធ្វើការដើម្បីរស់ ចង់បានរស់រានមានជីវិត វានៅតែស្លាប់ដដែល បងប្អូនខ្ញុំ ម៉ែឪខ្ញុំ អស់រលីង។

**ស៖** អម្បាញ់មិញអ្នកមីងបានលើកឡើងថា ពេលដែលទៅធ្វើការហ្នឹង របបអាហារអីមានការលំបាក ថាតើនៅពេលនោះ គេមានបង្អំឱ្យពិសាសាច់ជ្រូកដែលអត់ទេ នៅពេលនោះ?

**ឆ៖** ពេលនោះ គេបង្អំដែរ ឱ្យយើងស៊ីសាច់ដែរ ប៉ុន្តែយើងទៅមិនរួច កាលហ្នឹងវានៅរាងធូរបន្តិចដែរ។ ខ្ញុំអត់ហូបទេ ខ្ញុំហូបតែអំបិលទេ។ សាច់ជ្រូកហ្នឹង គេឱ្យយើងតើ គេធ្វើសម្ល គេអត់ធ្វើសម្លផ្សេងឱ្យយើងហូបណ៎ា គេឱ្យយើង បើយើងមិនស៊ីទេ ហូបអំបិលទេ។ អាខ្លះលេបទៅ អាខ្លះអត់លេបទៅមិនរួច។

**ស៖** ចុះទន្ទឹមពេលនោះ ឯម្ដាយអ្នកមីងដែលនៅផ្ទះហ្នឹង គេឱ្យធ្វើអីដែរ?

**ឆ៖** ម្ដាយខ្ញុំ គេឱ្យចិញ្ចឹមជ្រូកៗបីក្បាលកាលហ្នឹង រួចម្ដាយខ្ញុំខ្លាចថ្នាក់ដល់ធ្លាក់ខ្លួនឈឺ។ អត់ហ៊ានទៅកាន់ជ្រូកទេ គ្រាន់តែលាយកន្ទក់ឱ្យជ្រូកស៊ីទេ។ ទ្រាំទៅ ធ្វើម៉េចបើគេប្រើយើងហើយ បើយើងមិនធ្វើទេ គេថាយើងប្រឆាំងនឹងអង្គការ។

[១៤:០៤:២០]

**ស៖** បាទ អរគុណ។ ចំណុចមួយទៀតថា តើអ្នកមីងត្រូវបានគេបញ្ជូនឱ្យទៅដឹកប្រឡាយកន្លែងណាផ្សេងមួយទៀតដែរអត់ទេ?

**ឆ៖** នៅឆ្នាំទី២ នៅឆ្នាំទី២ហ្នឹង គេបញ្ជូនខ្ញុំទៅនៅបឹងក្រចាប់ហើយ រួចរាល់ហើយ បឹងក្រចាប់ហ្នឹងវារួចហើយណ៎ា ដូចថារួចអស់ហើយ គេបញ្ជូនខ្ញុំទៅនៅអីខាងទឹកជ្រៅនោះ។ នៅទឹកជ្រៅហ្នឹង ខ្ញុំដើរទៅបីថ្ងៃបានដល់កន្លែងទឹកជ្រៅហ្នឹង។ ទៅហ្នឹងយប់ យប់មើលអីមិនឃើញទេណ៎ា រួចអត់មានដូចថាមានកន្លែងស្នាក់នៅអីទេ ទៅហ្នឹងក្រាលកន្ទេលដេកលើផ្នូរខ្មោចតែម្ដងហើយ សុទ្ធតែផ្នូរខ្មោចកន្លែងហ្នឹង យប់ហ្នឹងនោះ។ ភ្លឺឡើងបានដឹងថាផ្នូរខ្មោច ដេកលើដី លើផ្នូរខ្មោច។ រួចដល់ៗមកទៀត ថ្ងៃភ្លឺឡើង

វាឲ្យខ្ញុំទៅរៀបចំធ្វើរោងដូចក្មេងលេងអ៊ីចឹង ប្រក់ស្លឹកឈើទៅ គ្រាន់តែប្រក់ទេ ក្រាលកន្ទេលដេកលើដី រហូត ពីរខែទៀត។ ដល់ភ្លៀងមកហ្នឹង និយាយពីទឹកត្រឹមៗនេះ និយាយពីសត្វឈ្លើង ហើយនិងជន្លេន ហ្នឹង និយាយពីអ្វូ! បើអ្នកខ្លាចវិញសន្លប់នៅក្នុងទឹកហ្នឹងហើយ មួយយប់ទល់ភ្លឺ ភ្លឺឡើងទៅកាប់ទៅធ្វើ ការទៀត អត់មានពេលសម្រាកទេ ដេកលើដីផ្ទាល់ ថាពីរខែបានចប់ការងារភ្លៀងធ្លាក់ខ្លាំង ជីកលែង កើតហើយ ជីកប្រឡាយហ្នឹង ទទឹងហ្នឹង៦ម៉ែត្រ ជម្រៅ ២ម៉ែត្រនៅខាងទឹកជ្រៅហ្នឹងនោះ។

**ស៖** បាទ អរគុណ។ នៅបានន័យថាពេលដែលទៅធ្វើប្រឡាយនៅទីនោះ តាមការរៀបរាប់ អម្បាញ់មិញ ការស្នាក់នៅអី ថាតើការស្នាក់នៅពេលមានភ្លៀងមានអីទេ ស្នាក់នៅយ៉ាងដូចម្ដេចទៅ?

**ឆ៖** ខ្ញុំហាលភ្លៀងហ្នឹងហើយ នៅកណ្ដាលភ្លៀងហ្នឹងហើយ ទាល់តែភ្លៀងរាំងទៅហ្នឹង អើវា ផុតទឹកភ្លៀងហ្នឹងទៅ នៅទៅ ធ្វើម៉េចបើទៅសុំផ្ទះប្រជាជន១អត់ឲ្យហ៊ាន -- គេអត់ឲ្យហ៊ាននៅទៀត។

**ស៖** បាទ អរគុណ។ ខ្ញុំចូលទៅក្នុងចំណុចមួយទៀតថា នៅពេលដែលយើងទៅចល័ត -- អ្នក មីងទៅចល័តទៅអីហើយ នៅពេលនោះគឺថាបានមកត្រឡប់មកខ្សាច់ប្រឆេះវិញ ថាតើមកខ្សាច់ប្រឆេះ វិញហ្នឹង គឺមានបញ្ហាអ្វីកើនឡើងទេនៅពេលនោះ?

**ឆ៖** នៅខ្សាច់ប្រឆេះត្រឡប់មកវិញមកពីធ្វើការនៅទឹកជ្រៅហ្នឹង ខ្ញុំមកវិញហ្នឹងបានតែបីថ្ងៃ បួនថ្ងៃទេណា គេឲ្យខ្ញុំ ចាត់តាំងខ្ញុំទៅជីកទំនប់នៅជំនីកឯណោះ ទៅជីកទំនប់ជំនីកហ្នឹងបានប្រហែល កន្លះខែ ឮស្នូរកាំភ្លើងបាញ់គ្នា បាញ់ហើយ ពួកនិរតីចូលមកហើយ វាវ៉ៃគ្នា វ៉ៃជាមួយពួកគេហៅថាខ្មែរស ខ្មែរស្អីទេ បាញ់គ្នាបាញ់ទៅមក១ ពួកខ្ញុំទ្រាំមិនបានរត់មកផ្ទះមក។

**ស៖** ពេលដែលអ្នកមីងនៅក្នុងខ្សាច់ប្រឆេះ១ហ្នឹង ថាតើមានការជួបជុំគ្នានៅ១កន្លែងណាមួយ ទេ គេមានហៅទៅជួបជុំគ្នានៅកន្លែងណាមួយទេនៅពេលនោះ?

[១៤:០៨:៥៦]

**ឆ៖** នៅពេលនោះ អត់មានពីណាហៅទៅជួបជុំអីទេ គេដឹងថា ខាងនោះគេវ៉ៃហើយ នោះគេ វាប្រតាប់ប្រតាយគ្នាហើយ វ៉ៃគ្នាហើយ បាញ់គ្នាហើយនោះ អ៊ីចឹងគេអត់វ៉ៃអីទេ នៅក្នុងខ្សាច់ប្រឆេះហ្នឹង បានប្រហែលកន្លះខែ ពួកនិរតីវាប្រមូលចាមយើងហ្នឹងហើយ សុទ្ធតែចាម បងប្អូនចាមយើងហ្នឹង គេអត់ ឲ្យនៅទេ គេប្រមូល គេបោសសម្អាតហ្នងហើយ គេយកទៅវ៉ៃចោល -- អ៎! យកទៅហើយ គេហៅ យកទៅហើយ ឲ្យទៅនៅ -- គេថាផ្លាស់ទីលំនៅ ផ្លាស់ទៅនៅខាងត្រើយម្ខាង ខាងស្ទឹងត្រង់ គេថាមាន ការងារធ្វើហូបចុកគ្រប់គ្រាន់។ រួចដល់មកខ្ញុំនេះ ទៅតែម៉ែឪ ម៉ែខ្ញុំ ប្អូនខ្ញុំ ជីដូនខ្ញុំទៅហ្នឹងណា ហើយនិង

អ្នកភូមិចាមៗទាំងអស់គ្នាហ្នឹងគេប្រមូលទៅអស់ហើយ។ ចំណែកខាងនារីវិញ គេឲ្យខ្ញុំទៅនៅភូមិទ្រា គេយកមក -- គេហៅមកប្រជុំនៅភូមិទ្រានេះ --អ៎! នៅខ្សាច់ប្រឆេះកណ្ដាល គេបែងចែកហើយ ម៉ែម្ដាយៗចុះកាណូតនៅក្រូចឆ្មារ ចុះសាឡាងនោះ។ ដល់ពួកខ្ញុំគេឲ្យខ្ញុំមកប្រជុំនៅខ្សាច់ប្រឆេះលើនេះ -- អ៎! ខ្សាច់ប្រឆេះកណ្ដាលនេះ ប្រជុំរួចរាល់ហ្នឹងប្រហែលជាម៉ោងមួយហើយបានគេឲ្យពួកខ្ញុំចេញទៅៗនៅភូមិទ្រា។

**ស៖** បាទ អរគុណ។ ថាតើនៅពេលដែលគេហៅប្រជុំហើយ គេឲ្យជិះទូក ជិះអីហ្នឹង សូមឲ្យអ្នកមីងជម្រាបទៅអង្គជំនុំជម្រះមើល ថាតើស្ថានភាពនៅពេលដែលគេឲ្យទៅជិះទូកហ្នឹង តើគេជិះទូកយ៉ាងម៉េច តើអ្នកមីងបានដឹងដែរឬអត់ទេ?

**ឆ៖** ខ្ញុំដឹងបងប្អូនថា គេនៅប្រាប់ខ្ញុំ ខ្ញុំទៅហើយហ្នឹង គេថាម្ដាយខ្ញុំជិះសាឡាង ជិះកាណូតធំៗបងអើយ គេដាក់សាឡាងទៅ មនុស្សច្រើនណាស់ មិនមែនតិចឯណា មួយស្រុកក្រូចឆ្មារ គេប្រមូលអស់ហើយសុទ្ធតែចាម។ ទៅចុះនៅខាងស្ទឹងត្រង់នោះ គេមកប្រាប់នោះ។

**ស៖** បានន័យថា ទិសដៅដែលគេដឹកទៅហ្នឹង ទៅខាងស្ទឹងត្រង់ ឬមួយទៅខាងណាទៀត។

**ឆ៖** ទៅខាងស្ទឹងត្រង់ហ្នឹងហើយ ប៉ុន្តែទិសដៅមិនដឹងទៅខាងណាខ្ញុំអត់ដឹងទេ ប៉ុន្តែទៅខាងស្ទឹងត្រង់ហ្នឹង ហើយចុះកាណូតនៅស្ទឹងត្រង់ហ្នឹងហ្មងហើយ។ គេយកទៅខាងណាខាងណីខ្ញុំអត់ដឹងទេណា ខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** ថាតើនៅពេលនោះ ក្រុមគ្រួសារអ្នកមីងត្រូវគេបញ្ជូនទៅតាមទូកហ្នឹងទាំងអស់ ឬមួយមានអ្នកផ្សេងទៅកន្លែងណាផ្សេង?

**ឆ៖** គ្រួសារខ្ញុំ គេបញ្ជូនទៅហ្នឹងហើយ ជិះកាណូតទូកធំហ្នឹងហើយ ហើយនិងគ្រួសារក្រៅពីហ្នឹងទៅទៀត សុទ្ធតែបងប្អូនចាមណោះក៏ទៅដែរ ទៅជាមួយគ្នាទាំងអស់ហ្នឹង សុទ្ធតែចាម អត់មានខ្មែរលាយម្នាក់ទេ។

[១៤:១២:៤៥]

**ស៖** អ្នកមីងអាចរៀបរាប់បានទេ ថាក្រុមគ្រួសារអ្នកមីងហ្នឹង មាននរណាខ្លះដែលទៅហ្នឹង?

**ឆ៖** ខ្ញុំរៀបរាប់បាន។ មើល៍ ក្រៅពីខ្ញុំទៅ ប្អូនប្រុសខ្ញុំម្នាក់ ម្ដាយខ្ញុំម្នាក់ ប្អូនស្រីបីនាក់ទៀត ហើយនិងជីដូនម្នាក់ទៀត ប៉ុណ្ណឹង។

**ស៖** អរគុណ។ ខ្ញុំសូមបង្វែរមកអ្នកមីងផ្ទាល់វិញ ថាតើនៅពេលនោះ គេឲ្យអ្នកមីងទៅខាងភូមិ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ទ្រាហ្នឹង តើការចាកចេញពីកន្លែងដែលរស់នៅខ្សាច់ប្រឆេះហ្នឹង ទៅភូមិទ្រាហ្នឹង ធ្វើដំណើរប៉ុន្មានម៉ោង ហើយទៅដល់នោះពេលណា យប់ ឬថ្ងៃ?

**ឆ៖** កាលគេឲ្យខ្ញុំទៅភូមិទ្រាហ្នឹង ពីម៉ោង ចាប់ពីម៉ោងមួយទៅ ដល់ភូមិទ្រា -- ពីម៉ោងមួយទៅដល់ម៉ោងប្រាំមួយ ជិតទៅម៉ោងប្រាំពីរហើយ ភ្លៀងស្រិបៗទៀត បានទៅដល់ភូមិទ្រាហ្នឹង។ ទៅដល់ភូមិទ្រា និយាយពីទន់ខ្លួន អត់បាយអត់ទឹកមួយថ្ងៃទាល់ល្ងាចហើយ អត់មានអីស៊ីទេ អត់មានអីចូលក្នុងពោះបន្តិចសោះ។ រួចទៅ ខ្ញុំដេកនៅលើផ្ទះហ្នឹងតែម្តង ហើយគេឲ្យខ្ញុំដេក រួចខ្ញុំទៅហ្នឹង ខ្ញុំឃើញផ្ទះអ្នកជិតខាងហ្នឹងគ្រាន់តែអើត ឃើញខ្ញុំមកហ្នឹង គេលួចអើតមកហ្នឹង។ ពួចវាក់ទៅជាប់ខ្នោះនៅនឹងជើងហ្នឹង មួយផ្ទះបានដែរ បួន ដប់ ម្ភៃនាក់ដែរ សុទ្ធតែអ្នកជនរងគ្រោះហើយ អាហ្នឹងសុទ្ធតែប្រុសៗទេ ហើយនិងមានកូនដែរ កូនទៅជាមួយដែរ មានប្រពន្ធមានកូនកាលហ្នឹងនោះ។ អ្នកអង្គភាពកាលហ្នឹងអ្នកអង្គភាពខ្ញុំស្គាល់ ថាអ្នកអង្គភាព អ្នកធ្វើការ វាយកទៅដាក់ផ្ទះមួយៗហ្នឹង រួចពួកខ្ញុំឡើងលើផ្ទះហ្នឹងហើយ។ ទៅនិយាយពីទន់ខ្លួនដេក។ ដេករួចទៅហ្នឹង ប្រហែលអត់ដល់ម្ភៃនាទីផង ចៅហ្វាយស្រុក ហូ ឡើងទៅមានយោធាពីរនាក់ ស្រីម្នាក់ហ្នឹងកាន់ខ្សែអង្រឹងទៀត។ ចៅហ្វាយស្រុក ហូ ថា៖ “ក្មួយៗយើងក្រោកឡើង ពូសុំចង”។ រួចពួកខ្ញុំក៏ក្រោកដែរ ក្រោកឡើងមកឲ្យគេចងដោយស្រួលគ្មានអីថា ងាករេទៅខាងណាខាងណីទេ ឲ្យគេចងរួចៗ គេតម្រង់ជួរមួយជួរៗទៅ។ ប្រហែលជា៣០០, ៤០០នាក់ក្នុងមួយផ្ទះហ្នឹងនោះ មិនមែនតិចទេណា សុទ្ធតែនារីពេញទំហឹងតែម្តងហើយ។ រួចដល់អ៊ីចឹងទៅ គេចងរួចៗហ្នឹង គេចាប់ផ្តើមសួរយើងហើយ។ គេសួរថា កូនចាម? កូនខ្មែរ? អ្នកដែលឆ្លើយត្រង់ថាកូនចាម កូនចាមចុះ មានអាវុធមួយដើម អាកាស្វាយបត់ ហើយនិងកាំបិតក្តុកមួយដើមទៀតលីទៅជាមួយគ្នា។ ស្រីម្នាក់ហ្នឹងណ៎ា ពួកខ្ញុំហ្នឹងចុះទៅហ្នឹង អ្នកដែលគេសួរថា កូនចាមហ្នឹង។ ពាក្យថា “កូនចាមចុះៗ” ហ្នឹងទៅសុទ្ធតែមានអ្នកជូនទៅ សុទ្ធតែមានប្រដាប់អាវុធទាំងអស់ អត់មាននេះទេ។ រួចទៅហ្នឹងអត់មានផ្លូវមកវិញទេ អត់ឃើញទេ អ្នកដែលទៅហ្នឹងអត់មកវិញទេ បាត់សូន្យទាល់តឡូវនេះ។ រួចខ្ញុំ គេចងខ្ញុំរួចគេសួរខ្ញុំរួចហ្នឹងណ៎ា រួចមកដល់ខ្ញុំនេះ សួរខ្ញុំថា៖ “នាងឯងកូនចាម កូនខ្មែរ? ក្មួយឯងកូនចាម កូនខ្មែរ?” ខ្ញុំឆ្លើយ ខ្ញុំថា៖ “ខ្ញុំកូនខ្មែរ!” រួចគេចុចពិលមើលខ្ញុំនេះ៖ “ទេ! មិនមែនកូនខ្មែរ កូនយួនទេអ្ហែះ?” ខ្ញុំថា៖ “ខ្ញុំកូនខ្មែរ! ខ្ញុំមិនមែនកូនយួនទេណ៎ា! មើលមុខឲ្យច្បាស់ទៅ!”។ អូ! ប្រកែកជាមួយចៅហ្វាយស្រុកទៀតបីដង ឆ្លើយជាមួយវាថា ខ្ញុំហ្នឹងកូនខ្មែរ បានវាទទួលស្គាល់ថា ខ្មែរមែន កាលនោះ។

[១៤:១៧:១២]

រួចដល់ពួកហ្នឹងវាទៅអស់ទៅ ពួកចាមៗហ្នឹងចុះទៅអស់ហើយ នៅសល់ពួកខ្ញុំប្រហែល ៣០ នាក់ ហ្នឹង គាត់ថា គាត់ចងរួច គាត់សួររួចហ្នឹងណ៎ា គាត់ស្រាយឲ្យវិញដែរ។ គាត់ថា "សំណាងបានពូ មកសួរនេះ កុំអីទៅអស់ហើយ" គាត់និយាយអ៊ីចឹងណ៎ា។ រួចដល់គេចងរួច អីរួចហ្នឹងណ៎ា និយាយពីថា ភ្លឺឡើងខ្ញុំបាន ដូចថាគេស្រាយរួចហើយ។ គេយកបបរមួយឆ្នាំងប៉ុណ្ណេះ គ្នាជាង៣០នាក់។ ប៉ុន្តែគេសម្ត កាលហ្នឹងសម្តម្ហូរដើមចេក សុទ្ធតែត្រីធំៗទៀត ត្រីពោធិ៍ខ្មៅត្រចៀក ត្រីកែស ត្រីក្លាំងហាយ។ គេស្ត មួយឆ្នាំងប៉ុននេះ បបរមួយឆ្នាំងក៏ប៉ុននេះដែរ គេយកមកហូប។ ខ្ញុំហូបតែពីរស្លាបព្រាទេ ខ្ញុំលេបអត់ចូល ទេ។ ពួកយោធាហ្នឹងវាថាឲ្យខ្ញុំទៀត វាថា៖ "បងអើយ! ហូបទៅហូបឲ្យឆ្អែតទៅ វាលែងអីហើយ អត់អី ទេ កុំភ័យ" វាថាអ៊ីចឹងណ៎ា។

**ស៖** បាទ អរគុណ។ ខ្ញុំសូមត្រឡប់ទៅក្រោយបន្តិច ថាតើ នៅពេលដែលគេបញ្ជូនអ្នកមីងមក ហ្នឹងមានគ្នាប៉ុន្មាននាក់ដែរដែលគេបញ្ជូនមកហ្នឹងហើយសុទ្ធតែជាយុវនារី ឬមួយមានអ្នកណាដែលមក ជាមួយដែរឬអត់ទេ?

**ឆ៖** គេបញ្ជូនមកហ្នឹង សុទ្ធតែនារីៗហ្នឹងហើយ ប៉ុន្តែថាមានយោធាជូនមក។ រួចកាលហ្នឹងវា បញ្ជូនខ្ញុំមកដល់ភូមិទ្រាហ្នឹង វាចងខ្ញុំរួច អីរួចស្រេចអស់ហើយហ្នឹង វាស្រាយរួចហើយ ភ្លឺឡើងវាឲ្យខ្ញុំធ្វើ ប្រវត្តិរូបទៀត ខ្ញុំភ្លេចនិយាយកន្លែងហ្នឹង។ ខ្ញុំបកស្រាយឲ្យបងប្អូនទាំងអស់ហ្នឹងឲ្យស្តាប់។ ហើយវាភ្លឺ ឡើងវាឲ្យខ្ញុំធ្វើប្រវត្តិរូប។ វាសួរខ្ញុំថា៖ "បងប្អូនម៉ែឪឈ្មោះអីខ្លះ?" ខ្ញុំថា៖ "ខ្ញុំឈ្មោះ មុត ឆេងអាន"។ ខ្ញុំ ប្រែថា ឈ្មោះខ្មែរទេណា មិនមែន នោ សាទះ ទេណ៎ា។ ខ្ញុំថា មុត ឆេងអាន។ រួចដល់អ៊ីចឹងទៅ វាធ្វើ ប្រវត្តិរូប។ រួចដល់វាងាកមកវាឃើញត្រចៀកខ្ញុំហ្នឹងនៅជាប់ក្រវិលមួយគូនេះ នៅជាប់នឹងត្រចៀកនេះ វាថា ក្រវិលហ្នឹងឲ្យដោះមក ទុកឲ្យអង្គការគេដូរដោះ ធ្វើចបកាប់ជីកទំនប់ជីកប្រឡាយ។ ខ្ញុំក៏ដោះឲ្យ គាត់ដែរ ត្រចៀកខ្ញុំ ខ្ញុំទុកទាល់តែរាល់ថ្ងៃនេះ ខ្ញុំអត់ដែលពាក់មាសទេសូម្បីតែបានប៉ុនណាក៏ដោយក៏ខ្ញុំ មិនពាក់ដែរ។ អាហ្នឹង ខ្ញុំទុកប្រវត្តិហ្នឹង ឲ្យកូនចៅមើល ខ្ញុំប្រាប់កូនខ្ញុំអស់ហើយរាល់ថ្ងៃនេះ។ ប្រវត្តិ-សាស្ត្រហ្នឹង មិនអាចបំភ្លេចបានទេ វាចុកជ្រុលពេក ចាស។

**ស៖** អ្នកមីងសម្រួលអារម្មណ៍បន្តិច។ ថាតើនៅពេលដែលគេសួរថា កូនចាម កូនខ្មែរ ហើយ ទៅ បានន័យថា នៅក្នុងផ្ទះហ្នឹង មានយុវនារីហ្នឹង ច្រើននាក់ ហើយដល់ចុងក្រោយ នៅសល់ប្រហែល នៅសល់ចំនួនប៉ុន្មានដែរ នៅជាមួយអ្នកមីង?

[១៤:២១:២០]

**ឆ៖** នៅសល់ប្រហែល៣០នាក់ រួចឥឡូវហ្នឹង ដឹងគាត់ទៅខាងណា ខាងណីអស់ហើយ គេទៅរកស៊ី ដូចថា គេរកអនាគតរបស់គេដែរ គេយកប្តីទៅ គេនៅស្រុកនេះទៅ គេនៅខេត្តនោះទៅ ឥឡូវនៅសល់តែខ្ញុំមួយនាក់ ពីរនាក់ហ្នឹង រួចមានស្លាប់ទៀត ពួកហ្នឹង ពួកក្រុមជាមួយខ្ញុំហ្នឹង។

**ស៖** ចុះនៅៗពេលនោះ តើគេមាននៅសល់ក្រុមអ្នកមីងអ៊ីចឹង ហើយគេមានបញ្ជូនទៅធ្វើការងារនៅកន្លែងផ្សេងទៀតណាអត់ទេ?

**ឆ៖** វាដោះលែងពួកខ្ញុំរួចហ្នឹង វាមុននឹងវាឲ្យខ្ញុំចេញ វាឃុំនៅកន្លែងហ្នឹងប្រាំបួនថ្ងៃរួចណ៎ា វាឃុំពួកខ្ញុំប្រាំបួនថ្ងៃរួច វាឲ្យពួកខ្ញុំចេញមក វាកាប់ជ្រូកមួយ វាសម្ពការី វាជប់លៀងពួកខ្ញុំ។ អ្នកណាមិនហូប ដឹងហើយ ដឹងគ្នាហើយ។ ពេលហ្នឹងហើយ ខ្ញុំចេះស៊ីសាច់ជ្រូកនោះ។ ខ្ញុំហូបសាច់ជ្រូកបានពីរបីដុំនឹងគេដែរ ដើម្បីឲ្យរស់ខ្លួនហ្នឹង ឲ្យមានរស់ជីវិត។ រួចដល់មក វាចេញមកហ្នឹង វាឲ្យខ្ញុំរយៈកាលបានបីថ្ងៃ ទៅនឹងហ្នឹង វាចាប់ផ្តើម ហើយវាចាត់តាំងឲ្យពួកខ្ញុំហ្នឹងទៅនៅក្រៅពីមន្ទីរវានោះ។ ឆ្លងដូចថា ភូមិទ្រា វាមានដូចថា មានអូរអ៊ីចឹង គេឲ្យខ្ញុំមកនៅក្នុងភូមិនេះ ភូមិបងប្អូនចាម ភូមិទ្រាហ្នឹង ផ្ទះផ្សេង។ ឲ្យនៅមួយក្រុមពួកខ្ញុំហ្នឹងហើយ រួចវាថា វាឲ្យពួកខ្ញុំហ្នឹងជីកដី ឲ្យកាប់ដីថា ធ្វើបង្គន់ ទទឹងហ្នឹងកន្លះម៉ែត្រ បណ្តោយហ្នឹង២ម៉ែត្រ ខ្ញុំនៅចាំរាល់ថ្ងៃហ្នឹង អត់ភ្លេចទេ។ រួចបានពួកដូចថា អ្នកដែលរត់គេចរួច ប្រុសៗកាលគេយកទៅវាយចោលនោះ ពួកហ្នឹងមកលួចប្រាប់ ប្រហែលម៉ោង១ដប់យប់ហ្នឹងហើយ អធ្រាត្រណ៎ា ម៉ោងដប់ ស្ងាត់មនុស្សហើយ ពួកយោធា អាពត យប់មក វាអត់ហ៊ានដើរទេ វាខ្លាចដែរ។ រួចដល់អ៊ីចឹងទៅ វាមកប្រាប់ វាថាពួកអ្ហែងហ្នឹង នៅខំជីកដល់ណាទៀត។ វាឲ្យជីករណ្តៅហ្នឹង ជីកហ្នឹង កាប់ពួកនាងឯងហ្នឹងដដែលហ្នឹង វាគ្មានទុកយើងឲ្យរស់ទេ។ រួចដល់អ៊ីចឹង ខ្ញុំក៏មានអារម្មណ៍តក់ស្លុតដែរណា ខ្ញុំថាអើបើឲ្យខ្ញុំទៅហ្នឹង ខ្ញុំនៅកន្លែងណា គាត់ថាមានកន្លែងនៅ អត់អីទេ នៅលើទូក មានទូកពីរបី។ រួចដល់ខ្ញុំសុំថា ចាំថ្ងៃក្រោយ ចាំស្អែកទៅ ខ្ញុំទៅៗសុំច្បាប់ពួកមីអស់ហ្នឹងថា ខ្ញុំភូតវា ខ្ញុំថាខ្ញុំទៅសុំយកខោអាវពីផ្ទះម្តាយខ្ញុំ បងប្អូនខ្ញុំ បងប្អូនខ្មែរ នៅខ្សាច់ប្រឆេះលើហ្នឹងណ៎ា។ ខ្ញុំសុំរួចហ្នឹង គេឲ្យខ្ញុំទៅដែរ ខ្ញុំថាទៅយកខោអាវមកពាក់ ខ្ញុំអត់មានខោអាវពាក់ទេ ខ្ញុំទៅហ្នឹងតែមួយខ្លួនទេ។ រួចដល់អ៊ីចឹងទៅ គេឲ្យខ្ញុំទៅដែរ។ ទៅ ពួកហ្នឹងនៅចាំខ្ញុំនៅក្នុង នៅភូមិខ្សាច់ប្រឆេះក្រោម ចាំទទួលពួកខ្ញុំ។ ខ្ញុំចេញមកពីម៉ោងពីរកន្លះ ម៉ោងបី -- ម៉ោងបួនកន្លះមកដល់។ មកដល់ ខ្ញុំចុះទូកទៅតែម្តង ទៅនៅក្នុងព្រៃជ្រៅតែម្តងហើយ។ រួចដល់កាលហ្នឹង វា១អី វាអាភ្លើងស្អី វាជាន់ទៅហ្នឹង និយាយពីភ្លឺ វារកពួកខ្ញុំបីថ្ងៃ អត់ឃើញ។ ផ្អើលនោឡោតាំងពីហ្នឹងមកហើយ។ រួចដល់វា ពួកនៅសល់ហ្នឹង វាអត់ហ៊ានធ្វើអីដែរ វាខ្លាចបែកការណ៍ ពួក

នៅជាមួយខ្ញុំហ្នឹង ខ្ញុំមកបានតែបីនាក់គ្នាខ្ញុំហ្នឹង។ ពួកហ្នឹងគេចិញ្ចឹមខ្ញុំ រួចដល់នៅៗក្នុងទឹកហ្នឹងបាន ប្រហែល--

[១៤:២៥:២៣]

**ស៖** ឥឡូវសូមកាត់បន្តិចអ្នកមីងបន្តិច ដោយសារមីងបានរៀបរាប់ហួសទៅមុខបន្តិច។ ខ្ញុំចង់ដឹងនៅពីក្រោយហ្នឹងបន្តិច ថាតើនៅពេលដែលគេបញ្ជូនអ្នកមីងទៅធ្វើការហ្នឹង ធ្វើការនៅតាមដងទន្លេ ឬមួយនៅកន្លែងណាហ្នឹង មានជួបប្រទះព្រឹត្តិការណ៍អីដែរអត់?

**ឆ៖** មានជួបដែរព្រឹត្តិការណ៍ហ្នឹង។ កាលហ្នឹងខ្ញុំគេឲ្យខ្ញុំទៅធ្វើការតាមភូមិហ្នឹង វាជួបប្រទះនៅដងទន្លេ ចំណែកយោធាវិញ វាសម្លាប់ណា វាចងខ្សែជាប់នឹងស្នូនោះ វាបណ្តែតទឹកតែម្តង មួយស្នូៗហ្នឹងមិនដឹងប៉ុន្មាននាក់ទេ។ បើកុមារវិញអាយុ១ឆ្នាំ ឬមួយ៦ខែវិញ វាច្រកបាវ វាចងរួច វាទម្លាក់ទឹក និយាយពីអណ្តែតឡើងស្តឹងៗ រួចជួបហេតុការណ៍ជាមួយ បងថូ ហ្នឹងនៅក្រូចឆ្មារ -- នៅខ្សាច់ប្រឆេះក្រោម គាត់អ្នកធ្វើការនៅខាងយុវជនឃុំ នៅខាងសហករណ៍កាលនៅអាពតហ្នឹងណា ថាអាពត ទៅចុះ។ រួចឃើញគាត់ហ្នឹងអណ្តែតទឹក វាអារកហ្នឹង ឃើញដាច់អានេះឡើងចំហ វានៅអណ្តែតអ៊ីចឹងហើយ រួចអណ្តែតគាត់ហ្នឹង មិនដឹងយ៉ាងម៉េចទេ វាចេះតែវិលទៅវិលមកៗ អត់ទៅចុះក្រោមទេ។ វាហូរឡើងលើទៅវិញទៅ វាចុះក្រោមទៅ វាហូរឡើង ដូចថាឡើងចុះៗ។ ដូចថាវិញ្ញាណមនុស្សហ្នឹងវាអត់ចង់ទៅណាទេ ចង់នៅតែកន្លែងហ្នឹងហើយយ៉ាងមើលទៅនោះ។ ឈ្មោះ បងថូ។

[១៤:២៧:២២]

**ស៖** អម្បាញ់មិញ អ្នកមីងថាពាក់ព័ន្ធនឹង បានន័យគេមានកូនក្មេងស្លាប់អណ្តែតទឹក ច្រកបាវ។ ធ្វើម៉េចបានដឹងរឿងហ្នឹង?

**ឆ៖** ហេតុការណ៍ហ្នឹង ខ្ញុំឃើញតែនៅក្នុងទឹកទេ ខ្ញុំឃើញជាក់ស្តែង ខ្ញុំអត់ចេះនិយាយភូតកុហកទេ ខ្ញុំឃើញប៉ុនណា ខ្ញុំឆ្លើយប៉ុណ្ណឹងតែម្តងហើយ។ ខ្ញុំថាយ៉ាងម៉េច គឺថាអ៊ីចឹងតែម្តងហើយ។ ឃើញនៅក្នុងទឹកហ្នឹងតែម្តង ពីព្រោះថាឃើញវាហើមអស់ទៅហើយ ឃើញតែបាវនៅក្នុងបាវហ្នឹងហើយ ជួនណារហែក។ រួចចំណែកបង ថូ ហ្នឹងខ្ញុំនៅស្គាល់មុខគាត់ច្បាស់ បានដឹងថាបង ថូ នោះ។

**ស៖** អរគុណ។ អម្បាញ់មិញ ខ្ញុំចង់បញ្ជាក់អារឿងថាកូនក្មេងហ្នឹង ហើយអ្នកមីងបានបញ្ជាក់ថា នៅបាវ ជួនកាលរហែកបាវ។ អ៊ីចឹងមានន័យថារហែកបាវបានយើងឃើញកូនក្មេង ឬមួយយ៉ាងម៉េច?

**ឆ៖** វារហែកបាវខ្លះទៅ ជួនវាអត់រហែកទៅ ប៉ុនយើងដឹងមនុស្សហ្នឹងថាវាច្រកបាវ។ ខ្ញុំមិនឃើញវាច្រកទេណា ប៉ុន្តែវាឃើញនៅក្នុងបាវហ្នឹងណ៎ា។ កាលហ្នឹង វាកំពុងពេញនិយមសម្លាប់មនុស្សអណ្តែតពេញទន្លេ ទឹកខ្ញុំមិនចង់ផឹកទេ។

**ស៖** ចំណុចមួយទៀត ដែលអ្នកមីងថា ឃើញគេចងជាទាហាន ឬយ៉ាងម៉េច? មានស្អីសម្គាល់ថាជាទាហាន?

**ឆ៖** ជាសម្គាល់ទាហាន ខ្ញុំដឹងថាយោធាវាស្លៀកពាក់ខោអាវទាហានហ្នឹងហើយ វាដោតទាំងខោអាវទាំងអីហ្នឹង វាចងទម្លាក់ទឹក វាដោតទាំងស្បូៗនោះ។ វាមិនឲ្យយើងនេះណ៎ា ស្លៀកពាក់ខោអាវយោធាទាំងអស់ហ្នឹង ពួកអណ្តែតទឹកដែលគេចងស្បូនោះ ដឹង បានដឹងថា យោធា – យោធាបូព៌ាគេសម្លាប់ចោល វាអត់ទុកទេ។

**ស៖** ខោអាវពណ៌ខ្មៅ ឬមួយខោអាវពណ៌អី?

**ឆ៖** ខោអាវនោះមិនមែនខ្មៅទេ ខោអាវទាហានពណ៌ស្លឹកឈើ ដូចប៉ាវ៉ាអីចឹង ដូចខោអាវប៉ាវ៉ាអីចឹង កាលហ្នឹងនោះ។ ពណ៌ខៀវ កាលនុ៎ង។

**ស៖** ចុះអ្នកមីងថា ឃើញមានស្លាមអារក តើឃើញតែម្នាក់នុ៎ង ឬមួយឃើញអណ្តែតទឹកហ្នឹងឃើញច្រើន?

[១៤:៣១:១៨]

**ឆ៖** អណ្តែតទឹកហ្នឹងឃើញតែម្នាក់ បងថូ ដែលឃើញគេអារកហ្នឹង ខ្ញុំស្គាល់ឈ្មោះណ៎ា ក្រៅពីហ្នឹង ខ្ញុំអត់ស្គាល់ទេ ដឹងពីណាខ្លះទេ ខ្ញុំអត់ដឹងទេ ខ្ញុំស្គាល់ទេ។ ឃើញតែមនុស្សអណ្តែតទឹក។ វាឃើញអីចឹង។ អត់ឃើញគេសម្លាប់ទៀត ឃើញតែមនុស្សអណ្តែតទឹកទេ។

**ស៖** បាទ អរគុណ។ ខ្ញុំនៅតែសំណួរពីរទៀត ថាតើនៅពេលដែលអ្នកមីងត្រូវគេឲ្យមកធ្វើការងារនៅតាមភូមិតាមអីហ្នឹងហើយ ឃើញព្រឹត្តិការណ៍ហ្នឹង។ ដល់ពេលដែលឃើញព្រឹត្តិការណ៍ហ្នឹងហើយ បានត្រឡប់ទៅនៅភូមិទ្រាហ្នឹងវិញ ឬមួយទៅនៅកន្លែងណាវិញ?

**ឆ៖** កាលហ្នឹង ខ្ញុំ កាលហ្នឹង ខ្ញុំធ្លាប់ធ្វើការនៅក្នុងរយៈកាលវាប្រើពួកខ្ញុំហ្នឹង ខ្ញុំមិនទាន់ចូលព្រៃទេណ៎ា ខ្ញុំទៅនៅភូមិទ្រាវិញ។ បានរយៈកាលបីថ្ងៃ បានខ្ញុំរត់ចូលព្រៃនោះ។ ខ្ញុំលែងនៅហើយ ខ្ញុំថាស្លាប់នៅក្នុងព្រៃក៏ស្លាប់ទៅចុះ។ អ្នកណាបាញ់ខ្ញុំស្លាប់នៅក្នុងព្រៃ ក៏ខ្ញុំ ដូចថាខ្ញុំសប្បាយចិត្ត ខ្ញុំនឹងគ្មានអីទាក់ទាញទាស់ចិត្តអីកន្លែងណាទេ កុំឲ្យតែពួកហ្នឹងវាចាប់ខ្ញុំយកទៅចងអារកម្តងទៀត ខ្ញុំអត់ចង់បានទេ

អាហ្នឹង ខ្ញុំរត់ស្លាប់នៅកន្លែងណាស្លាប់ទៅ ខ្ញុំលែងគិតហើយ កាលហ្នឹងនោះ។ ខ្ញុំទៅនៅក្នុងព្រៃនោះ វាបាញ់ខ្ញុំមួយថ្ងៃ ជួនណា វាទៅជាន់ព្រៃ វាទៅរកពួកខ្ញុំមួយថ្ងៃម្តង ពីរដង រត់ជាមួយពួកវានេះ ស្គាកស្គាមនៅទេនេះ។ នេះ! ជើងខ្ញុំនៅស្នាមទេនេះ។ បុកគល់ឈើ និយាយពីឃើញតែឆ្អឹង អត់មានឈាម អត់មានអីទេ របេះសាច់មិនដឹងទៅខាងណាទេ។

**ស៖** បាទ អរគុណ។ ខ្ញុំចង់ទៅត្រឡប់ទៅកន្លែងភូមិទ្រាហ្នឹងបន្តិច ថាតើនៅក្នុងភូមិទ្រាហ្នឹងពេលដែលនៅផ្ទះក្បៀងហ្នឹង អ្នកមីងថាមានពួគេអូសច្រវាក់ក្រោកៗម៉េច? បានន័យថានៅកន្លែងហ្នឹងមានមន្ទីរឃុំឃាំង ឬមួយយ៉ាងម៉េច?

[១៤:៣៤:៣៨]

**ឆ៖** នៅភូមិទ្រា កន្លែងភូមិទ្រាហ្នឹង មន្ទីរឃុំឃាំងយោធាក៏នៅកន្លែងហ្នឹង អ្នកធ្វើការថៅហ្វាយស្រុកស្អីៗនៅកន្លែងហ្នឹងទាំងអស់។ ឃុំឃាំងហ្នឹងក៏នៅកន្លែងហ្នឹងដែរ។ ដូចថាអ្នកគេយកទៅហ្នឹង គេយកទៅចូលនៅក្នុងភូមិទ្រាហ្នឹង គេដាក់ផ្ទះមួយៗនុំងហើយ ដូចថាម៉ាផ្ទះ ដូចថាជួនណា ១០នាក់អីចឹងផ្ទះតូចតាមផ្ទះតូចផ្ទះធំណ៎ា គេដាក់អីចឹង។

**ស៖** បាទ អរគុណ។ ខ្ញុំចង់ឲ្យអ្នកមីងជម្រាបទៅអង្គជំនុំជម្រះម្តងទៀត ពាក់ព័ន្ធហេតុអ្វីបានជាអ្នកមីងនឹកឃើញថា ឆ្លើយថាកូនខ្មែរ?

**ឆ៖** នឹកឃើញថាអីចេះ ខ្ញុំឆ្លើយថាកូនខ្មែរហ្នឹងដើម្បីថា បើសិនណាជាថាកូនខ្មែរទៅ វាឲ្យយើងនៅរស់ វាអត់យកយើងទៅទេ។ បើឆ្លើយថាកូនចាមហ្នឹង វាយកទៅអស់។ ដល់អីចឹងខ្ញុំចង់ឆ្លើយថាពេលហ្នឹងខ្ញុំក៏ថាអស់សង្ឃឹមដែរ ថាអស់ហើយ ថាខ្ញុំស្លាប់យប់ហ្នឹងហើយ ប៉ុនថាខ្ញុំហ្នឹងដូចនឹកឃើញយ៉ាងម៉េចទេ អាយុជីវិតខ្ញុំហ្នឹងវាថ្លៃ។ ខ្ញុំថា ខ្ញុំឆ្លើយថាកូនខ្មែរទៅ បានខ្ញុំឆ្លើយថាកូនខ្មែរម្តងទៅចុះ សាកមើលទៅខ្លាចវាបានរស់។ រួចដល់ខ្ញុំឆ្លើយទៅ អើវាបានដូចបំណងខ្ញុំឃើញនៅថាហ្នឹងណ៎ា។

**ស៖** បាទ អរគុណ។ ថាតើនៅពេលដែលក្រោយមក បែកឆ្នាំមួយពាន់ប្រាំបួនរយ -- ថ្ងៃ០៦ មករា ១៩៧៩ អ្នកមីងវិលត្រឡប់មកភូមិវិញដែរអត់ទេ?

[១៤:៣៦:៣០]

**ឆ៖** ដាច់ពីអាពតមកហ្នឹងដូចថា ខ្ញុំត្រឡប់មកៗ ខ្ញុំទៅនៅស្ទួង ខាងរណសិរ្សសាមគ្គីសង្គ្រោះជាតិហ្នឹង គេជួយពួកខ្ញុំ គេយកពួកខ្ញុំទៅនៅមួយកន្លែង។ ទៅនៅបានប្រហែលកន្លះខែ បានខ្ញុំនៅមិនសុខខ្ញុំចេះតែនឹកឃើញថាម៉ែឪមកវិញហើយ ខ្ញុំសុំច្បាប់គេ ខ្ញុំដើរពីស្ទួងទៅដល់ក្រូចឆ្មារ ស្វាយឃ្លាំងនេះ

បីថ្ងៃបានមកដល់ផ្ទះ មកអត់ឃើញបងប្អូនទេ មីងមាស្លាប់អស់រលីង គ្មានសល់ទេ គ្មានឃើញអ្នកណាម្នាក់ទេ។ មានដែរ ដែលអ្នកប្រជាជននៅក្នុងភូមិគេជម្លៀសទៅខាងណេះខាងណោះទៅ វាសេសសល់មួយគ្រួសារ ពីរគ្រួសារទេមកនៅហ្នឹងនោះ។ សួរថាម៉ែឪខ្ញុំ ឃើញម៉ែឪខ្ញុំមកដែរ? ថាអត់ឃើញទេ។ ខ្ញុំកន្លែងហ្នឹង ខ្ញុំអង្គុយយំ ស្រក់ទឹកភ្នែក ខ្ញុំនឹកប្អូនខ្ញុំ ពេលណាខ្ញុំឃើញដែលគេដាក់នៅក្នុងទូរទស្សន៍ ដាក់ខ្មែរក្រហម ដូចថាគេឃើញពួកនៅក្មេងៗគេយកទៅធ្វើបាបអី ខ្ញុំអង្គុយយំមួយយប់ទាល់ថ្ងៃ មួយថ្ងៃទាល់យប់។ ខ្ញុំគ្មានពេលណា ដូចថា ទឹកភ្នែកខ្ញុំហូរ ហូរទាល់រាល់ថ្ងៃនេះ ភ្នែកខ្ញុំមើលមិនសូវឃើញទេ ស្រពេចស្រពិលអស់ហើយ ខ្ញុំនឹកដោយសារបងប្អូន ម៉ែឪខ្ញុំស្លាប់អស់ ខ្ញុំនៅម្នាក់ឯង។ ពេលណាខ្ញុំនឹកឃើញគាត់មក ខ្ញុំអង្គុយយំតែម្តងហើយ។

ជួនណាខ្ញុំទៅស្រែកនៅវាលស្រែ អត់ដឹងអីទេ ដូចថាមនុស្សវាបាត់ការចងចាំហើយ បានខ្ញុំទៅស្រែកនៅវាលស្រែម្តងៗ។ កាលណាខ្ញុំទៅស្ទូងស្រូវអី ខ្ញុំស្រែកច្រៀងដូចមនុស្សឆ្កួតអ៊ីចឹង គ្មានដឹងអីទេ អត់ដឹងខ្លួនថាច្រៀង អត់ដឹងអី។ ទាល់តែគេសួរថាយ៉ាងម៉េច បានវាស្រែកអ៊ីចឹង? អត់ទេ ខ្ញុំមានស្រែកពីណា ខ្ញុំគ្មានទៅស្រែកពីណា ខ្ញុំដើរមកតើ។ នេះហើយការដែលខ្ញុំពិបាកវេទនាតាំងពីនោះមក ខ្ញុំដូចថាឆ្អែតឆ្អន់ដល់គ្មានអ្វីផ្ទឹមមិនបានទេ។ រួចខ្ញុំមកនៅផ្ទះហ្នឹង ខ្ញុំយក ខ្ញុំទើបមកយកគ្រួសារ រៀបការចេញអាពតមក ខ្ញុំរៀបការ បានកូនចៅទៅហ្នឹង បានដូចថាវាធូរចិត្តម្តងបន្តិចៗទៅ។ ប៉ុន្តែថាឲ្យខ្ញុំភ្លេច ខ្ញុំអត់ភ្លេចសោះហើយ ខ្ញុំអត់ភ្លេចទេ រាល់ថ្ងៃនេះ ខ្ញុំមិនភ្លេចទេ។ កន្លែងណាដែលគេធ្វើបាប ខ្ញុំនៅនឹកឃើញកន្លែងហ្នឹងហើយ ខ្ញុំគ្មានថ្ងៃណាបំភ្លេចបានទេ។

[១៤:៣៨:៥៤]

**ស៖** បាទ អរគុណ។ ចំណុចចុងក្រោយបំផុត គឺថាតើអ្នកភូមិដែលបានជម្លៀសចេញពីហ្នឹងទៅ ហើយពេលដែលអ្នកមីងមកក្នុងភូមិវិញនេះ ដែលជម្លៀសទៅជាមួយឪពុកម្តាយ ប្អូនអីដែលបាត់អស់ហ្នឹង តើអ្នកដែលទៅជាមួយគាត់ហ្នឹងមានមកវិញខ្លះដែរអត់ទេ?

**ឆ៖** ទៅជាមួយម្តាយ ជាមួយពួកខ្ញុំហ្នឹង ម៉ែៗខ្ញុំ ម្តាយខ្ញុំ ប្អូនខ្ញុំអត់មានមកវិញទេ អស់ហើយ។ បានគេតែអ្នកជម្លៀស ដូចថាគេជម្លៀសទៅនៅក្នុងឃ្លាំងឡហ្នឹង រួចគេបែងចែកទៅនៅស្រុកនេះ ស្រុកនោះ ភូមិនេះ ភូមិនោះទេ ដូចថាវាមានសេសសល់ខ្លះ បានមកនៅហ្នឹងនោះ។ បើចំណែកពួកខ្ញុំហ្នឹង ទៅអស់ហើយ នៅមួយក្រុម មួយជួរពួកខ្ញុំដែលនៅជួរដងទន្លេហ្នឹង គេប្រមូលអស់ហើយ អត់មានទេ។

**លោក ឡៅ ជុនធី៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំបាទអស់សំណួរហើយ ហើយខាងខ្ញុំអត់មានសំណួរបន្តទៀតទេ។ សូមអរគុណអ្នកមីង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះ -- ដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឱ្យអញ្ជើញគាត់រួមទាំងបុគ្គលិកនៃអង្គជំនុំជម្រះគាំពារសាក្សី និងអ្នកជំនាញចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងបី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤០ នាទី ដល់ម៉ោង ១៥:០២ នាទី)*

[១៥:០២:១៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្ដល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ មានទេ?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

លោកប្រធាន គឺអត់មានសំណួរទេ។ សូមវេទិកាជូនសហព្រះរាជអាជ្ញាលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ តទៅនេះ សូមផ្ដល់វេទិកាជូនទៅសហព្រះរាជអាជ្ញាដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរូបនេះ។

**លោក ស្រ៊ា រតនះ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងភាគីទាំងអស់ដែលមានវត្តមាននៅសវនាការនេះ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ស្រ៊ា រតនៈ៖**

**ស៖** សូមជម្រាបសួរលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី! ខ្ញុំឈ្មោះ ស្រ៊ា រតនៈ ជាសហព្រះរាជអាជ្ញារងជាតិ។ ខ្ញុំបាទមានសំណួរពីរបីសំណួរ ដើម្បីសួរពាក់ព័ន្ធនឹងហេតុការណ៍ដែលកើតឡើងចំពោះលោកស្រីនៅឯភូមិទ្រា។ ខ្ញុំចង់ដឹងថា នៅពេលលោកស្រីទៅដល់ផ្ទះមួយនៅឯភូមិទ្រានោះ ផ្ទះហ្នឹង តើផ្ទុក នៅពេលលោកស្រីទៅដល់មានអ្នកផ្សេងនៅក្នុងហ្នឹងទេ?

**លោកស្រី នោ សាទះ៖**

**ឆ៖** អត់មានទេ កាលខ្ញុំឡើងទៅហ្នឹង អត់មានមនុស្សនៅទេ ប៉ុន្តែខ្ញុំឃើញដូចថាក្រវិល ដូចជាក្រវិល ហើយនិងចិញ្ចៀនអីនៅជាប់នឹងអី ដាក់នៅនឹងរបាំងជញ្ជាំង។ ដោះ ដូចថាដោះចោលនៅកន្លែងហ្នឹង រួចក្រវិលអី ក្រវិលពាក់អីហ្នឹងជាប់នៅរនាប ឃើញហេតុការណ៍តែប៉ុណ្ណឹង។ ពួកខ្ញុំឡើងទៅនោះ។

**ស៖** ចុះចំពោះអ្នកដែលធ្វើដំណើរទៅជាមួយលោកស្រីហ្នឹង គេយកទៅដាក់តែក្នុងផ្ទះហ្នឹងតែមួយ ឬក៏មានបំបែកគ្នាទៅផ្ទះផ្សេងៗទៀត?

**ឆ៖** គេអត់បំបែកទៅណាទេ គេដាក់នៅក្នុងផ្ទះហ្នឹងទាំងអស់។

**ស៖** នៅចំណុចមួយទៀត លោកស្រីបានមានប្រសាសន៍ជម្រាបអង្គជំនុំជម្រះមុននេះបន្តិចតាមរយៈសំណួររបស់លោកមេធាវី ថាលោកចៅហ្វាយស្រុកឈ្មោះ ហូ ឡើងមកសួរក្រុមលោកស្រី តើនៅពេលនោះ ហេតុអ្វីបានលោកស្រីស្គាល់ថាគាត់ឈ្មោះ ហូ ជាចៅហ្វាយស្រុក?

**ឆ៖** ហេតុអីយ៉ាងម៉េច បើគាត់នៅធ្វើការ គាត់ប្រាប់ខ្ញុំដឹងថាគាត់នៅធ្វើការអ្នកចៅហ្វាយស្រុកថ្មីមកនៅត្រើយម្ខាងមកៗឈរឈ្មោះនៅកន្លែងហ្នឹងហើយ ចៅហ្វាយស្រុក ហូ ហ្នឹងប្រធាន, អនុប្រធានហ្នឹងឈ្មោះៗអីទេ ភ្លេចទៀតទៅហើយ អនុប្រធានឈ្មោះ ជឹម -- អ្នក ឈ្មោះ ផែនៗ, សមាជិកហ្នឹងឈ្មោះ ជឹម។ ដឹងតែប៉ុណ្ណឹង ហើយនិងយោធាប៉ុន្មានៗ ខ្ញុំអត់ស្គាល់ឈ្មោះវាទេ មន្ទីរវាហើយកន្លែងហ្នឹងនោះ។

**ស៖** សំណួរខ្ញុំអម្បាញ់មិញនេះចង់ជម្រាបសួរលោកស្រីថា ហេតុអីបានលោកស្រីស្គាល់គាត់ថាគាត់ហ្នឹងជាចៅហ្វាយស្រុក?

**ឆ៖** ខ្ញុំស្គាល់តាមពួកយោធាហ្នឹងហើយ គេថាចៅហ្វាយស្រុកៗ អនុចៅហ្វាយស្រុក សមាជិកខ្ញុំស្គាល់តែប៉ុណ្ណឹង ហូ ហ្នឹងតើអ្នកប្រធានគេនោះ ចៅហ្វាយស្រុកហ្នឹងនោះ គេប្រកាសហើយតើ គេ

ប្រាប់ហើយតើ គេដឹងថាអ្នកនេះគេហៅទៅដូចថានេះនោះ គេប្រាប់ថាខ្ញុំឈ្មោះគេធ្វើអ្នកធ្វើការនៅកន្លែងនេះ នៅទីតាំងនៅភូមិទ្រានេះ អ្នកប្រធានគេដែលថៅហ្វាយស្រុកហ្នឹងឈ្មោះ ហូ ហ្នឹងហើយ។

[១៥:០៧:១២]

**ស៖** នៅចំណុចមួយទៀតគឺពាក់ព័ន្ធនឹងអ្នកដែលឆ្លើយថាចាម ហើយលោកស្រីថាត្រូវបានគេនាំចុះទៅក្រោម។ តើនៅពេលនោះ មានចំនួនប៉ុន្មាននាក់ដែលឆ្លើយថាចាម? ហើយប៉ុន្មាននាក់ដែលឆ្លើយថាខ្មែរ?

**ឆ៖** វាច្រើនណាស់មនុស្សហ្នឹងនៅក្នុងផ្ទះហ្នឹង វាមិនមែនតិចទេ ប្រហែលជា៣០០នាក់ ចាមអ្នកឆ្លើយថាចាមហ្នឹងឆ្លើយទៅមុនខ្ញុំហ្នឹងទៅអស់ហើយនៅសល់ប្រហែល៣០នាក់មកដល់ខ្ញុំហ្នឹងណ៎ា នៅសល់ ខ្ញុំឆ្លើយទៅ ខ្ញុំថា ខ្ញុំនឹកឃើញថាឆ្លើយទៅក្រែងថាវាបាននៅរស់រានមានជីវិតវិញ ចង់មើលដូចថាប្រទេសជាតិវាយ៉ាងម៉េចវិញណាស់ រួចដល់ខ្ញុំឆ្លើយទៅ យប់ណាកាលហ្នឹង មិនមែនភ្លឺអីចឹងទេ យប់អត់មើលមុខគ្នាឃើញទេ វាច្របាច់ពិលមើលខ្ញុំ វាថា អេ្ហ!មិនមែនកូនខ្មែរទេ កូនយួនទេអី? ខ្ញុំថាអត់ទេ ខ្ញុំកូនខ្មែរ! វាច្របាច់ម្ដងទៀត ថៅហ្វាយស្រុក ហូ ហ្នឹងណា វាថា អេ្ហ!កូនយួនទេ មិនមែនកូនខ្មែរទេអី? អត់ទេខ្ញុំកូនខ្មែរ ខ្ញុំស្រែកខ្លាំងអីចឹងទៅ ប្រាប់វាពីរដងវាមិនព្រមទេ ឡើងទៅបីដង បានខ្ញុំថាៗ ខ្ញុំកូនខ្មែរហើយ ថាយ៉ាងម៉េចទៀត! បានគេព្រម គេថាឲ្យខ្ញុំនៅម្ខាង។ រួចដល់មកក្រោយៗមក ពួកហ្នឹងវាឆ្លើយតាមខ្ញុំដែរ បងដែលអ្នកក្រុមទៅជាមួយខ្ញុំហ្នឹងនៅស្រុកភូមិជាមួយគ្នាហ្នឹង គេប្រាប់ថាវាឆ្លើយតាមខ្ញុំដែរ គេសួរគេវាថាឆ្លើយថាកូនខ្មែរៗហ្នឹងបាននៅសល់ថា៣០នាក់ចុះ ថាអីចឹងទៅចុះ។

[១៥:០៩:០២]

**ស៖** ចុះបន្ទាប់ពីយប់នោះមក មានការតាមដានបន្តទៀតទេដែលនៅពេលនោះគេអត់ជឿលោកស្រីភ្លាមថាជាកូនខ្មែរហ្នឹង ហើយលោកស្រីបានឆ្លើយជម្រាបជូនអង្គសវនាការមុននេះថាគេទុកលោកស្រីនៅរយៈពេលប្រាំបួនថ្ងៃ អីចឹងក្នុងចន្លោះពេលនេះមានការតាមដានបន្តទៀតទេ?

**ឆ៖** គេនៅតែតាមដានយើងហ្នឹងហើយ ប៉ុន្តែគេនៅគេៗដឹង គេថាពួកខ្ញុំហ្នឹងមកហ្នឹងវាមានមូលហេតុ ហេតុការណ៍ហើយណា អ្នកស្រុកភូមិអីចឹងណាគេអាណិតដែរ ប៉ុន្តែគេប្រាប់ថាខ្ញុំហ្នឹងកូនខ្មែរមែន វាទៅស៊ើបសួរនៅក្នុងភូមិៗខ្ញុំនៅអីនោះ វាទៅសួរថាកូនចាម កូនខ្មែរ។ គេអ្នកស្រុកភូមិហ្នឹងគេអាណិតពួកខ្ញុំ គេដឹងថាពួកខ្ញុំហ្នឹងគេថាកូនខ្មែរទេ យកទៅច្រឡំ គេនិយាយអីចឹងណា ដូចម៉ែធម៌ខ្ញុំយាយហៀង អីហ្នឹង ខ្មោចយាយហៀង អីនោះ គាត់និយាយប្រាប់អីចឹងណា។

**ស៖** ចុះនៅក្នុងចំណោមអ្នកដែលនៅសល់ហ្នឹងមានត្រូវបានរកឃើញបន្តទៀតទេ?

**ឆ៖** សូមឲ្យលោកសួរម្តងទៀត ខ្ញុំស្តាប់អត់បាន។

**ស៖** ចុះនៅក្នុងចំណោមដែលលោកស្រីលើកឡើងខាងដើមអំមិញថា ប្រហែលជា៣០នាក់ដែល ឆ្លើយថាខ្មែរហ្នឹង តែបន្តមកទៀតហ្នឹងគេមានរកឃើញថាចាមៗដែរឬទេ?

**ឆ៖** អត់មានរកទេថា អត់មានពីណាគេនៅនេះទេណា ប៉ុន្តែម្នាក់ៗហ្នឹងប្រឹងត្បុលរត់គេច អត់មាននៅមួយកន្លែងទេ គេរត់អស់ហើយ។ គេនៅខ្លាចវាសម្លាប់ម្តងទៀត។

[១៥:១១:១៣]

**ស៖** ចំណុចមួយទៀត តើលោកស្រីដឹងថាមានអ្វីកើតឡើងចំពោះអ្នកដែលឆ្លើយថាចាម ហើយគេនាំចុះមកក្រោមផ្ទះនោះ?

**ឆ៖** គេសួរថាអ៊ីចឹង ខ្ញុំអត់ដឹងអីទេ ខ្ញុំអត់មានដឹងចម្លើយអីទេ ប៉ុនថា គេសួរថា កូនចាមចុះៗៗហ្នងហើយ។ ដល់មកពួកខ្ញុំឆ្លើយថា កូនខ្មែរហ្នឹងគេឲ្យយើងនៅ។

**ស៖** អ្វីៗដែលខ្ញុំចង់ដឹងពីលោកស្រីហ្នឹង គឺចង់ដឹងថាតើចុះមកៗហ្នឹងមានអ្វីកើតឡើងចំពោះពួកគេ លោកស្រីមានជ្រាបទេរឿងនេះ?

**ឆ៖** ខ្ញុំឃើញគេនាំចុះមកហ្នឹង ឃើញអ្នកដែលនាំជញ្ជូនមនុស្សហ្នឹងឆ្លើយថាកូនចាមហ្នឹងណ៎ាឃើញកាន់កាំបិតក្តុកៗហ្នឹង មួយដើម ហើយនិង អាកា ស្វាយបត់ហ្នឹងមួយដើម។ អាហ្នឹងយោធាអ្នកនាំទៅ។ ឃើញតែប៉ុណ្ណឹង នាំចុះៗៗទៅរហូត ទាល់សព្វថ្ងៃនេះអត់ឃើញមកវិញទេ។

**ស៖** ខ្ញុំមានឯកសារពីរដែលលោកស្រីធ្លាប់បានឆ្លើយបី ដែលនៅក្នុងនោះ មានឯកសារពីរដែលលោកស្រីបានឆ្លើយ គឺឯកសារ E3/9333 ដែលមាន ERN ជាភាសាខ្មែរ 00204450, ERN ជាភាសាអង់គ្លេស 00204453 និងជាភាសាបារាំង 00224116។ លោកស្រីបានរៀបរាប់ថា៖ "ខ្ញុំឃើញខ្មែរក្រហមបណ្តើរនារីម្នាក់ដែលមានចងក្រមានៅនឹងក្បាលសំដៅទៅមាត់ទឹកទន្លេនៅខាងមុខផ្ទះ។ ពេលទៅដល់ខ្មែរក្រហមម្នាក់បានទាញចុងក្រមាឲ្យនារីនោះងើបក្បាលឡើងលើ រួចដកកាំបិតមួយសស្វាចអារបំពង់ក ហើយច្រានទម្លាក់ក្នុងទឹកទន្លេ។ អ្នកជាបន្តបន្ទាប់មកទៀត ក៏ត្រូវបានសម្លាប់តាមវិធីតែមួយដូចៗគ្នារហូតដល់អស់គ្មានសល់ម្នាក់ ដោយគ្មាននរណាម្នាក់រើបម្រះ ឬស្រែកឡើយ។" ជាមួយគ្នានេះ នៅក្នុងឯកសារ E305/13/1.3.23 ដែលមាន ERN ជាភាសាខ្មែរ 00045908 ដល់ 09 និង ERN ជាភាសាអង់គ្លេស 01132817 និង ERN ជាភាសាបារាំង 01128403។ នៅពេលនោះលោក

ស្រីបានឆ្លើយនៅចំពោះមុខលោក ឧស្មាន ថា ខ្ញុំសូមដកស្រង់៖ "សំណួរ៖ ហេតុអ្វីបានជាបងដឹងថាគេយកទៅវាយចោល? អើ ឃើញនឹងភ្នែកគេអារកទម្លាក់ទឹកហើយតើ ផ្ទះនៅមាត់ច្រាំង ហើយពេលនោះខែទឹកឡើង។" បញ្ចប់ការដកស្រង់។ សូមដកស្រង់៖ "ពេលគេយកទៅនោះបងឃើញយ៉ាងដូចម្ដេចខ្លះ?" ឃើញៗផ្ទាល់នឹងភ្នែកពេលវាយកទៅដៃយើងជាប់ហើយ វាទាញក្រមាឲ្យងើយក្បាលឡើងអ៊ីចឹងទៅ វាអារកទម្លាក់តែម្ដងនៅត្រង់មាត់ទឹក អត់មានបាញ់អីទេ"។ ទន្ទឹមនឹងនេះដែរនៅក្នុងឯកសារ E3/5193 ដែលមាន ERN ជាភាសាខ្មែរ 00204445, ជាភាសាអង់គ្លេស 00274704, ជាភាសាបារាំង 00224113។ លោកស្រីឆ្លើយថា ខ្ញុំ -- លោកស្រីបានឆ្លើយនៅចំពោះមុខអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតថា "ខ្ញុំមិនបានឃើញការសម្លាប់ដោយផ្ទាល់ភ្នែកទេ ប៉ុន្តែមានមនុស្សម្នាក់ដែលបានឃើញការសម្លាប់នេះនិយាយប្រាប់ខ្ញុំ"។ ខ្ញុំបញ្ជាក់ថា ឯកសារដែលខ្ញុំអានចុងក្រោយនេះ គឺលោកស្រីបានធ្វើការកែតម្រូវទាំងស្រុងអំពីអ្វីដែលលោកស្រីបានឆ្លើយនៅចំពោះមុខលោក ឧស្មាន ដែលឆ្លើយថា "ឃើញផ្ទាល់ភ្នែក" ហើយមកឆ្លើយថា "អត់ឃើញទេវិញ" ដោយបញ្ជាក់ថាកាលនោះខ្ញុំប្រាប់លោក ឧស្មាន ថា "ខ្ញុំឃើញការសម្លាប់នេះ ពីព្រោះខ្ញុំចង់រកយុត្តិធម៌ប្រឆាំងនឹងពួកឃាតករ"។ តើកន្លែងនេះលោកស្រីមានការអះអាងយ៉ាងដូចម្ដេចដែរ? ថាតើលោកស្រីចង់រកយុត្តិធម៌ទើបលោកស្រីឆ្លើយប្រាប់តាមត្រង់ដល់មន្ត្រីតុលាការ?

[១៥:១៦:៥០]

**ឆ៖** ខ្ញុំចង់ឃើញយុត្តិធម៌ហ្នឹង ក៏ប៉ុន្តែខ្ញុំឆ្លើយពេលហ្នឹងៗខ្ញុំក៏ឆ្លើយយ៉ាងម៉េចខ្លះទេ ខ្ញុំភ្លេចភ្លាំងអស់ហើយ។ ខ្ញុំចាំតែកន្លែងណាដែលខ្ញុំឃើញ ដូចថាៗខ្ញុំចាំ ខ្ញុំនៅចាំ កន្លែងណាខ្ញុំភ្លេចៗ ខ្ញុំគ្មានពេលណាមកនេះទេ ប៉ុន្តែឃើញចង់បានយុត្តិធម៌ គឺថាចង់បានតែម្ដង ពីព្រោះខ្ញុំហ្នឹងដូចថាវាបាត់បង់អស់ទៅហ្នឹងដូចថាមនុស្សម្នាក់មិនមែននៅគ្រប់ដប់ទាំងអស់ទេ។ ដែលពាក្យសម្ដីដែលខ្ញុំនៅឆ្លើយប្រាប់បងប្អូននេះ ខ្ញុំគ្មានឆ្លើយបំបិទភស្តុតាងមួយណាទេ ខ្ញុំឃើញនឹងភ្នែក ពាក្យដែលខ្ញុំនៅៗរៀបរាប់តាំងពីអើយមកនេះ។ ប៉ុន្តែកន្លែងថា អារក បំពង់ក អារអីហ្នឹង ឃើញដូចថា ម្នាក់បងធូ ហ្នឹងខ្ញុំនៅចំណាំមែន គាត់អណ្ដែតទឹកហ្នឹងឃើញចំហមាត់ កគាត់នេះនៅចំហ។ ខ្ញុំដឹង ខ្ញុំស្គាល់គាត់ៗហ្នឹងខ្សាច់ប្រឆេះក្រោម គាត់ហ្នឹងធ្វើជានារី ធ្វើប្រធាននារី គាត់ធ្វើខាងយុវជននោះ ខាងយុវជននារីនោះ បងធូ ហ្នឹង។ រួចដល់ពួកនិរតីមកហ្នឹងដឹងគាត់វាយកទៅធ្វើម៉េចបានតែឃើញ ស្រាប់តែឃើញអណ្ដែតទឹកហ្នឹងចុះឡើងៗហ្នឹងនៅនឹងមាត់ទន្លេនេះ។

**ស៖** សំណួរខ្ញុំចុងក្រោយនេះ ខ្ញុំចង់បានការបញ្ជាក់ពីលោកស្រី ហើយដោយខ្ញុំសូមរំឭកឡើងវិញថា លោកស្រីធ្លាប់ឆ្លើយប្រាប់ទៅលោក ឧស្មាន ថាលោកស្រីបានឃើញគេអារកអ្នកដែលនាំពីលើផ្ទះចុះទៅក្រោម ផ្ទុយទៅវិញលោកស្រីបានកែសម្រួលចម្លើយនេះ កែដោយខ្លួនឯងនៅចំពោះមុខអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតថា អត់បានឃើញទេ ដោយឮសួរថាមានអ្នកប្រាប់ទៅវិញ។ អ៊ីចឹងខ្ញុំសូមការបញ្ជាក់ពីលោកស្រីថា តើ -- ដោយលោកស្រីបញ្ជាក់ថា "ខ្ញុំប្រាប់លោក ឧស្មាន ថាបានឃើញការសម្លាប់នេះដោយសារចង់បានយុត្តិធម៌"។ អ៊ីចឹងខ្ញុំចង់បានការបញ្ជាក់ពីលោកស្រីថា លោកស្រីធ្វើការកែសម្រួលចម្លើយដោយខ្លួនឯងឡើងវិញនេះ ដោយសារលោកស្រីធ្វើ -- ដោយសារលោកស្រីឆ្លើយនៅចំពោះមុខមន្ត្រីតុលាការ ហើយចង់បានយុត្តិធម៌។ តើអ៊ីចឹងមែនទេ?

[១៥:១៩:២៨]

**ឆ៖** ឆ្លើយនៅមុខតុលាការ យើងមកហ្នឹងចង់បានយុត្តិធម៌ហ្នឹងហើយ បានខ្ញុំមកឆ្លើយនៅ -- ខំមករាប់សិបដងនេះ។

**ប្រធានអង្គជំនុំ៖**

ទំនងជាពិបាកយល់តាមសំណួរដែលសួរហ្នឹង។ សូមសហព្រះរាជអាជ្ញារងជាតិរៀបចំកែសម្រួលសំណួរឡើងវិញឱ្យបានច្បាស់លាស់ហើយងាយយល់។ ហើយរៀបរាប់យ៉ាងវែងមក ហើយដល់តាំងសំណួរហ្នឹងគឺពិបាកយល់។ យើងគិតថាពិបាកយល់ អាចឆ្លើយមិនត្រូវទេ មិនចំនឹងសំណួរទេ កាលណាវាពិបាកយល់។

**លោក ស្រ៊ា រតនៈ៖**

ខាងសហព្រះរាជអាជ្ញារងជាតិអស់សំណួរ លោកប្រធាន។ សូមការអនុញ្ញាតជូនវេទិកាទៅខាងសហព្រះរាជអាជ្ញារងអន្តរជាតិ បាទ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ!

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរ លោក លោកស្រីចៅក្រម ភាគីទាំងអស់។

[១៥:២០:៤២]

**សួរដោយលោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

**ស៖** ជម្រាបសួរលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំសួរសំណួរមួយចំនួនពាក់ព័ន្ធទៅនឹងពេលវេលាលោកស្រីស្នាក់នៅឯភូមិទ្រា។ តាមរយៈអ្វីដែលលោកស្រីរៀបរាប់កន្លងមកនេះ នៅពេលដែលនៅក្នុងផ្ទះមួយគេសួរលោកស្រីថា លោកស្រីចាម ឬក៏ខ្មែរ លោកស្រីឆ្លើយថាមានស្ត្រីទាំងអស់ប្រហែលជា៣០០នាក់ ហើយស្ត្រី៣០នាក់ បានឆ្លើយថា ពួកគាត់គឺជាជនជាតិខ្មែរ។ អ៊ីចឹងឯងបានជាគេមិនបានយកពួកគាត់ទៅបាត់នោះទេ។ ដូច្នេះខ្ញុំចង់សួរអំពីតួលេខនេះ ត្រូវ ឬក៏មិនត្រូវ ថាមានស្ត្រីទាំងអស់២៧០នាក់ ត្រូវបានគេនាំខ្លួនទៅបាត់នៅក្នុងយប់នោះ។ តើអ៊ីចឹងមែនទេ?

**លោកស្រី នោ សាទះ៖**

**ឆ៖** វាពិតជាអ៊ីចឹងមែនហើយ។ នាំទៅហ្នឹង អត់ឃើញយកមកវិញទេ អត់ គ្មានមកវិញទេ អ្នកដែលកូនចាមថា "កូនចាមចុះៗ" នោះ។

**ស៖** បាទ សូមអរគុណ។ លោកស្រីក៏បាននិយាយផងដែរថា នៅពេលអ្នកណាឆ្លើយថា ចាម ត្រូវបានគេយកនាំខ្លួនចេញទៅបាត់នោះ ហើយអ្នកដែលឆ្លើយថា ខ្លួនជាខ្មែរ រួមទាំងលោកស្រីផង គឺថាស្ថិតនៅក្រោមការតាមដាន គឺថាមានការតាមដាននៅតាមភូមិ<របស់លោកស្រីផ្ទាល់>។ លោកស្រីក៏បាននិយាយថា គេមានស្ងសម្លសាច់ជ្រូកឲ្យលោកស្រីហូបផង។ ខ្ញុំចាប់ផ្ដើមសួរត្រឹមថ្ងៃពេលគេស្ងសាច់ជ្រូក ឲ្យលោកស្រីហូបនោះ។ តើចៅហ្វាយស្រុកឈ្មោះ ហូ<> នេះ មានហូបចំណីអាហារសម្លសាច់ជ្រូកហ្នឹងជាមួយលោកស្រីដែរទេ ពេលដែលគេស្ងសាច់ជ្រូកឲ្យពួកលោកស្រីហូបនុ៎ង?

[១៥:២៣:០០]

**ឆ៖** ពួក គេហៅតែ គេឲ្យតែពួកខ្ញុំហូបមួយក្រុមពួកខ្ញុំហ្នឹង ៣០នាក់ហ្នឹង ហូ ហ្នឹងគេមិនបានមកហូបជាមួយយើងទេ ប៉ុន្តែគេឲ្យយោធាហ្នឹងនៅមើល ដូចថាយើងអង្គុយមួយជួរៗនៅហូបហ្នឹង បើយើងហូប មិនហូប គេដឹងហើយ។ បើយើងមិនហូបទេ យើងហ្នឹងចាមហើយ។ ខ្ញុំហូបសាច់ជ្រូកពេលហ្នឹងហើយ បានខ្ញុំហូប ចេះហូបនោះ។

**ស៖** ទោះបី ហូ មិនហូបសម្លនោះក៏ដោយ តើគាត់មានវត្តមាននៅទីនោះឬទេ នៅពេលដែលគេឲ្យពួកលោកស្រីហូបសម្លនោះ?

**ឆ៖** មាន គាត់នៅកន្លែងនោះហើយ គាត់នៅមើលខុសត្រូវនៅកន្លែងហូបហ្នឹងហើយ ទាំងចៅហ្វាយស្រុក ទាំងយោធាហ្នឹងហើយ ទាំង ហូ ហ្នឹង ទាំងយោធាហ្នឹង។

**ស៖** ក្នុងចំណោមស្ត្រី៣០នាក់ ដែលឆ្លើយថាពួកគាត់ជាជនជាតិខ្មែរ ក្នុងអំឡុងពេលដែលស្ត្រី

ចាមដទៃទៀតត្រូវបានគេនាំខ្លួនទៅបាត់នោះ តើលោកស្រីនិងស្ត្រីជនជាតិចាមដទៃទៀត និយាយគ្នាជាភាសាខ្មែរ ឬក៏និយាយគ្នាជាភាសាចាម?

**ផ៖** សុំសំណួរហ្នឹងសួរម្តងទៀត។

**ស៖** ស្ត្រី៣០នាក់ដែលបានឆ្លើយថា ពួកគាត់ជាជនជាតិខ្មែរ រួមទាំងលោកស្រីផង តើក្រុមលោកស្រី៣០នាក់ហ្នឹង និយាយគ្នាប្រើប្រាស់ភាសាខ្មែរ ឬក៏និយាយគ្នាដោយប្រើប្រាស់ភាសាចាម?

[១៥:២៥:០៥]

**ផ៖** ចាប់ពីពេលហ្នឹងទៅ និយាយខ្មែររហូត អត់មានពាក្យនិយាយចាមមួយម៉ាត់កន្លែងណាទេ រហូតតែម្តងហើយ ទាល់មកដាច់ ប៉ុល ពត នេះហើយបានមកនិយាយចាមវិញនេះ។

**ស៖** ហើយថាតើមានជនជាតិចាមណានិយាយខ្មែរដោយនិយាយជាមួយសំឡេង ឬក៏ថាតុងណាមួយដែលអាចឱ្យគេកត់សម្គាល់បានថាជាជនជាតិចាមដែរទេ?

**ផ៖** គេមិនសួរពិនិត្យ ត្រួតពិនិត្យទេណា ដូចថាយើងឆ្លើយថាប្រាប់ថាខ្មែរហើយណា។ កាលហ្នឹងពួកខ្ញុំហ្នឹងបើថាខ្មែរ គេដឹងថាខ្មែរហើយ និយាយខ្មែរអត់មានប៉ែឡាំអីទេ កាលហ្នឹងនោះ។ គេមិនសួរតាមដានយើងទេ។

**ស៖** សូមអរគុណ។ លោកស្រីក៏បានលើកឡើងថា <>ឃើញបុរសៗ គឺថាគេដាក់ខ្នោះជើងនៅក្នុងផ្ទះ<ទាំងនោះ គឺនៅជិតផ្ទះដែលលោកស្រីត្រូវបានឃុំខ្លួនដែរ គឺ>នៅភូមិទ្រា។ តើលោកស្រីធ្លាប់បានឃើញ ឬក៏បានដឹងថាបុរសៗដែលគេឃុំខ្លួននៅក្នុងផ្ទះទាំងនោះហ្នឹង ដែលត្រូវបានគេយកទៅណា ឬក៏ធ្វើយ៉ាងណានោះទេ?

**ផ៖** ខ្ញុំអត់ទេ ប៉ុនថា ឃើញបាត់ផ្ទះពីរបីហ្នឹង គេយកទៅអស់រលីង ពួកបុរសៗហ្នឹងណា មិនដឹងទៅខាងណាទេ អត់ឃើញគេសម្លាប់ទេ ប៉ុន្តែអត់ឃើញមនុស្សទេនៅលើផ្ទះហ្នឹងនោះ។

**ស៖** លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំសូមអានចម្លើយរបស់លោក<ស្រី>នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឺ E3/4705, ERN ជាភាសាអង់គ្លេស 00417852, ខ្មែរ 0036 9026, និងបារាំង 00932677 ដល់ 78។ លោកស្រីបានឆ្លើយថា៖ "ចំពោះប្រុសៗខ្ញុំឃើញគេដាក់ខ្នោះជើង ហើយគេនាំទៅកាន់កាណូត ហើយក៏យកចេញទៅបាត់ទៅ"។ តើនេះជួយរំឭកដល់ការចងចាំរបស់លោកស្រីទេ ថាពួកបុរសៗគឺត្រូវបានគេដាក់ខ្នោះជើង ហើយគេនាំទៅសំដៅកាណូត រួចហើយក៏យកទៅបាត់ទៅ?

[១៥:២៧:៥២]

**ឆ៖** ខ្ញុំអត់មាននិយាយប្រាប់អ្នកកាសែត ដូចថាអ្នកទៅសម្លាសខ្ញុំហ្នឹង ខ្ញុំអត់ចាំទេកន្លែងហ្នឹងនោះ។ ខ្ញុំឃើញមែន ប៉ុន្តែថាខ្ញុំឃើញតែនៅលើផ្ទះហ្នឹងណា ប៉ុន្តែស្រាប់យប់ថ្ងៃក្រោយ មួយថ្ងៃ ពីថ្ងៃក្រោយមកហ្នឹង វាបាត់មនុស្សហ្នឹងទៅអស់ មិនដឹងគេយកទៅខាងណា។ ខ្ញុំដឹងថាខ្លួនខ្ញុំនិយាយអ៊ីចឹង។

**ស៖** សូមអរគុណលោកស្រី។ ឥឡូវនេះ ខ្ញុំសូមចូលទៅនិយាយអំឡុងពេលមុនៗ នៅពេលដែលលោកស្រីរស់នៅស្វាយឃ្លាំង។ លោកស្រីបានឆ្លើយថា នៅស្វាយឃ្លាំងនេះៗ គឺជាភូមិចាមទេ។ លោកស្រី អាចផ្តល់តួលេខបានទេ ថាមានប្រជាជនចាមប៉ុន្មាននាក់រស់នៅក្នុងភូមិរបស់លោកស្រី? ហើយបើអាចនោះ ថាតើមានបងប្អូនចាមរស់នៅក្នុងឃុំរបស់លោកស្រីហ្នឹងសរុបទាំងអស់ទៅនឹងប៉ុន្មាននាក់ដែរ?

**ឆ៖** ខ្ញុំអត់ដឹងទេ ដឹងថាប៉ុន្មានៗខ្ញុំអត់ដឹងទេ កាលហ្នឹង ខ្ញុំនៅវ័យក្មេងដែរហ្នឹង។ ខ្ញុំអត់ចងចាំទេ ប៉ុន្តែមនុស្សច្រើនដែរនៅស្វាយឃ្លាំងហ្នឹង ចាមនៅភូមិស្វាយឃ្លាំងហ្នឹងវារាប់ពាន់គ្រួសារណោះ មិនមែនរាប់រយទេ។ មានតែប៉ុណ្ណឹង។

**ស៖** តើនៅក្នុងឃុំស្វាយឃ្លាំងនេះមានព្រះវិហារចាមទេ?

**ឆ៖** មាន។ ដល់នៅជំនាន់ពីមុន ពីសង្គមមកមានវិហារដល់ពីរឯណោះ។ រួចដល់មកពួកខ្ញុំបែកបាក់ គេជម្លៀសចេញអស់ទៅហ្នឹង វិហារហ្នឹងក៏បាក់បែកដែរ រលាយអស់ដែរ។

**ស៖** ចុងក្រោយបំផុត ហាក់ដូចជាស្តាប់ការបកប្រែភាសាអង់គ្លេសមិនបានឮត្រង់<ចម្លើយចុងក្រោយរបស់ដើមបណ្តឹងរដ្ឋប្បវេណី>ទេ។

*(មានបញ្ហាបច្ចេកទេស)*

**ប្រធានអង្គជំនុំ៖**

អញ្ជើញៗត!

[១៥:៣១:១៦]

**សួរដោយលោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

**ស៖** ខ្ញុំសូមសួរសំណួរខ្ញុំឡើងវិញ ថាតើនៅឃុំស្វាយឃ្លាំងមានព្រះវិហារដែរឬក៏អត់ទេ? ហើយបើមាន មានព្រះវិហារចំនួនប៉ុន្មានដែរ?

**លោកស្រី នោ សាទះ៖**

**ឆ៖** មានដល់ពីរវិហារ ព្រះវិហារចាមមានដល់ពីរ។ រួចដល់ពីឆ្នាំ៧៥ ពួកខ្ញុំគេជម្លៀសចេញ

ទៅអស់ហ្នឹង វិហារហ្នឹងក៏វាបាក់បែក គេរុះរើអស់រលីង។ មកវិញនៅសល់ដីទទេទេ គេនៅសាងសង់ថ្មីវិញតើឥឡូវហ្នឹង បានវិហារគេធ្វើថ្មីទៀត បាននៅថ្វាយបង្គំរាល់ថ្ងៃនេះ។

**ស៖** តើព្រះវិហារទាំងអស់ហ្នឹងត្រូវបានបែកបាក់ហ្នឹងតាំងពីមុនលោកស្រី តាំងពីមុនគេជម្លៀសលោកស្រី ឬក៏យ៉ាងម៉េច?

**ឆ៖** គេជម្លៀសចេញហើយ បានពួក នៅក្នុងប៉ុល ពត ក្តោបក្តាប់ហើយ បាក់បែកហ្នឹង គេរុះរើអស់ហើយហ្នឹងនោះ ខ្ញុំចេញពីស្រុកភូមិហ្នឹងទៅហើយ។

**ស៖** តើលោកស្រីមានបានដឹងថា ព្រះវិហារទាំងហ្នឹងវាបែកបាក់ដោយសារអ្វីទេ ហើយឬក៏ថាតើមានអ្នកណាជាអ្នកធ្វើឲ្យវិហារហ្នឹងបែកបាក់?

**ឆ៖** អត់ដឹងដែរ មានតែពួកខ្មែរក្រហមហ្នឹងហើយគេរុះ។ ក្រៅពីខ្មែរក្រហមគេអត់ហ៊ានរុះទេរបស់អ៊ីចឹងៗនោះ។

**ស៖** តើខ្មែរក្រហមបានមកដល់ឃុំស្វាយឃ្លាំងនៅពេលណាដែរ?

**ឆ៖** ចាប់ផ្តើមតាំងពីឆ្នាំ៧៥មកហ្នឹង វាធ្ងន់ធ្ងររហូត។ ខ្ញុំអត់ដឹងថាឆ្នាំណាៗទេ ប៉ុនថាខ្ញុំនៅស្វាយឃ្លាំងហ្នឹង កន្លែងដល់ពេលរម្លុបខ្ញុំនៅហ្នឹង និយាយពីថា វាចាប់ផ្តើមពិបាកហ្នឹងពីមុន៧៥មកហើយ គេចាប់ផ្តើមធ្វើសហករណ៍នោះ។ វាយ៉ាប់ម្តងបន្តិចៗ ដល់ចាប់៧៥ហ្នឹងវាមានមនុស្សបះបោរច្របូកច្របល់ហើយ ឈ្លោះគ្នា វៃតប់គ្នាហើយ គេក្រោកឈរឡើង។ វាធ្វើបាប វាចង់បំបាត់សាសនាអស់ហើយនោះ វាអត់ឲ្យយើងថ្វាយបង្គំនៅក្នុងព្រះវិហារទេ តាមផ្ទះក៏វាមិនឲ្យដែរ។ រៀនសូត្រចាម ក៏វាមិនឲ្យដែរ គម្ពីរគូរ៉អានអី វាដុត ដូចថាវាប្រមូល វាមិនដឹងយកទៅខាងណាខាងណីទេ វាអត់ឲ្យយើងកាន់ទេ។ អត់ឲ្យមានមាននៅក្នុងផ្ទះតែម្តងហើយ។

**ស៖** លោកស្រីនៅចាំបានទេថា គម្ពីរគូរ៉ាន់ហ្នឹង ត្រូវបានប្រមូលពីតាមផ្ទះ ហើយដុតចោលហ្នឹងនៅឆ្នាំណាដែរ?

**ឆ៖** រង្វង់៧៥ហ្នឹងហើយ។ ចាប់ផ្តើមបាក់ចែកពីគ្នាចេញពីផ្ទះហ្នឹងទៅ គេប្រមូលហើយ អ្នកដូចថាគេបោសសម្អាតនៅភូមិហ្នឹងនោះ គេអត់ឲ្យមានទេ។ ដឹងគេដុត ដឹងគេយកទៅខាងណាទេ។

[១៥:៣៥:០០]

**ស៖** មុនពេលគេជម្លៀសលោកស្រី តើគេនៅអនុញ្ញាតឲ្យលោកស្រីស្លៀកសម្លៀកបំពាក់ចាមដែរទេ?

**ឆ៖** សម្លៀកបំពាក់ពេលហ្នឹង មានរឿងអីទេ គ្រាន់តែថាវាមានតែខោខ្មៅ អាវខ្មៅ សំពត់ខ្មៅអី ហ្នឹងហើយ មានតែស្លៀកពាក់អ៊ីចឹង។ ចាម ខ្មែរ ស្លៀកពាក់អ៊ីចឹងទៅ គេអត់មានទេ។ មានតែដូចខ្មែរ ទាំងអស់ហ្នឹង ស្លៀកពាក់ធម្មតាដូចបងប្អូនខ្មែរយើងទាំងអស់ហ្នឹង។

**ស៖** លោកស្រីនៅចាំបានទេថា គេឈប់ឲ្យលោកស្រីស្លៀកសម្លៀកបំពាក់ចាមហ្នឹងចាប់ពីត្រឹម ឆ្នាំណាមក?

**ឆ៖** ចាប់ផ្តើមពី៧៥ ទៅដល់ ៧៦ គេផ្តាច់អស់ហើយ គេឲ្យយើងស្លៀកខោខ្មៅ សំពត់ខ្មៅ អាវ ខ្មៅ។ អត់មានស្លៀកពាក់ដូចចាមអ៊ីចេះទេ។ ទាំងគេ ទាំងខ្ញុំហ្នឹង ស្លៀកតែសំពត់ខ្មៅ អាវខ្មៅ ខ្មៅគ្រិបៗ ហ្នុងហើយ។ គេឲ្យតែស្លៀកអ៊ីចឹង អត់មានម៉ូតហ្នឹងអីទេ ដូចឥឡូវហ្នឹងទេ។

**ស៖** ហើយតើសម្លៀកបំពាក់បែបប្រពៃណីរបស់ចាមហ្នឹង គេយកទៅណាទៅ នៅពេលដែល គេលែងអនុញ្ញាតឲ្យស្លៀកពាក់នោះ?

**ឆ៖** ហ៊ើយ! វាបាត់បង់អស់ទៅហើយ យើងបើគេអត់ឲ្យពាក់ហើយ យើងមិនត្រូវបោះចោល។ ពាក់ទៅ វាបានរឿងរ៉ាវទៀតហើយ។

**ស៖** តើស្ត្រីចាម គេអនុញ្ញាតឲ្យទុកសក់វែងដដែលដែរទេ?

**ឆ៖** ពេលហ្នឹងគឺកាត់សក់ខ្លីទាំងអស់ហើយ គ្មានសល់ទេ អត់មានទុកសក់វែង សក់អីទេនៅក្នុង របបហ្នឹង។

**ស៖** តើអ្នកណាប្រាប់លោកស្រីមិនឲ្យប្រើប្រាស់គម្ពីរគូរ៉អាន មិនឲ្យស្លៀកពាក់ប្រពៃណីរបស់ ចាម មិនឲ្យទុកសក់វែង អ្នកណាជាអ្នកប្រាប់ ការហាមឃាត់ទាំងអស់នេះ? <ហើយតើប្រាប់ដោយ របៀបម៉េចដែរ?>

**ឆ៖** ថា "អង្គការ" មួយម៉ាត់ថាអង្គការហ្នឹងមកពីថ្នាក់លើ។ អង្គការមកពីថ្នាក់លើហ្នឹង គេ បញ្ជាគេអត់ឲ្យមានថ្វាយបង្គំ អត់ឲ្យមានពាក់ ស្លៀកពាក់ដូចអ៊ីចេះទេ គេអត់ឲ្យមានក្រមាទូលទេ គេឲ្យ កត់សក់ គេអត់ឲ្យមានគម្ពីរគូរ៉អាន អត់ឲ្យមានសម្លៀកបំពាក់ យើងថ្វាយបង្គំអី អត់ឲ្យមានទេ។ អង្គ ការមកពីថ្នាក់លើ គេបញ្ជាពីថ្នាក់លើ មិនដឹងថាអង្គការណាទេ ខ្ញុំអត់ដឹងទេ។

[១៥:៣៩:០០]

**ស៖** តើការហាមឃាត់ទាំងអស់នេះ គេប្រាប់លោកស្រីនៅក្នុង<អង្គ>ប្រជុំ ឬក៏យ៉ាងណា?

**ឆ៖** ប្រាប់នៅក្នុងអង្គប្រជុំហ្នឹងហើយ គេហៅយើងទៅប្រជុំ។ បើអ្នកណាមិនតាម គឺថាអ្នក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហ្នឹងក្បត់នឹងអង្គការ។

**ស៖** តើអ្នកណាជាអ្នកឡើងនិយាយរឿងការហាមឃាត់នេះនៅក្នុងអង្គប្រជុំ។

**ឆ៖** វាមានមេឃុំ មានប្រធានភូមិ អនុភូមិ សមាជិកភូមិ។ គេមកហៅប្រជុំ គេកោះហៅប្រជុំមួយភូមិហ្នឹងណ៎ា គេប្រាប់ គេឃោសនាប្រាប់ បើអ្នកណាមិនតាម អ្នកហ្នឹងខ្មាំង។

**ស៖** តើមានហាកឹម <ឬហាកឹមរង> ដែរទេនៅឃុំស្វាយឃ្លាំង?

**ឆ៖** មានៗរឿងហាកឹម មាន ប៉ុន្តែដល់ពេល៧៥ហ្នឹងរលាយអស់ហើយ គ្មានសល់ទេ អត់មានហាកឹម អត់មានអីទេ។ ពីអើយមកហ្នឹងមាន ដល់ពេល៧៥ហ្នឹង វារលាយ ដូចថារលាយទាំងអស់ចាម វាគ្មានសល់ទេ សូម្បីថានិយាយ ក៏គេមិនឲ្យនិយាយដែរ នៅជួបជុំគ្នាដូចថាបី បួននាក់សុទ្ធតែចាមហ្នឹង គេមិនឲ្យជួបជុំទេ ទាល់តែមានបងប្អូនខ្មែរម្នាក់ ឬមួយថាពីរនាក់នៅរួមគ្នាជាមួយគ្នាបានៗ បើអ៊ីចឹងទេ គេថាយើងហ្នឹងខ្មាំង។

**ស៖** តើលោកស្រីដឹងថាហាកឹម ទាំងនោះទៅណាដែរ ដោយសារថាគេលែងឲ្យមានហាកឹមទៀតហើយនៅឆ្នាំ១៩៧៥?

**ឆ៖** លោកហាកឹមពេលហ្នឹងនោះ ហាកឹម ពីជំនាន់៧៥ហ្នឹង គេយកទៅអស់ហើយ អត់មានសល់ទេ អត់មានដឹងគេយកទៅខាងណាទេ គេយកទៅដាក់គុក ដាក់ច្រវាក់អស់ហើយ។ អ្នកហាតួនហាក់គឹម អ្នកចេះដឹង ដូចសាស្ត្រាចារ្យអីនោះ អត់មានឲ្យនៅទេ ចាប់អស់ហើយ ប្រមូល ដោយសាររឿងអ៊ីចឹងហើយ បានវាមានការបះបោរនៅស្វាយឃ្លាំងនេះ។

**ស៖** នៅពេលដែលគេកំពុងតែជម្លៀសលោកស្រីចេញពីភូមិរបស់លោកស្រីនោះ តើគេមានប្រាប់លោកស្រីថា ហេតុអីបានជាត្រូវជម្លៀសលោកស្រីចេញទេ?

[១៥:៤២:៣៧]

**ឆ៖** គេអត់ប្រាប់ទេ ប៉ុនថាវាត្រូវតែគេជម្លៀស ពីព្រោះខ្ញុំហ្នឹងក្រោកឡើង ឈរឡើងបះបោរប្រឆាំងនឹងពួកវា វាធ្វើបាបពេក មួយយប់វាយក៣០នាក់ ៤០នាក់ វាយកទៅដាក់គុក។ អាអ្នកស្លូតត្រង់អត់ដឹងអីហ្នឹង ក៏វាចោទថាស័ក្តិ២ ស័ក្តិ៣ ស័ក្តិ៤ ស័ក្តិ៥ដែរ។ អ៊ីចឹងហើយបានវាយកទៅដាក់គុកនោះនៅៗក្រូចឆ្មារនេះ គុកនៅក្រូចឆ្មារហ្នឹងគេៗរម្លុបចោលហើយ ឥឡូវហ្នឹងគេធ្វើផ្ទះថ្មីនៅហើយ គុកនៅក្រូចឆ្មារហ្នឹងដាក់សុទ្ធតែអ្នកទោស ទោសអត់ដឹងអីហ្នឹង អ្នកអត់ ដូចថាគ្មានដឹងអីទេ គេចោទសុទ្ធតែស័ក្តិ១ ស័ក្តិ២ ស័ក្តិ៣, សេ.អ៊ី.អា អាមេរិកាំង។ រួចអ្នកដាក់ត្រូវទោសហ្នឹង ពួកហ្នឹងអ្នកដែលទៅ គេ

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ចាប់ទៅហ្នឹង អត់ដែលបានមកវិញទេ បានមកម្នាក់មួយៗហ្នឹង បានមកប្រហែលកន្លះខែ មួយខែ ស្លាប់ទៅវិញហើយ ឈឺនិយាយពីហើមស្គរៗ បើស្គមវិញ ដូចកង្កែបខែប្រាំងអ៊ីចឹង។

**ស៖** សូមអរគុណលោកស្រី។ ខ្ញុំសួរលោកស្រីបន្តទៅទៀត ហើយសុំលោកស្រីឆ្លើយខ្លីៗបានហើយ ដោយសារខ្ញុំនៅសល់ពេលវេលាតិចតួចពេក។ នៅពេលដែលកំពុងជម្លៀសលោកស្រីចេញពីភូមិហ្នឹង តើលោកស្រីមានបានឮអំពីការប្រកាស ការជម្លៀសនេះដែរទេ?

**ឆ៖** គេឲ្យពួកខ្ញុំចេញទៅ គេអត់ឲ្យនៅទេ គេបោសសម្អាតខ្លាំង ឮតែប៉ុណ្ណឹងហើយ គេប្រកាសប្រាប់មេក្រុ គេថាឲ្យយើងចេញឲ្យអស់ៗ អ្នកណាមិនចេញ អ្នកហ្នឹងខ្លាំង។ ដែលពេលនោះហើយបានវាចេញៗអស់នោះ យើងទម្លាក់អាវុធដូចថា កាំបិតភ្នកអី កាំបិតអីហ្នឹង យើងតដៃជាមួយពួកវាហ្នឹងលែងហើយ យើងចាញ់គេហើយ ពីព្រោះគ្រាប់កាំភ្លើងវារះដូចទឹកភ្លៀង។ បះបោរនៅស្វាយឃ្លាំងនេះដឹងស្រាប់ហើយបងប្អូនដែលឮដែរ។

[១៥:៤៥:១៩]

**ស៖** លោកស្រីនិយាយថា ពួកគេបាញ់រះគ្រាប់កាំភ្លើងដើម្បីឲ្យលោកស្រីចាកចេញពីភូមិ អ៊ីចឹងឬក៏យ៉ាងណា?

**ឆ៖** បាញ់រះហ្នឹង អ្នកណាតដៃគេបាញ់រះអ៊ីចឹងហើយ យើងតដៃហ្នឹង រួចដល់អ៊ីចឹងគេឲ្យយើងចាកចេញពីភូមិហ្នឹងហើយ គេឲ្យយើងចេញនោះ ចេញដោយសម្រួលទៅគេអត់បាញ់ទេ បើយើងចេញអត់ចេញទេ គេបាញ់ហើយ។ ពេលដែលនៅបះបោរហ្នឹង វាបាញ់ៗរះ។

**ស៖** លោកស្រីលើកឡើងចំណុចនេះ ពីខាងដើមរួចហើយ ប៉ុន្តែលោកស្រី សូមជម្រាបជូនតុលាការមើលថាតើមានរឿងអ្វីកើតឡើងចំពោះឪពុកលោកស្រីនៅពេលដែលគេជម្លៀសលោកស្រីចេញពីភូមិនោះ?

**ឆ៖** កើតឡើងចំពោះឪពុក ឪពុកខ្ញុំៗហ្នឹងនៅជាមួយក្រុមគ្រួសារពួកខ្ញុំហ្នឹងហើយ ដែលបះបោរហ្នឹង ដល់ពេលគេឲ្យចេញទៅ ទៅឆ្លងស្ពានស្វាយឃ្លាំងហ្នឹងហើយ ស្ពានព្រែកចាមហ្នឹង ទៅនៅត្រើយខាងណោះ។ គេឃាត់ឪពុកខ្ញុំនៅកន្លែងហ្នឹងហើយ នៅមាត់ស្ពានហ្នឹង ឃាត់ទាល់តឡូវហ្នឹងហើយគ្មានផ្លូវមកវិញទេ អត់ឃើញទេ។

**ស៖** នៅពេលដែលលោកស្រីបានឃើញគេឃុំខ្លួនលោកឪពុករបស់លោកស្រីហ្នឹង តើលោកស្រីមានបានឃើញអ្នកដទៃទៀត ដែលគេឃុំជាមួយឪពុកលោកស្រីហ្នឹងដែរទេ?

**ឆ៖** ឃើញ មនុស្សនៅពេញ សុទ្ធតែយុវជន ហើយនិងបុរសៗ។ ពួកដែលឃាត់ហ្នឹង សុទ្ធតែអ្នកខ្លាំងហើយនោះ។

[១៥:៤៧:៣៥]

**ស៖** ហើយលោកស្រីបាននិយាយថា <>លោកស្រីត្រូវបានគេឃុំខ្លួននៅ<ក្នុងឃ្លាំងឡ។> តើគេមាន<>ចាប់ខ្លួនអ្នកដទៃទៀតដែរទេ <នៅពេលដែលលោកស្រីត្រូវបានគេឃុំខ្លួននៅក្នុងឃ្លាំងឡអស់ពេលមួយខែនោះ>?

**ឆ៖** ពេលពួកខ្ញុំឃុំខ្លួនហ្នឹង ទៅពីៗមាត់ស្ពានព្រែកចាមហ្នឹងទៅហ្នឹង គេឲ្យទៅនៅក្នុងឡ ឃ្លាំងឡគេដាក់ថ្នាំណា គេឃុំពួកខ្ញុំនៅសុទ្ធតែនារីខាងស្រីៗនារី អ្នកមានកូនកុមារ ហើយនិង ពួកខ្ញុំហ្នឹងនៅតូចៗដែរ កាលហ្នឹងអាយុខ្ញុំអត់ម្ភៃទេ អាយុខ្ញុំទើប ១៧ទេ។ គេឃាត់ទាំងអស់ មួយពេញមួយឃ្លាំងឡហ្នឹង ក្មេងកុមារតូចៗក៏មានដែរ និយាយពីយំស្រែកដូចកូនសត្វវានៅជួបជុំចូលសំបុកអ៊ីចឹង។ វាឃ្លានបាយ ឃ្លានបបរ បបរចែកឲ្យគ្នាម្នាក់មួយវែក រួចសុទ្ធតែទឹក រួចអត់មានអីឲ្យស៊ីទៀត សុទ្ធតែ ដាក់អំបិលឲ្យ អត់ដាក់អំបិលឲ្យទៀត ឲ្យតែបបរសុទ្ធ។

**ស៖** សូមអរគុណលោកស្រី ហើយបន្តទៅមុខទៀតនេះ ក៏សូមឲ្យឆ្លើយខ្លីៗហើយ។ សំណួរខ្ញុំសួរថា តើលោកស្រីមានដឹងថាមានការចាប់ខ្លួនដែរទេ នៅពេលដែលគេឃុំខ្លួនលោកស្រីនៅក្នុងឡថ្នាំនោះ?

**ឆ៖** គេយកទៅឃុំនៅហ្នឹង គេនៅជ្រើសរើស គេរកខ្លាំង អ្នកណាដែលខ្លាំង អ្នកណាដែលប្រឆាំងនឹងអង្គការ គេចាប់ បើអ្នកអត់ប្រឆាំងទេ មើលទៅថាមនុស្សហ្នឹងអត់អីទេ គេទុក។ ដល់មួយខែបីថ្ងៃ បានគេឲ្យពួកស្រីៗហ្នឹងចេញពីឡឃ្លាំងហ្នឹងទៅហ្នឹងណា មួយខែបីថ្ងៃ បានគេឲ្យចេញ គេជម្លៀសទៅនៅតាមភូមិ តាមឃុំ ទៅខាងណាខាងណី ដូចថា ខាងស្រុកស្រែទៅ ខាងសូភាស ខាងស្រែវាលខាងស្ទឹងត្រង់អ៊ីចឹងទៅ ទៅនៅខាងណោះទៅ។ រួចណោះ ខាងពួកមេម៉ាយៗនេះ គេឲ្យទៅនៅជួរមុខក្រូចឆ្មារហ្នឹងហើយ អ្នកដែលគេយកប្ដីទៅបាត់បង់អស់ប្ដីហ្នឹងបាត់ទៅហើយហ្នឹង គេយកទៅហើយហ្នឹង អត់ឃើញហ្នឹង បាត់ហើយ ដឹងថាបាត់ហើយហ្នឹង។ គេឲ្យនៅជួរមាត់ទន្លេ។

**ស៖** បាទ ខ្ញុំព្យាយាមសួរលោកស្រីម្តងទៀត។ នៅពេលដែលគេឃុំខ្លួនលោកស្រីនៅឡថ្នាំ នៅពេលនុ៎ង តើលោកស្រីមានបានដឹងថាគេចាប់ខ្លួនអ្នកណាផ្សេងទៀតដែរទេ?

**ឆ៖** វាមានច្រើនកន្លែង គេដាក់មនុស្សទោសទៅណ៎ា ថាទោសទៅចុះ ទាំងគេទាំងខ្ញុំហ្នឹង។ វា

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មានក្រូចឆ្មារលើ ក្រូចឆ្មារក្រោម វាមានដើមជ្រៃនៅក្នុងវត្ត។ ដល់អ៊ីចឹងគេជ្រើសរើសអស់ហើយ បានគេឲ្យយើងចេញពីភូមិពីនេះហ្នឹង។ ជម្លៀសហើយ គេចេញហើយ ជាងមួយខែ១ បីថ្ងៃ។ អ្នកណាអត់មែនខ្មាំងណោះ អ្នកហ្នឹងជួបប្រពន្ធនិងកូនវិញទៅ។ បើអ្នកខ្មាំងហើយអត់មានជួបទេទាល់ឥឡូវហើយ។ ដូចឪពុកខ្ញុំហ្នឹងវាបាត់ទាល់ឥឡូវហ្នឹង ដោយសាររឿងអី គេថាខ្មាំងស័ក្តិ៤, ស័ក្តិ៥ឯណោះ, សេ.អ៊ី.អា អាមេរិកាំង សុទ្ធតែខ្មែរអាមេរិកាំង។ ឪពុកខ្ញុំអត់ទាំងចេះអក្សរខ្មែរមួយនេះទេ គេចោទអ៊ីចឹងដែរ។

[១៥:៥១:៥៩]

**ស៖** សូមអរគុណ ឥឡូវនេះសូមបន្តទៅមុខទៀត។ ទៅដល់ពេលលោកស្រីនៅខ្សាច់ប្រឆេះលើ <។> ពេល<ដែល>កម្មាភិបាលកពីភូមិភាគនិរតីបានមកដល់ទីនោះ តើលោកស្រីដឹង<ដែរឬទេ>?

**ឆ៖** មិនមែនអ៊ីចឹងទេ ទៅមុនៗដំបូង ទៅនៅខ្សាច់ប្រឆេះលើហ្នឹងគេជម្លៀសខ្ញុំឲ្យទៅនៅខ្សាច់ប្រឆេះលើហ្នឹងគេឲ្យខ្ញុំទៅធ្វើការ ពួកនិរតីវាមិនទាន់មកទេ។ ដល់មក៧៦-៧៧ នេះបានពួកនិរតីវាមក វាធ្វើដូចថាវាប្រមូលចាមហ្នឹង។ អាហ្នឹងវាមិនទាន់ដល់វគ្គខ្ញុំឆ្លើយទេ។ មកនៅខ្សាច់ប្រឆេះលើហ្នឹងគេឲ្យខ្ញុំទៅធ្វើតាមសហករណ៍ ទៅជីកប្រឡាយ ជីកអីហ្នឹងហើយ។ ដល់ខែប្រាំងគេឲ្យខ្ញុំទៅជីកលើកទំនប់នៅបឹងក្រចាប់។ អាហ្នឹងលើកទី១ នៅឆ្នាំទី១។ ឆ្នាំទី២ ទៅបឹងក្រចាប់ដែរ ប៉ុន្តែរួចពីបឹងក្រចាប់ទៅនៅទឹកជ្រៅ។ ទៅទឹកជ្រៅហ្នឹងហើយបានវាថា ដូចថាវាសាហាវឃោរឃៅមែនទែន ធ្វើការទាំងថ្ងៃទាំងយប់។ មួយថ្ងៃ៣ម៉ែត្រគូប រែកមិនរួច យប់ធ្វើការទៀតទាល់ម៉ោង១០។ ភ្លៀងហើយយប់ហ្នឹង ដេកហាលភ្លៀងហើយហ្នឹង ភ្លឺឡើងទៅធ្វើការទៀត។ ដេកលើផ្នូរខ្មោចក៏មាន ដេកលើដីពីរបីខែឯណោះ។

**ស៖** លោកស្រី ខ្ញុំសួរអំពីពេលវេលាជាក់លាក់ នៅពេលដែលកម្មាភិបាលនិរតីមកដល់ខ្សាច់ប្រឆេះលើ។ <ខ្ញុំយល់ហើយថា លោកស្រីនៅក្នុងកងចល័តនៅមុនពេលហ្នឹង ប៉ុន្តែ>ខ្ញុំមិនសួរ<លោកស្រីពីរយៈពេលនោះ>ទេ <ខ្ញុំកំពុង>សួរថា តើកម្មាភិបាលនិរតីមកដល់ខ្សាច់ប្រឆេះលើនៅពេលណា<ឬឆ្នាំណាដែរ?>

[១៥:៥៤:៤៦]

**ឆ៖** វាមានច្រើនដែរហ្នឹងហើយ វាមកហ្នឹងមិនដឹងពេលណាទេ ពេលនិរតីវាចូលមកហ្នឹង ដឹងខែណាពេលណាទេ ខ្ញុំអត់ចំណាំទេ ប៉ុន្តែខ្ញុំចំណាំថាវាមកហ្នឹងវាធ្វើសកម្មភាពលើប្រជាជនហ្នឹង វាដូចថាអ្នកណាធ្វើខុសបន្តិចបន្តួចហ្នឹង ដូចថាវា១យកទៅហើយ វាអត់ទុកទេ។ រួចដល់អ៊ីចឹងទៅ ដល់មកវគ្គក្រោយនេះទៀត វា១បោសសម្អាតសុទ្ធតែជនជាតិចាមយើងហ្នឹងហើយ វាប្រមូលឲ្យអស់ អត់ឲ្យមាន

សល់ទេ។ វាឲ្យថា វាថាផ្លាស់ទីលំនៅ ថានៅខាងស្ទឹងត្រង់នោះ វាមានការងារធ្វើ មានបាយបគ្រប់គ្រាន់ នៅឯណេះវាអត់មានការងារធ្វើទេ ដល់អ៊ីចឹងប្រជាជនក៏ចេះតែតាមទៅ គេក៏ដឹកទៅ ដល់ដឹកទៅ ដឹកទៅ ឥឡូវហ្នឹង គ្មានឃើញមកវិញឯណា។

**ស៖** ហើយថាតើកម្មាភិបាលនិរតីហ្នឹងសម្រេចថាអ្នកណាជាចាម អ្នកណាមិនមែនជាចាមដោយរបៀបណា?

**ឆ៖** អ្នកធ្វើការហ្នឹង ខាងនិរតីហ្នឹង វាឲ្យអ្នកធ្វើការនៅក្នុងស្រុក ក្នុងភូមិហ្នឹងដើរប្រមូល។ ប្រធានភូមិ អ្នកដើរចុចឈ្មោះថា អ្នកនេះចាមៗៗ។ គេឲ្យរបាយការណ៍ទៅឲ្យអ្នកនិរតីហ្នឹង អ្នកធ្វើការខាងនិរតីហ្នឹង។ ចៅហ្វាយស្រុកអីហ្នឹង វាឲ្យដើរប្រមូលធ្វើអ៊ីចឹង អ្នកណាចាមខ្លះនុ៎ង កត់បញ្ជីបង្ហើយឲ្យវាមក វាប្រមូល វាអត់ឲ្យនៅ។

[១៥:៥៦:៤៤]

**ស៖** ហើយនៅពេលដែលគេរៀបបញ្ជីប្រជាជនចាម តើមានអ្វីកើតឡើងចំពោះចាមប្រុសៗនៅខ្សាច់ប្រឆេះលើហ្នឹង?

**ឆ៖** វាអត់មានកើតអីទេ មានតែគេយកគេប្រមូលយកទៅទាំងអស់ហ្នឹង ខាងប្រុសៗ។ វាប្រមូលទៅមុន វាថាឲ្យយកទៅធ្វើផ្ទះនៅ។ ឲ្យស្រីៗទៅក្រោយមកថ្ងៃ ប្រុសទៅថ្ងៃហ្នឹង ពួកស្រីៗទៅស្អែក ឲ្យប្រុសៗហ្នឹងទៅៗធ្វើផ្ទះ វាថាឲ្យទៅធ្វើផ្ទះ ឲ្យស្រីៗនៅ។ រួចដល់អ៊ីចឹងទៅ ប្រុសៗទៅមួយថ្ងៃហ្នឹងទៅ ភ្លឺឡើងហ្នឹង គេប្រមូលស្រីៗទៅទៀតហ្នឹង ទៅអស់ហើយ ទាំងតូច ទាំងធំហ្នឹង។

**ស៖** តើលោកស្រីអាចជម្រាបជូនតុលាការអំពីការប្រមូលស្ត្រីជនជាតិចាមពីខ្សាច់ប្រឆេះលើហ្នឹង គេប្រមូលដោយរបៀបណាដែរ?

**ឆ៖** គេហៅដូចមកអង្គប្រជុំហ្នឹង ដូចគេយកមកប្រជុំអ៊ីចឹង ប្រជុំទាំងអស់ហ្នឹង បងប្អូនចាមយើងហ្នឹង។ គេហៅមកប្រជុំហ្នឹង គេប្រាប់ ហើយគេឲ្យផ្លាស់ទីលំនៅទៅខាងនេះ ខាងនោះហ្នឹង។ ពួកប្រធានភូមិហ្នឹងហើយ អ្នកដើរប្រមូល។ គេឲ្យប្រធានភូមិដើរប្រមូល។

[១៥:៥៨:៣៤]

**ស៖** ហើយថាតើពេលគេផ្លាស់ទីលំនៅប្រជាជនចាមទាំងនេះ ទៅភូមិថ្មីដោយរបៀបណាដែរ?

**ឆ៖** គេហៅទៅហ្នឹង ជិះកាណូត ជិះកប៉ាល់ទៅហ្នឹងហើយ ទៅៗចុះស្ទឹងត្រង់ហ្នឹងហើយ ដាក់សាឡាងធំ មួយសាឡាងហ្នឹងហើយ ទៅហើយ មនុស្សពីរបីរយនាក់ ក៏មិនទាបដែរ។

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**ស៖** ខ្ញុំសល់តែពីរបីសំណួរទៀតទេ។ ទី១ គឺទាក់ទងទៅនឹងជនជាតិចាមទាំងប្រុស ទាំងស្រី ដែលគេប្រមូលចេញពីភូមិខ្សាច់ប្រឆេះលើ។ តើមានទំនាក់ទំនងគ្នាដែរ តើមានការទាក់ទងគ្នារវាងបុរសចាម ស្ត្រីចាម<ទាំងនោះដែលត្រូវបានគេ>បញ្ជូនចេញពីភូមិខ្សាច់ប្រឆេះលើ <ក្រោយការមកដល់របស់>កម្មាភិបាលមកពីនិរតីនុ៎ង <ដែរឬទេ? តើមានសមាជិកក្រុមគ្រួសាររបស់លោកស្រី ដែរឬទេ>?

**ឆ៖** អត់មានទាក់ទងអីទេ ដឹងថាគេប្រមូលហ្នឹងទាំងប្រុស ទាំងស្រីហ្នឹងហើយ មានរឿងអីទៅទាក់ទងអី។ បើកាលហ្នឹងដើរទៅភូមិមួយៗ កាត់ពីភូមិខ្សាច់ប្រឆេះលើទៅខ្សាច់ប្រឆេះកណ្តាលហ្នឹង អត់បានទេ គេអត់ឲ្យដើរកាន់នេះទេ។ គិតតែពីធ្វើការងារនៅក្នុងសហករណ៍ហ្នឹងហើយ។ អត់មានរឿងអីដឹងទេ មានតែប៉ុណ្ណឹង។ បើគេហៅទៅៗហើយ ទៅៗទាំងអស់គ្នាហ្នឹង។ មានរឿងអីទាក់ទងដូចសម័យឥឡូវមានទូរស័ព្ទអី យើងចេះលួចខ្សឹបប្រាប់អ្នកនេះប្រាប់អ្នកនោះ អត់មានទេ។

**ស៖** ខ្ញុំមិនគួរប្រើពាក្យថា មានការទាក់ទងគ្នានោះទេ។ អ៊ីចឹងសួរអ៊ីចេះវិញ ថាតើ<មាន> សមាជិកគ្រួសាររបស់លោកស្រី<ដែរឬទេ ដូចជា> ឪពុកម្តាយ <បងប្អូនបង្កើត> បងប្អូនស្រី បងប្អូនប្រុស តើពួកគាត់ទាំងអស់នោះស្ថិតនៅក្នុងចំណោមប្រជាជនចាមទាំងអស់ដែលគេប្រមូលចេញពីភូមិខ្សាច់ប្រឆេះលើដែរទេ?

**ឆ៖** គេប្រមូលទាំងអស់ហ្នឹងហើយតើ បងប្អូនទាំងស្រី ទាំងប្រុស ទាំងប្អូនខ្ញុំប្អូនប្រុសពីរនាក់ ស្រីប្អូននាក់ទាំងខ្ញុំ ជីដូនខ្ញុំម្នាក់ ម្តាយខ្ញុំម្នាក់ គេប្រមូលទាំងអស់ ទាំងហ្នង ទាំងគេទាំងម្តាយខ្ញុំហ្នឹងហើយ ទាំងគេ ទាំងដូចថាអ្នកស្រុកភូមិហ្នឹងទៅជាមួយគ្នាហ្នឹង អ្នកនៅជាមួយគ្នាហ្នឹង។

**ស៖** តើក្រោយមក លោកស្រីបានជួបនឹងពួកទាំងពួកគាត់ទាំងនោះឡើងវិញទេ?

**ឆ៖** អត់ជួបទេ។ ទៅហ្នឹង ទៅបាត់ទល់រាល់ថ្ងៃហ្នឹងហើយ។

**ស៖** តើប្រជាជនខ្មែរត្រូវបានគេជម្លៀសចេញពីភូមិខ្សាច់ប្រឆេះលើដែរទេ នៅពេលនោះ?

**ឆ៖** វាមាន មាន គេជម្លៀសដូចថា គេជម្លៀសទៅ ដូចថានៅខ្សាច់ប្រឆេះលើ គេជម្លៀស រកាខ្នុរ បងប្អូនខ្មែរយើងហ្នឹងណា។ ប៉ុន្តែគេអត់យកទៅវ៉ៃចោលទេ ចំណែកប្រជាជនសុទ្ធសាធហ្នឹង បើអ្នកនៅធ្វើការនៅអង្គភាព វាយកទៅអស់ហើយ បងប្អូនខ្មែរ វាអត់ទុកទេ អ្នកនៅអង្គភាព វាឲ្យទៅនៅអង្គភាព ដូចថានៅតាមក្រសួងៗ វាឲ្យទៅនៅតាមក្រសួង។ ប៉ុន្តែនៅតាមក្រសួងឯណា បាត់ទាល់រាល់ថ្ងៃនេះ។

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

សូមអរគុណលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ សូមអរគុណលោកប្រធាន។ ខ្ញុំអស់សំណួរហើយ។

[១៦:០៣:១១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សវនាការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារ ទី ២៩ ខែកញ្ញា ឆ្នាំ២០១៥ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី នោ សាទះ បន្តបញ្ចប់ ហើយនិងផ្ដើមស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-845 ហើយសូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

ហើយអង្គជំនុំជម្រះអរគុណលោកស្រី នោ សាទះ ដំណើរការស្ដាប់សក្ខីកម្មរបស់លោកស្រីក្នុងឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកស្រីឲ្យមកបន្តផ្ដល់សក្ខីកម្មនៅព្រឹកថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួន។

ហើយអង្គជំនុំជម្រះក៏អរគុណដែរបុគ្គលិកគាំពារសាក្សី និងអ្នកជំនាញ ដោយការស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះមិនទាន់ចប់ អង្គជំនុំជម្រះអញ្ជើញកញ្ញាមកបន្តចូលរួមក្នុងការអង្គុយអមសាក្សីរូបនេះនៅក្នុងពេលដែលដើមបណ្ដឹងរដ្ឋប្បវេណីនេះផ្ដល់សក្ខីកម្មនៅព្រឹកថ្ងៃស្អែកទៀត។

ហើយបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះទៅកាន់កន្លែងដែលគាត់ស្នាក់ ហើយនិងឲ្យអញ្ជើញ គាត់ត្រឡប់មកចូលរួមសវនាការផ្ដល់សក្ខីកម្មនៅព្រឹកថ្ងៃស្អែកទៀតចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅថ្ងៃស្អែកវិញ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៥នាទី)*